ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Dec-2011, 13:58
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១១**

**ម៉ោង ០៩: ១៥នាទី**

**សវនាការលើកទី៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី
កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*
លោក ដាវ អានសាន

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វីល្លៀម ស្មីត *(Mr. William SMITH)*
លោក សេង ប៊ុនឃាង
លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*
លោក ច័ន្ទ តារាវស្មី
លោក ឌេល លីសាក់ *(Mr. Dale LYSAK)*
លោក វេង ហ៊ត់

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក គីម ម៉េងឃី

លោក ឡោ ជុនធី

លោក ហុង គីមសួន

លោកស្រី នូស៊ីន សាកាវ៉ាទី

*(Ms. Nushin SAKARATI)*

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍

*(Ms. Philipine SUTZ)*

លោក ប៉ាស្កាល់ អូប៊ីង

*(Mr. Pascal AUBOIN)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**មន្ត្រីអង្គភាពគាំពារសាក្សី/អ្នកជំនាញ៖**

លោក ញ៉ែម សំណាង

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ច័ន្ទ តារាវស្មី | ខ្មែរ |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក អេនឌ្រូ អ៊ីនូហ្វ៊ី | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោក រម៉ាម យុន (TCCP-123) | ខ្មែរ |
| លោក ឡុង នរិន្ទ (TCW-395) | ខ្មែរ |
| លោក ញ៉ែម សំណាង | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី រ៉ោម យុន** (TCCP-123)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ០៥

សួរដោយលោក គីម ម៉េងឃី ផ្តើមពី....................ទំព័រ ០៧

សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯលៈ....................ទំព័រ ២៨

សួរដោយលោក ច័ន្ទ តារាស្មី ផ្តើមពី ....................ទំព័រ ៤១

**ការសួរសំណួរទៅសាក្សី ឡុង នរិន្ទ** (TCW-395)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ៥០

សួរដោយលោក ឌេល លីសាក់ ផ្តើមពី ....................ទំព័រ ៥៦

# កិច្ចដំណើរការនីតិវិធី

[០៩:១៥:៣៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះសាលដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ កាលពីម្សិលមិញអង្គជំនុំជម្រះបានជម្រាបជូនដំណឹងដល់ភាគី និងសាធារណជនថា នៅព្រឹកនេះអង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ក្លាន ហ្វិត ហើយនិងរសៀលបន្តការស្ដាប់ចម្លើយជនជាប់ចោទ នួន ជា។ ប៉ុន្តែដោយមូលហេតុ ក្លាន ហ្វិត មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅព្រឹកនេះបាន ដោយបញ្ហាសុខភាព។

ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចផ្អាកការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះសិន។ ឯការស្ដាប់ដើមបណ្ដឹងរដ្ឋប្បវេណី ក្លាន ហ្វិត នេះអង្គជំនុំជម្រះលើកទៅពេលក្រោយ គឺនឹងកំណត់ពេលវេលាសមស្របសម្រាប់បន្តការស្ដាប់សក្ខីកម្មរបស់គាត់។

[០៩:១៧:៣៧]

ទីពីរ ដោយតាមគម្រោងផែនការអង្គជំនុំជម្រះត្រូវស្ដាប់នូវសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីររូបនាចាប់ផ្ដើមដំបូងៗនៃកិច្ចដំណើរការសវនាការដេញដោលពិនិត្យភស្តុតាង។ ដូច្នេះ នៅព្រឹកនេះអង្គជំនុំជម្រះសម្រេចស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី TCCP-123 ដោយសារគាត់មានវត្តមាននៅ អ.វ.ត.ក នេះរួចហើយ។

ទីបី មានការផ្លាស់ប្ដូរដោយពីម្សិលមិញ អង្គជំនុំជម្រះបានជម្រាបជូនដំណឹងផងដែរ អំពីលទ្ធភាពនៃការរំពឹងទុកថានឹងបានស្ដាប់សក្ខីកម្មរបស់សាក្សី TCW-395 ដោយមូលហេតុបញ្ហាសុខភាពរបស់សាក្សីរូបនេះមិនអំណោយផលឲ្យអង្គជំនុំជម្រះពន្យារពេលនៅក្នុងការស្ដាប់សាក្សីរូបនេះឡើយ។

[០៩:១៨:៥០]

ហើយពីម្សិលមិញយើងបានត្រៀមលក្ខណៈសម្បត្តិ ដើម្បីទទួលព័ត៌មានអំពីបញ្ហានៃការរៀបចំការស្ដាប់សក្ខីកម្មរបស់សាក្សីរូបនេះតាមប្រព័ន្ធសោតទស្សន៍ ដែលធ្វើពីចម្ងាយ ដោយសារគាត់សុខភាពគាត់ចាស់ជរា ហើយនិងបញ្ហាសុខភាពធ្ងន់ធ្ងរផង យើងធ្វើពីចម្ងាយ។ ប៉ុន្តែទទួលព័ត៌មានមិនបាន រហូតដល់ព្រឹកមិញនេះទើបយើងទទួលព័ត៌មាន។

ដូច្នេះ ចាប់ពីរសៀលនេះទៅអង្គជំនុំជម្រះសាលាដំបូងនឹងស្ដាប់សក្ខីកម្មរបស់សាក្សីTCW-395 ដោយធ្វើតាមប្រព័ន្ធសោតទស្សន៍ ហើយតាមការប្រមើលមើលនូវពេលវេលា និងសារៈសំខាន់នៃសាក្សីរូបនោះ ទាំងបញ្ហាសុខភាពផង អង្គជំនុំជម្រះប្រមើលមើលថា លទ្ធភាពនៃការសួរសាក្សីនោះនឹងអាចបន្តរហូតដល់ទៅថ្ងៃស្អែក។

[០៩:១៩:៥៧]

ទីបួន បញ្ហាការពិភាក្សាដេញដោលស្ដាប់ចម្លើយជនជាប់ចោទ ជាពិសេសលោក នួន ជា ដែលអង្គជំនុំជម្រះបានធ្វើពីដើមដំបូង ហើយកាលពីម្សិលមិញមានគ្រោងធ្វើនៅរសៀលនេះ។ ប៉ុន្តែ ដោយមូលហេតុដូចជម្រាបជូនខាងលើនេះ អង្គជំនុំជម្រះសម្រេចលើកការស្ដាប់ចម្លើយជនជាប់ចោទទាំងអស់ គឺទាំង នួន ជា និងទាំងជនជាប់ចោទផ្សេងទៀតទៅសប្ដាហ៍ក្រោយ លើកលែងតែកាលៈទេសៈប្រែប្រួលដែលអង្គជំនុំជម្រះរក្សាសិទ្ធិនៅក្នុងការរៀបចំកែប្រែនូវលំដាប់នៃការស្ដាប់ចម្លើយជនជាប់ចោទ ឬសក្ខី-កម្មនេះទៅតាមករណីស្ថានភាពជាក់ស្ដែង។

មន្ត្រីតុលាការសូមអញ្ជើញសាក្សី TCCP-123 ចូលមកកាន់បន្ទប់សវនាការ!

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន មុនពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីមកដល់នេះ ខ្ញុំសូមលើកសេចក្ដីសង្កេតមួយសិន។ ខ្ញុំយល់ថា កាលពីម្សិលមិញ ក្រោយពីដើមបណ្ដឹងរដ្ឋប្បវេណីផ្ដល់សក្ខីកម្មមួយផ្នែក បន្ទាប់មកសម្រាកនោះ ដើមបណ្ដឹងរដ្ឋប្បវេណីក៏បានជួបជាមួយនឹងបុគ្គលផ្សេង ហើយជួបពិភាក្សាជាមួយបុគ្គលមួយចំនួន។

ដូច្នេះ នៅពេលដែលសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី គាត់មកផ្ដល់សក្ខីកម្មនេះ យើងមិនគួរអនុញ្ញាតឲ្យគាត់ប្រាស្រ័យទាក់ទងជាមួយអ្នកផ្សេងនោះទេ មិនថាគាត់ជាដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏សាក្សីនោះទេ។ ដូច្នេះហើយ ជាការអនុវត្តបទដ្ឋានរបស់យើងហ្នឹង យើងគួរតែអនុវត្តគ្រប់ទៅលើបុគ្គលដែលជាសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីមិនឲ្យគាត់ប្រាស្រ័យទាក់ទងទេ ដរាបណាសក្ខីកម្មគាត់មិនទាន់បានផ្ដល់ចប់។ សូមអរគុណ។

[០៩:២២:២៩]

**ប្រធានអង្គជំនុំ៖**

អរគុណ នូវការសង្កេតរបស់លោកមេធាវីការពារលោក អៀង សារី ហើយដោយសារបញ្ហានេះ

អង្គជំនុំជម្រះបានជម្រាបជូនពីម្សិលមិញហើយ អំពីបញ្ហាដែលចែងនៅក្នុងវិធាន៨៨ ចំណុច៣ នោះ អំ ចំណុច២។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយអង្គជំនុំជម្រះនឹងប្រឹងប្រែង ដើម្បីសម្រប រៀបចំជាមួយនឹងខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីសម្របសម្រួលបញ្ហានេះឲ្យបានលទ្ធផលល្អតាមខ្លឹមសារនៃបទប្បញ្ញត្តិនៃវិធានដែលអាចធ្វើទៅបាន។ ពីព្រោះវិធាននោះដោយសារ លទ្ធភាពនៃការធំធេងនៃសំណុំរឿងក្ដី ហើយនិងការចូលរួមនៃសាធារណជនយ៉ាងច្រើនសន្ធឹកសន្ធាប់។

[០៩:២៣:១៧]

ដូច្នេះ ដែលលទ្ធភាពក្នុងការគ្រប់គ្រងទាំងស្រុងនោះមិនបានល្អទេ តែប្រសិនបើមានកាលៈទេសៈនៃបញ្ហាដូច្នេះ នៅក្នុងអំឡុងពេលនៃមុនផ្ដល់សក្ខីកម្មនោះ គឺអង្គជំនុំជម្រះនឹងរៀបចំ និងដាស់តឿនដល់ខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញដែលទទួលបន្ទុកកិច្ចការនេះ ដើម្បីឲ្យគាត់រៀបចំដំណើរការក្នុងការគ្រប់គ្រងសាក្សី អ្នកជំនាញ ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងផ្ដល់សក្ខីកម្មឲ្យបានល្អ។

សូមអញ្ជើញ អង្គជំនុំជម្រះមុននឹងផ្ដល់វេទិកាទៅ គឺសូមជម្រាបថា ការសួរ ស្ដាប់សក្ខីកម្មរបស់លោក រម៉ាម យុន ហៅ ខាំភី នេះមានរយៈពេលតែមួយព្រឹកនេះប៉ុណ្ណោះ។

សូមអញ្ជើញ! សហព្រះរាជអាជ្ញាអន្តរជាតិចង់មានបញ្ហាអីទៅ?

[០៩:២៤:២២]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯលៈ**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ជម្រាបជូនដល់អង្គជំនុំជម្រះនិងភាគីទាំងអស់ថា ការិយាល័យសហព្រះរាជអាជ្ញាចង់សួរសាក្សី TCW-395 ទៅលើអង្គហេតុទាំងអស់នៃសំណុំរឿង០០២ គឺមិនមែនត្រឹមតែដំណាក់កាលទីមួយនៃសំណុំរឿង០០២ ទេ។ គឺដោយសារកាលៈទេសៈពិសេស យោងទៅលើស្ថានភាពសុខភាពរបស់គាត់ គឺថាវាមានលក្ខណៈមិនស្ថិតស្ថេរ មិនប្រែប្រួល មិនទៀងទាត់។

ដូច្នេះ សូមឲ្យអង្គជំនុំជម្រះមេត្តាអនុញ្ញាត។ អង្គជំនុំជម្រះបានបញ្ជាក់ថា ស្ថានភាពសុខភាពគាត់នោះ គឺថាមានលក្ខណៈមិនទៀងទាត់ គាត់មិនអាចធ្វើដំណើរបានទេ ហើយស្ថានភាពនេះ គឺថាមានការវិវឌ្ឍន៍ពីមួយថ្ងៃទៅមួយថ្ងៃ។ ដូច្នេះ ដូចដែលយើង ដោយសារថាគាត់អាចមានស្ថានភាពគាត់ អាចធ្វើសក្ខីកម្មបាន គឺសូមមេត្តាឲ្យគាត់ធ្វើសក្ខីកម្មទៅលើអង្គហេតុទាំងមូលនៃសំណុំរឿង០០២ ដែលគាត់បានដឹង ពីព្រោះថាប្រហែលជាពេលក្រោយនោះ គាត់គ្មានលទ្ធភាពក្នុងការផ្ដល់សក្ខីកម្មតទៅទៀតទេ។ ប្រសិនបើអង្គជំនុំជម្រះឯកភាពទៅលើសំណើនេះ ខ្ញុំគិតថានឹងសុំឲ្យមានការកែសម្រួលពេលវេលាខ្លះ

ដើម្បីឲ្យគាត់អាចធ្វើសក្ខីកម្មបាន។

[០៩:២៥:៤៩]

ដូច្នេះ សូមឲ្យគាត់មានពេលវេលាច្រើនបន្តិច ដើម្បីឲ្យអាចត្រៀមសម្រាប់សំណួរ សួរទៅលើសំណុំរឿងទាំងមូល ទៅលើអង្គហេតុទាំងមូលតែម្តងមិនមែនតែត្រឹមដំណាក់កាលទីមួយនេះទេ គឺថា-- គឺអាចមកធ្វើសក្ខីកម្មថ្ងៃនេះក៏បាន ឬក៏ស្អែកក៏បាន អាស្រ័យទៅលើអង្គជំនុំជម្រះ។ ហើយជាទូទៅយើងខ្ញុំយល់ឃើញថា ស្ថានភាពសុខភាពផុយស្រួយរបស់គាត់ទាំងផ្នែកផ្លូវចិត្ត និងផ្លូវកាយនោះ ហើយគាត់មានវិបត្តិស្មារតីផងដែរចំពោះមនុស្សចាស់ គឺអាចបញ្ជាក់ហេតុផលថា ដើមបណ្តឹងរដ្ឋប្បវេណី គឺសាក្សីទាំងអស់នោះ គឺថាមិនត្រឹមតែសាកសួរទៅលើផ្នែកទីមួយទេ គឺសុំឲ្យសួរទៅលើផ្នែកទាំងអស់តែម្តង ដើម្បីថាកុំឲ្យតែថាស្ថានភាពសុខភាពគាត់កាន់តែដុនដាបទៅ ដើម្បីកុំឲ្យ-- ដែលធ្វើឲ្យយើងមិនអាចសួរគាត់បាន។ សូមអរគុណលោកប្រធាន។

[០៩:២៦:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមអនុញ្ញាតលើកឡើង។ អរុណសួស្តីអស់លោក លោកស្រីទាំងអស់គ្នាដែលនៅក្នុងសវនាការនេះ។ ពាក្យសុំនេះ គឺគួរតែធ្វើឡើងជាមុន។ គឺយើងគួរតែលើកឡើងនៅក្នុងកិច្ចប្រជុំរៀបចំសវនាការក្រៅផ្លូវការ។ យើងមិនគួរលើកឡើងបញ្ហានេះនៅក្នុងពេលនេះ នៅចំពោះមុខអង្គជំនុំជម្រះទៀតទេ យើងមិនគួរធ្វើដូច្នេះនោះទេ។ ប្រសិនបើចង់សួរទៅលើសំណុំរឿងទាំងមូលនោះ ភាគីនោះគួរតែបង្ហាញឲ្យបានជាក់លាក់ បង្ហាញហេតុផលឲ្យបានច្បាស់លាស់ ថាតើអង្គហេតុណាមួយដែលខ្លួនចង់សួរទាំងមូលនោះ ដើម្បីឲ្យភាគីផ្សេងអាចឆ្លើយតបបាន។

[០៩:២៧:៥១]

ដូច្នេះ ការធ្វើដូច្នេះ គឺដើម្បីឲ្យវាជាការគោរពទៅដល់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលគាត់មកផ្តល់-- ដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំគិតថា វាហាក់ដូចជាការបំផ្លិចបំផ្លាញ និងគ្រោះថ្នាក់ចំពោះខ្ញុំ នៅពេលដែលមានការលើកឡើងភ្លាមៗដូច្នេះ។ ដូច្នេះខ្ញុំស្នើសុំលោកប្រធាន និងចៅក្រម ឲ្យសហព្រះ

រាជអាជ្ញា និងភាគីផ្សេងទៀត ប្រសិនបើខ្លួនចង់ស្នើសុំសួរអង្គហេតុផ្សេងពីផ្នែកទីមួយនេះ គួរតែពួកគាត់ស្នើសុំឲ្យបានមុន ទុកពេលវេលាឲ្យពួកយើងឲ្យបានត្រឹមត្រូវ។ ការធ្វើដូច្នេះ គឺយើងមិនចំណាយពេលឥតប្រយោជន៍នៅក្នុងតុលាការ។

ដូច្នេះហើយ យើងនៅទីនេះ គួរតែដេញដោលទៅលើបញ្ហាភស្តុតាងមិនមែនមកធ្វើការសម្រេចទៅលើបញ្ហាសំណើ ដែលបានស្នើឡើងនោះឡើយ។

[០៩:២៨:៤៣]

**ប្រធានអង្គជំនុំ៖**

បានហើយ មិនអនុញ្ញាតទៀតទេ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក តើលោកឈ្មោះ រម៉ាម យុន អ៊ីចឹងពិតមែនដែរទេ?

**លោក រម៉ាម យុន៖**

**ឆ៖** បាទ។ ខ្ញុំ រម៉ាម យុន។

**ស៖** ចុះ តើលោកមានឈ្មោះហៅក្រៅថា ខាំភី ពិតមែនដែរទេ?

**ឆ៖** មែន។ ឈ្មោះពីរ ខាំភី រម៉ាម យុន អ៊ីចឹង។

[០៩:២៩:៤៤]

**ស៖** លោក រម៉ាម យុន តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ម្តងទៀតអ៊ំ!

**ឆ៖** ៧០។

**ស៖** អាយុ ៧០ឆ្នាំ។ តើលោកកើតនៅទីកន្លែងណា?

[០៩:៣០:០៧]

**ឆ៖** កើតនៅភូមិកាចូត។

**ស៖** នៅឃុំ ស្រុក ខេត្តណា?

**ឆ៖** ខេត្តរតនគិរី។

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ម្ដងទៀតអ៊ំ ម្ដងទៀត។

**ឆ៖** ស្រុកអណ្ដូងមាស ខេត្តរតនគិរី។

**ស៖** លោក រម៉ាម យុន តើសព្វថ្ងៃនេះលោករស់នៅទីកន្លែងណាដែរ?

**ឆ៖** នៅកន្លែងដដែលហ្នឹង។

[០៩:៣០:៣៦]

**ស៖** លោករកស៊ីធ្វើអ្វីទៅសព្វថ្ងៃ?

**ឆ៖** ធ្វើស្រែចម្ការហ្នឹងហើយ អត់ធ្វើអីទេ។

**ស៖** លោក រម៉ាម យុន តើមានប្រពន្ធដែរទេ?

**ឆ៖** បាទ, មាន។

**ស៖** លោកមានកូនប៉ុន្មាននាក់?

**ឆ៖** កូនបួន ប្រុសទាំងអស់។

**ប្រធានអង្គជំនុំ៖**

ដោយអនុវត្តទៅតាមវិធាន៩១ ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក និងដីកាចាត់តាំងភារកិច្ចឲ្យសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១១ របស់អង្គជំនុំជម្រះ ។ផ្ដល់វេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីចាប់ផ្ដើមនូវការសួរដេញដោលដល់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ រម៉ាម យុន នេះ មុនភាគីឯទៀត។

សូមអញ្ជើញ!

[០៩:៣១:៥១]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម! មេធាវីនាំមុខសូមអនុញ្ញាតលោកប្រធានផ្ទេរសិទ្ធិនៅក្នុងការសួរសំណួរទៅលើដើមបណ្ដឹងរដ្ឋប្បវេណី 123 នេះ ជូនទៅមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក គឺលោក ម៉េង ឃី និងជាយថាហេតុ ជូនលោកស្រី គ្រីស្ទីន ម៉ាទីណូ។ សូមលោកប្រធានអនុញ្ញាត។

[០៩:៣២:២១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ ប៉ុន្តែអង្គជំនុំជម្រះសូមជម្រាបថា ដោយសារកំណត់ពេលវេលានៃការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះតែមួយព្រឹកទេ។ ឥឡូវនេះអង្គជំនុំជម្រះកំណត់ឲ្យទៅមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនូវរយៈពេលនៃការសួរនេះ ៤៥ នាទី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយ លោក គឹម ម៉េងឃី៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូលជាទីគោរព។

ជាបឋមមុននឹងខ្ញុំចាប់ផ្តើមសំណួរ ខ្ញុំសូមអនុញ្ញាតជម្រាបជូនឡើងវិញ អំពីសារណារបស់ក្រុមយើងខ្ញុំដែលបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងដើមបណ្តឹងលោក រម៉ាម យុន ហៅខាំភី នេះ អំពីបញ្ហាដែលគាត់មានផលលំបាកផ្នែកការចងចាំ ហើយគាត់មិនអាចចងចាំនូវអ្វីដែលយើងសួរបានច្រើនទេ ដោយសារមូលហេតុទីមួយ គឺគាត់មិនចេះភាសាខ្មែរច្បាស់លាស់។ បញ្ហាទីពីរ គឺវ័យចំណាស់ ហើយនិងបញ្ហាទីបី គឺសុខភាពរបស់គាត់ផ្ទាល់។

[០៩:៣៣:៣៧]

ដូច្នេះ ក្នុងនាមជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះសាលាដំបូងនឹងកំណត់ឲ្យគ្រប់ភាគីទាំងអស់ ដែលសួរទៅកាន់គាត់ ក៏ដូចយើងខ្ញុំផងដែរ សួរនូវសំណួរដែលសាមញ្ញបំផុត ងាយយល់ ហើយអន្តរាគមន៍ភ្លាមៗ ចំពោះការរំខាន ដែលធ្វើឲ្យប៉ះពាល់ដល់ការធ្វើសក្ខីកម្មរបស់គាត់។ បាទ សូមអរគុណ។

ហើយដូច្នេះ ជាដំបូង ខ្ញុំសូមចាប់ផ្តើមនឹងសំណួរទៅកាន់លោកអ៊ុំ រម៉ាម យុន។

**ស៖** លោកអ៊ុំ រម៉ាម យុន តើលោកអ៊ុំអាចរៀបរាប់បានទេ នៅក្នុងសម័យមុនរបបខ្មែរក្រហម ១៩៧៥ លោកអ៊ុំធ្វើអ្វីខ្លះ? ហើយនៅកន្លែងណាខ្លះ? សូមលោកអ៊ុំមេត្តារៀបរាប់។

[០៩:៣៤:៣៤]

**លោក រម៉ាម យុន៖**

**ឆ៖** បាទ, ប៉ុន្តែ កាលជំនាន់ខ្មែរក្រហម។ ប៉ុន្តែច្រើនដែរ វាច្រើនតែភ្លេចភ្លាំងបន្តិចណ៎ា វាចាំមិនគ្រប់សព្វហ្នឹងណ៎ា។ កន្លែងណាដែលនឹកឃើញ វាឃើញទៅណ៎ា។ កន្លែងណាដែលមិននឹក វាហើយ

វាអ៊ីចឹង។ វាក្រឡិចក្រឡុចហើយណាស់ ភ្លេចមុខភ្លេចក្រោយ កាលនៅជាមួយខ្មែរក្រហម។ រឿងនេះ បើយើងនឹកឃើញថា ដូចថាវាល្អ ក៏មិនល្អ ត្រូវក៏មិនត្រូវ អ៊ីចឹង។ ហើយរឿងនេះ តាមយល់តាមឃើញ ប៉ុន្តែមាគ៌ា ដឹកនាំមាគ៌ាចាត់ចែងនេះវា វាខុស ឃើញថាខុស យើងពីដើមឃើញដែរខុស យើងមិនប៊ាន តវ៉ា។ យើងមិនប៊ានត្អូញត្អែរ ពីព្រោះគេខាងលើ យើងខាងក្រោយហ្នឹងណាស់ អ៊ីចឹង។ អានេះ រឿងនេះ ខ្ញុំឃើញច្បាស់អ៊ីចឹង។

ទីពីរ ការងារអនុវត្តជាក់ស្ដែងទៀត ឃើញវាអនុវត្តនោះវាហួសហេតុពីច្បាប់សង្គមជាតិ សិទ្ធិមនុស្សដែរអ៊ីចឹង។ ទីមួយ នែ៎ រឿងអាប្រើប្រាស់កម្លាំងសហគមន៍ទាំងអស់ អ៊ីចឹងខ្លាំង ប្រើប្រាស់មិនដឹងអាកម្លាំងគេធំ កម្លាំងគេតិច វាអត់ដឹងទេ យកទាំងអស់ហ្នឹង ក្មេងចាស់ ធំ ស្រី មានកូនមានចៅ បើថាមិនចុះពលកម្មខ្លួនឯង ធ្វើខ្លួនឯង យើងអត់មានរបបហូប អ៊ីចឹង។ អានេះ ខ្ញុំឃើញវាមាគ៌ាវាដឹកនាំនេះវាដូចជាហួសហេតុ ប៉ុន្តែដឹកនាំឲ្យត្រូវហើយ ថាកុំឲ្យវាខ្វះវាខាតការស៊ីចុកបុកទំពាចិញ្ចឹមកម្លាំងកូនចៅទាំងអស់ វាអត់មានពេលវេលា វាអត់ចិត្តអីៗ ថាធ្វើហត់ពេក សម្រាក អានេះវាអត់ អត់មានទេ។ ឈឺគ្រុនក៏ទៅ អត់បាយហូបក៏ទៅ អ៊ីចឹងហើយនេះទីមួយ។

[០៩:៣៧:២៩]

ទីពីរ រឿងគោលជំហរអ្នកនយោបាយ ពាក្យសម្ដី ពីព្រោះថាឃោសនា ដឹកនាំ ដូចវាខ្លាំង។ ព្រួយបារម្ភណាស់ មិនថាក្មេង មិនថាចាស់ មិនថាទុំ មិនថាស្រី វាអត់សមរម្យ។ មួយ-- ពេលទៀត រឿងការខុស ការត្រូវ អត់គិត អត់នឹកទេ ថាដូចធ្វើដូចឆ្កែ វ៉ៃដូចឆ្កែអ៊ីចឹង ដូចរឿងចង់កាប់មាន់ ចង់ថ្ងៃណា ក៏កាប់ថ្ងៃហ្នឹង អ៊ីចឹង។ បើជ្រូកយើងចង់លក់ ក៏លក់ថ្ងៃហ្នឹងដែរ បើថា អ្ហ៎! ទុកសិនទៅ អត់មានទេ អ៊ីចឹង អាហ្នឹងទីពីរនេះ ខ្ញុំឃើញអ៊ីចឹង។

ទីបីទៀត គឺថា អត់មានគោលជំហរថានឹងនរ ការពារអាយុជីវិតសិទ្ធិមនុស្ស អត់ស្ដាយទេ អត់អាណិតទេ អ៊ីចឹងរឿងនេះ ធ្វើយ៉ាងម៉េចក៏ធ្វើតាមចិត្តខ្លួនឯងធ្វើ អ៊ីចឹង។ អានេះ ខ្ញុំឃើញថាវាៗធ្វើវាខ្លាំង។

បួនទៀត រឿងខុសរឿងត្រូវនេះ យើងមានដែរ ពីដើមមានម៉ែមានឪដែរ។ មានម៉ែមានឪខុសត្រូវតូចធំ ទៅដោះស្រាយគោលជំហរអ្នកនយោបាយសតិអារម្មណ៍ឲ្យវាយល់ វាឲ្យដឹង ប៉ុន្តែយើងចង់ឲ្យវាលើសមែនទែន វាឲ្យដាក់គុក ប៉ុន្មានខែក៏ដាក់ចុះ អ៊ីចឹង។ អានេះ អត់ទេ អត់ដាក់គុកអីទេ(ឮមិនច្បាស់)។ អ៊ីចឹងអាហ្នឹងតាមគំនិតខ្ញុំ ខ្ញុំឃើញ។ អ៊ីចឹងហើយខ្ញុំឃើញថា អត់ចិញ្ចឹមមនុស្ស អត់ថែទាំមនុស្ស អ៊ីចឹង

មនុស្សដែលមនុស្សអាក្រក់ មនុស្សល្អ មនុស្សធំ មនុស្សតូចអីអត់ទេ។ អត់រើសអើងទេ អ៊ីចឹង។ ហ្នឹង ខ្ញុំមើលឃើញត្រង់ហ្នឹង។

[០៩:៤០:៣៦]

**ប្រធានអង្គជំនុំ៖**

អ៊ីចេះអ៊ំ! អ៊ំចាំស្ដាប់សំណួរសាជាថ្មី ឬក៏សួរបន្ថែមទៀតពីភាគី ពីមេធាវី ហើយមេធាវីអំមិញខ្លួនឯងបាននិយាយច្បាស់លាស់ ដោយសារបញ្ហាអារម្មណ៍ បញ្ហាការយល់ដឹងរបស់គាត់មានកម្រិតគប្បីសួរខ្លី ប៉ុន្តែសំណួរលោកសួរខ្លី ប៉ុន្តែឲ្យគាត់រៀបរាប់។ ពាក្យថា រៀបរាប់នេះ គឺវាជាសំណួរវែងហើយ។ ដូច្នេះគួរតែអង្គន់នូវសំណួរដែលលោកចង់សួរ ដើម្បីឲ្យចំបញ្ហា ហើយគាត់មានលទ្ធភាពអាចឆ្លើយបាន។

សូមអញ្ជើញបន្តសំណួរទៀត។

**សួរដោយលោក គឹម ម៉េងឃី៖**

សូមអរគុណលោកប្រធាន។

**ស៖** លោកអ៊ំពាក់ព័ន្ធទៅនឹងសំណួរអំមិញនេះ គឺលោកអ៊ំបានឆ្លើយអ្វីដែលខ្ញុំសួរហ្នឹងចង់ដឹងថា តើនៅមុនឆ្នាំ១៩៧៥ អ៊ំធ្វើអី? នៅទីណា?

**ឆ៖** បាទ, ខ្ញុំអង្កាល់នុ៎ងភារកិច្ចខ្ញុំធ្វើមុនដំបូង ដែលខ្ញុំធ្វើថ្នាក់មុនដំបូងធ្វើនីរសារ ជំនាន់ ពត។ ធ្វើនីរសារជូនសំបុត្រ ជូនមនុស្សកម្មាភិបាលធំ-តូច គេហ្នឹងជូនទៅ។ យូរៗ ខ្ញុំធ្វើគណៈកម្មការភូមិ។ ធ្វើគណៈកម្មការភូមិចាត់ចែងយ៉ាងនេះ យ៉ាងនោះ ខ្ញុំធ្វើតាមផែនការវាដាក់ឲ្យហ្នឹង ធ្វើចម្ការធ្វើសាមគ្គីក្នុងភូមិ ក្នុងស្រុកនុ៎ងអ៊ីចឹង។

[០៩:៤២:៤៩]

ហើយនៅៗភូមិនោះ គេថាអ្ហែ អានេះវាភូមិ វាគ្រប់គ្រាន់ហើយ ទៅនៅជាមួយគេនៅឃុំចុះ។ ទៅនៅជាមួយឃុំ ប៉ុន្តែតែថា នៅឃុំនុ៎ងពីរឆ្នាំ។ ទេ អាហ្នឹងដូចអ៊ីចេះវាផ្លាស់មនុស្សហើយ ចូលដល់ត្រឹមស្រុកចុះ អ៊ីចឹង ដូចអណ្ដែតទៅៗអ៊ីចឹង។ យើងធ្វើអនុគេ មកគេចាត់ចែងយ៉ាងម៉េចៗចេះតែធ្វើតាមគេ អាសំបុត្រគេ ពាក្យគេ ផែនការគេ ធ្វើតាមហ្នឹង ធ្វើហើយមានការគេខុស ការគេត្រូវក្នុងភូមិឃុំនុ៎ង ឃើញថាមានផែនការថា-- ដល់វាចេញមកថាបោសសម្អាតទៅ បោសឲ្យវាស្អាតទៅ។ បោសយ៉ាងម៉េច? បើមានស្មៅអីចេះបោសម៉េចមនុស្ស មនុស្សចេះបោស? ទេ អាវាមិនល្អបោសចោលអាណាវាល្អទុក អ៊ីចឹងទៀត អារឿងនេះ។ ខ្ញុំញ៉ូវខ្លួនហើយ ខ្ញុំមិនដែលឃើញ ដល់យូរៗទៅខ្ញុំស្រៀវខ្លួន

ឯងធ្វើអ៊ីចេះវាអត់កើតទេ។ គាត់ហៅមកយ៉ាងម៉េច? ហៅមកប្រជុំអត់ឃើញ អី មិនស្រួលខ្លួន ថ្ងៃណាហៅ ក៏ខ្ញុំថាអត់ស្រួលខ្លួនទេ។

[០៩:៤៥:១៥]

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

មេធាវីគាត់សួរថា ធ្វើហ្នឹងធ្វើនៅណាអ៊ំ ធ្វើនៅឃុំណា នៅស្រុកណា? នៅខេត្តណាអង្កាល់ហ្នឹង?

**ឆ៖** បាទ, ឃុំខ្លួនឯងហ្នឹង ឃុំ-- ធ្វើនៅស្រុកអណ្តូងមាសហ្នឹងហើយ។ ភូមិធ្វើនៅភូមិកាចូតខ្លួនឯងហ្នឹងហើយ ធ្វើនៅភូមិញ៉ាង ខ្លួនឯងនៅហ្នឹងហើយ អ៊ីចឹង។ អត់ធ្វើទៅណា ទៅណាទេ អ៊ីចឹង។

**ស៖** សូមអរគុណលោកអ៊ំ។ ខ្ញុំបន្តសំណួរអ៊ំមិញ លោកអ៊ំថាតួនាទីអ៊ំមានធ្វើខាងនីរសារអ៊ំអាចបញ្ជាក់បានទេ នីរសារហ្នឹង នីរសារឲ្យអ្នកណាគេ?

**ឆ៖** នីរសារយ៉ាងម៉េចហ្នឹង?

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

នីរសារ អ្នករត់សំបុត្រ រត់សំបុត្រឲ្យអ្នកណា?

**ឆ៖** ឲ្យតាមភូមិគេ កម្មាភិបាលតាមភូមិ ឃុំគេណា។

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

មេអ៊ំហ្នឹង មេធំអ្នកណាគេ?

**ឆ៖** មេធំគេហ្នឹង ខ្ញុំឲ្យឈ្មោះ ឲ្យតាជូ តាមមកភូមិគេធំៗ ឃុំគេហ្នឹងណាអ៊ីចឹងមួយ។ ពីរទៀតពួកខ្ញុំនៅព្រំដែនវៀតណាម ជួនកាលគេបញ្ជូនទៅវៀតណាម មានអ៊ីចឹង។ សំបុត្រហ្នឹងមិនដឹងគេឲ្យទៅណាមកណាទេ យើងចេះតែកាន់ជូនឲ្យគេហ្នឹង។

**ស៖** លោកអ៊ំអាចបញ្ជាក់បានទេ តើសំបុត្រហ្នឹងចេញដោយអ្នកណាគេ? ហើយទិសដៅសំបុត្រហ្នឹងទៅណាវិញ?

[០៩:៤៧:០៤]

**ឆ៖** បាទ! សំបុត្រជូនហ្នឹង ជូននៅតាមឃុំ ជូនឲ្យតាមភូមិអ៊ីចឹង។

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

យកសំបុត្រពីអ្នកណា យកពីអ្នកណា យកទៅឲ្យអ្នកណា សំបុត្រហ្នឹង?

**ឆ៖** ទៅដល់ វ៉ាន់ នៅខាងពួកខ្ញុំហ្នឹង។ គាត់គណៈភូមិភាគ គាត់ធ្វើគណៈភូមិភាគកាលហ្នឹង វ៉ាន់ៗហ្នឹង។

**ស៖** លោកអ៊ំបញ្ជាក់បានទេ តើ វ៉ាន់ ហ្នឹងគណៈភូមិភាគអីគេដែរ? គេហៅគណៈភូមិភាគអីនៅពេលហ្នឹងអ៊ំ?

**ឆ៖** ភូមិភាគនៅ ភូមភាគពាយ័ព្យ ហ្នឹង។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ភូមិភាគពាយ័ព្យ អ៊ំ?

**ឆ៖** ហ្នឹងហើយ។

[០៩:៤៨:០៨]

**ស៖** ហើយលោកអ៊ំបានដឹងថា តើនៅក្នុងសំបុត្រហ្នឹងគេមាននិយាយពីអីដែរឬទេ?

**ឆ៖** អាហ្នឹងអត់ដឹងទេ យើងមិនចេះបកគេមានស្រោម មានអីហ្នឹង យើងទៅចេះបកយ៉ាងម៉េចរឿងគេ។ ប្រាប់ជូន គឺជូន។

**ស៖** លោកអ៊ំអាចបញ្ជាក់បានទេថា មូលហេតុអីបានដឹងថាសំបុត្រហ្នឹងចេញពីឈ្មោះវ៉ាន់ គណៈភូមិភាគពាយ័ព្យ?

**ឆ៖** អ៊ូ! អាហ្នឹងវាឲ្យតាមឃុំនោះណា តាមស្រុកនោះណា សំបុត្រហ្នឹងឯង ស្រុកណេះទៅផ្លូវណេះ ឃុំណេះវាទៅផ្លូវណេះអ៊ីចឹង។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ម៉េចបានដឹងអ៊ំ ម៉េចបានដឹងសំបុត្រហ្នឹងៗរបស់អ៊ំវ៉ាន់ហ្នឹង ម៉េចបានដឹង?

**ឆ៖** មិនដែលឃើញម៉េច វានៅជិតអាពួកព្រៃហ្នឹងហើយ ធ្វើផ្ទះគាត់ក្បែរហ្នឹងតែម្តង បើពេលទៅធ្វើការអី នីរសារគាត់ហ្នឹងមកជូនតាមផ្លូវណេះៗ ផ្លូវអីទៅអ៊ីចឹងណា មិនមែនយើងទៅនៅជាមួយវាឯណា។

**ស៖** ចុះលោកអ៊ំចាំឈ្មោះនីរសាររបស់ វ៉ាន់ ដែលបញ្ជូនសំបុត្រទៅឲ្យអ៊ំដែរឬទេ? ឈ្មោះគាត់អីគេ?

**ឆ៖** អ្នកណាទៅចាំ ខ្ញុំអត់ចាំដែរ ចាំមានតែទទួលសំបុត្រ តែអ្នកហុចឲ្យហ្នឹងយកតែម្តងយកទៅបញ្ជូនឲ្យគេទៅ អ៊ីចឹង។

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

អត់ស្គាល់ឈ្មោះទេអ៊ំ?

**ឆ៖** អត់ស្គាល់ទេ វានៅមន្ទីរវាឆ្ងាយណាស់ អ៊ីចឹង។

**ស៖** លោកអ៊ំអាចបញ្ជាក់ឡើងវិញថាតើ វ៉ាន់ ហ្នឹងគាត់មានឈ្មោះអីផ្សេង ដើម្បីសម្គាល់គាត់ក្រៅពីឈ្មោះ វ៉ាន់ ដែលលោកអ៊ំស្គាល់ហ្នឹងទេ?

**ឆ៖** កាលនោះអត់ស្គាល់ទេគ្រាន់តែឮឥឡូវនេះទេ ឈ្មោះគាត់ វ៉ាន់ ហ្នឹងណ៎ា។ អត់ស្គាល់ទេ។

**ស៖** សូមអរគុណលោកអ៊ំ។ ខ្ញុំបន្តសំណួរបន្តទៀតទាក់ទងនឹងការងាររបស់លោកអ៊ំនៅក្នុងភូមិ។ ពេលដែលអ៊ំនិយាយថា គេឲ្យអ៊ំធ្វើភូមិមានន័យថាម៉េច? មានន័យថា គេតែងតាំងអ៊ំ ឬក៏មានន័យថាអ៊ំជាមេភូមិស្រាប់?

**ឆ៖** អាហ្នឹងភូមិកើតមុនបាទ។ មេភូមិកើតមុន។ ខ្ញុំអានេះ ពូវន គាត់ប្រធានភូមិ។ ខ្ញុំនៅតែកណ្ដាលភូមិទេណ៎ាអ៊ីចឹង។

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ចង់និយាយថា គេចាត់តាំងធ្វើមេភូមិ ឬក៏អ៊ំជាមេភូមិស្រាប់កាលនោះ?

**ឆ៖** អត់ទេ។ មេភូមិស្រាប់នេះណ៎ា។ មេភូមិនេះ មេភូមិគេហៅប្រជុំអី។ ខ្ញុំអត់មានការប្រជុំទេ នៅតែបញ្ជានៅភូមិនោះ អ៊ីចឹង។

**ស៖** ក្នុងតួនាទីអ៊ំជាមេភូមិហ្នឹងអ្នកណាជាមេធំរបស់អ៊ំ លើអ៊ំទៀត?

[០៩:៥២:១៣]

**ឆ៖** ប្រធានភូមិអង្គការចាត់តាំងហ្នឹងហើយមេគេហ្នឹង។ ខ្ញុំមេក្នុងភូមិទេអ៊ីចឹង ការងារអីគាត់មកសួរខ្ញុំដែរ អ៊ីចឹង។ ការងារអីគាត់ជូនឲ្យដំណឹងមកខ្ញុំដែរ ខ្ញុំក៏ជូនឲ្យដំណឹងសហគមន៍ក្នុងភូមិ។ មានតែប៉ុណ្ណឹង។

**ស៖** តើអង្គការចាត់តាំងដែលលោកអ៊ំនិយាយហ្នឹងអ្នកណាគេអ៊ំ?

**ឆ៖** អង្គការហ្នឹងចេញមកពីអង្គការគណៈកម្មាធិការភូមិហ្នឹងហើយ អង្គការគេចាត់តាំងហ្នឹងហើយប្រគល់ឲ្យខ្ញុំ។

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

អ្នកណាគេខ្លះអ៊ំ? អង្គការគេហ្នឹងមានប៉ុន្មាននាក់? ឈ្មោះស្គាល់ឈ្មោះទេ?

**ធ៖** គណៈកម្មាធិការគេនោះ វន នេះ អាខ្មោច អាយន នេះពីរនាក់។ ខ្ញុំនៅគ្រប់គ្រងក្នុងភូមិដដែល អ៊ីចឹង។

**ស៖** គ្រប់គ្រងភូមិហ្នឹងធ្វើអីខ្លះអ៊ំ?

[០៩:៥៣:៤៣]

**ធ៖** ការងារកាលនោះមានអីធ្វើការងារអីនោះ ធ្វើស្រែធ្វើចម្ការនេះណា។ ការខុស ការត្រូវ អ៊ីចឹងយើងដោះស្រាយឲ្យណ៎ា។ មានតែប៉ុណ្ណឹងក្នុងភូមិ។

**ស៖** តើអង្គការគេចាត់តាំងឲ្យភូមិធ្វើការងារស្រែចម្ការហ្នឹងយ៉ាងម៉េចទៅ?

**ធ៖** ការហ្នឹងអង្គការគេចាត់តាំងហ្នឹង គេចាត់តាំងឲ្យសាមគ្គីគ្នា ពេលនេះយើងធ្វើស្រែយើងធ្វើចម្ការពេលយើងបូតស្រូវពេលយើងជម្រះស្មៅនេះណ៎ាឲ្យសាមគ្គីគ្នា។ មានប៉ុណ្ណឹងក្នុងភូមិហ្នឹង។

**ស៖** តើពីមុនមកអ្នកដែលនៅក្នុងភូមិហ្នឹងអត់ដែលមានសាមគ្គីគ្នាទេ បានអង្គការចាត់តាំងបែបដូច្នេះលោកអ៊ំ? សូមបញ្ជាក់។

**ធ៖** ពីដើមអត់មានទេ។ មានដែរ តែវាអត់ញឹកញយនោះណ៎ា។ ដល់អង្គការចាត់តាំងទៀតវាដូចវាឯកភាពគ្នា។ អ៊ីចឹងធ្វើការងារនៅក្នុងភូមិមានការខុស មានការត្រូវវាដោះស្រាយអត់ស្មើភាពគ្នាអ៊ីចឹង។

[០៩:៥៥:១០]

**ស៖** អ៊ំបញ្ជាក់បានទេ ការងារសាមគ្គីហ្នឹងធ្វើយ៉ាងម៉េច?

**ធ៖** សាមគ្គីដូចថា យើងធ្វើស្រែធ្វើចម្ការ អាណាវានៅមិនទាន់ហើយយើងទៅជួយណ៎ា អ៊ីចឹង។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

មិនទាន់ហើយជួយ។

**ធ៖** ជួយតែគ្នាទៅវិញទៅមក។ សាមគ្គីរឿងបាយទឹកវាអត់ឃ្លាន វាជួយគ្នាទៅវិញទៅមក អ៊ីចឹង។ បើមានរឿងរ៉ាវអី យើងទាំងអស់គ្នាទៅជួយដោះស្រាយឲ្យអ៊ីចឹង។ ពេលធ្វើចម្ការវាហួសរដូវហួសពេលហើយ យើងទៅជួយឲ្យ អ៊ីចឹង មានប៉ុណ្ណឹង។

[០៩:៥៦:០២]

**ស៖** សូមអរគុណលោកអ៊ំ។ លោកអ៊ំអាចបញ្ជាក់បានទេថា ក្រោយពីលោកអ៊ំក្លាយជាប្រធានភូមិធ្វើការបាននៅមុនឆ្នាំ១៩៧៥ហ្នឹង ក្រោយមកទៀតគេឲ្យអ៊ំធ្វើអីទៀត? ហើយអ្នកណាអ្នកតែងតាំងអ៊ំ?

**ធ៖** បាទ, មានអ្នកណា បណ្ដាញសហគមន៍នៅភូមិហ្នឹងហើយ ចេះតែរើស ធ្វើគណៈកម្មការភូមិអ៊ីចឹង។

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ចង់និយាយថា ភូមិហើយគេមិន-- អ៊ំឡើងទៅជាឃុំ ទៅធ្វើនៅឃុំ អ្នកណាចាត់តាំងអ៊ំ?

**ធ៖** បាទ, អាហ្នឹង-- អាហ្នឹងហើយមានគណៈធំៗគេហ្នឹងហើយ ព្រោះវាចាត់តាំង ភារកិច្ចចាត់តាំងពេលតាំងពីភូមិដល់ឃុំណ៎ា អ៊ីចឹង។

[០៩:៥៧:០៨]

**ស៖** សូមអ៊ំបញ្ជាក់គណៈធំៗ ដែលអ៊ំនិយាយអំមិញហ្នឹង មានឈ្មោះអ្នកណាគេខ្លះ?

**ធ៖** គណៈឃុំ មានអា-- កាលនុ៎ង ពូ ហួន។

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ហួន?

**ស៖** ហួន។

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ហួន។

[០៩:៥៧:២៦]

**ធ៖** គាត់ស្លាប់ហើយ គាត់ធ្វើ ហើយគាត់ស្លាប់គេយកថ្មីទៀត យកថ្មី។ ដល់ថ្មីនេះវាដល់ឥឡូវវាតទៀត ថ្មីទៀតអ៊ីចឹង។

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

គាត់សួរថា គេចាត់តាំងអ៊ំឲ្យធ្វើមេឃុំ អ្នកណាអ្នកចាត់តាំងអ៊ំ? អ៊ំថាគណៈៗ គណៈធំៗគេហ្នឹង គណៈធំៗហ្នឹងអ្នកណាគេខ្លះ? ឈ្មោះអីខ្លះចាំទេ?

**ធ៖** ឃុំហ្នឹងវា កាលនុ៎ងពួក-- រាជការយើងហ្នឹងចាត់តាំងឃុំ។ ដល់ហើយឃុំនេះវាអត់មានមនុស្សអ៊ីចឹងៗ ធ្វើឃុំផង គ្រប់គ្រងភូមិផងអ៊ីចឹង។

[០៩:៥៨:៤៩]

**ស៖** លោកអ៊ំ តើលោកអាចពន្យល់បានទេ ដែលលោកអ៊ំនិយាយអំពីភូមិភាគព្លសានហ្នឹង រចនាសម្ព័ន្ធភូមិភាគព្លសានមានអ្នកណាគេខ្លះ អ៊ំដឹងទេ?

**ធ៖** គណៈភូមិភាគពួសាន កាលនុំង វាគណៈភូមិភាគថ្មីៗយើងណា ពេលដើមយើងអត់ថាទេណា។ ចាប់ពី--

**ស៖** សូមលោកអ៊ំរៀបរាប់ពីដើមរហូតដល់ថ្មីៗ ដែលលោកអ៊ំដឹង ទាំងអស់ដែលលោកអ៊ំដឹង។

**ធ៖** មាន អាចង មួយ គណៈភូមិភាគអី អាថ្នាក់ខេត្តយើងនេះណា ឧបមាណា ថ្នាក់ខេត្តពីដើមគេហៅអីម៉េច?

[០៩:៥៩:៥០]

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ប៉ុន្តែ អង្កាល់ៗអ៊ំធ្វើជាឃុំជាអីហ្នឹង លើភូមិភាគ--។

**ធ៖** ហ្នឹងហើយ។

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ភូមិភាគអង្កាល់សម័យនុំងឈ្មោះអីខ្លះអ៊ំ?

**ធ៖** ហើយអានេះហើយ រកអាថ្មីទៀត អាគេចាត់តាំងថ្មីទៀតហ្នឹងណា។ អានេះចាស់ ដូចថាៗមេឃុំ ចៅហ្វាយស្រុក អ៊ីចឹងណា។ ដល់ហើយពួកនេះហើយ អាហ្នឹងវាឡើងមកទទេ។ គណៈឃុំនេះទៀត គេថាបដិវត្តន៍គេអ៊ីចឹង មានពីរជំនាន់។ កាលណា គេថាបដិវត្តន៍ៗមានគណៈកម្មាធិការភូមិ មានឃុំដែរ មានស្រុកដែរអ៊ីចឹង។ នុំងវាមួយ អាចគណៈកម្មាធិការចាស់យើងពីដើម ពីរវាឡើងមកថ្មីនេះ។

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ចាស់ឈ្មោះអីខ្លះ ថ្មីឈ្មោះអីខ្លះទៅ គណៈភូមិភាគ?

**ធ៖** ហ្នឹងហើយគណៈចាស់ភូមិភាគ។

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ឈ្មោះមនុស្ស មាននៅក្នុងគណៈភូមិភាគហ្នឹងណា? អាចចាស់ហ្នឹងមានឈ្មោះអីខ្លះ? អាថ្មីៗគេចាត់តាំងថ្មីឈ្មោះអីខ្លះ?

**ធ៖** អ៎! ខ្ញុំឃើញមួយជំនាន់ ខ្ញុំឃើញតែខ្ញុំទេណា អាមុនហ្នឹង ម៉េចទៅដឹងរឿងរបស់គេ។ យើងនៅថ្មីថ្មោង កាលនុំង។

**ស៖** អរគុណលោកអ៊ំ។ ខ្ញុំសូមកាត់លោកអ៊ំ ហើយនៅក្នុងពេលតស៊ូបដិវត្តន៍ហ្នឹង តើលោកអ៊ំមាននៅចាំបានថា គេហៅអ៊ំទៅប្រជុំប៉ុន្មានដងដែរឬទេ?

**ធ៖** ដល់ពេលយើងធ្វើបដិវត្តន៍ហ្នឹង? អ៊ូ! ញឹកញយណាស់រឿងប្រជុំគេហៅអ៊ីចឹង។ អាហ្នឹងគេហៅយើងទៅប្រជុំ មានផែនការគេចាត់ចែងឲ្យធ្វើ អ៊ីចឹង ដឹកនាំធ្វើអ្វីៗមាន។

[១០:០២:១៨]

**សៈ** លោកអ៊ំ! សុំលោកអ៊ំនិយាយពីរឿងប្រជុំដែលលោកអ៊ំចាំ តើអ្នកណាគេហៅលោកអ៊ំទៅប្រជុំ? ហើយគេធ្វើអ្វីគេខ្លះ?

**ធ៖** ដល់បដិវត្តន៍នេះណ៎ា យើងធ្វើ-- គេធ្វើបដិវត្តន៍ថ្មីណ៎ា។ កាលនោះ មានគណៈភូមិភាគគេតើ។ គណៈភូមិភាគឈ្មោះ វ៉ាន់ គាត់ធំហ្នឹងណ៎ា វាកាត់បារាំងដែរ។ គាត់មាឌធំ គេហៅ វ៉ាន់ៗ ប៉ុន្តែខ្មែរដែរ ប៉ុន្តែមាឌវាមាឌបារាំង។ អាណោះដឹកនាំ។ កាលណាហ្នឹង វ៉ាន់ ដឹកនាំនៅក្នុង--

**សៈ** លោកអ៊ំដឹកនាំប្រជុំនិយាយអំពីអីជាមួយ វ៉ាន់ ដែលលោកអ៊ំនិយាយអំមិញហ្នឹង?

**ធ៖** ដឹកនាំរឿងការសាមគ្គីគ្នា ហើយរឿងធ្វើការងារ។ ធ្វើស្រែ ធ្វើចម្ការ រឿងសាមគ្គី ការខុស ការត្រូវ អ៊ីចឹង។

**សៈ** ចុះបន្ទាប់មកទៀត អ៊ំមានប្រជុំអីទៀតទេ អ៊ំមានចាំបានទេ?

**ធ៖** ហៅទៅហើយ គេ-- បើវាហៅ យើងទៅប្រជុំជាមួយគេ--។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

គេមាននិយាយអីទៀតទេប្រជុំអ៊ំ ក្រៅពីសាមគ្គី សាមអីហ្នឹង?

**ធ៖** អាក្រៅពីនោះ វាហៅយើងទៅនុ៎ង វាមានផែនការៗចាត់ចែងក្នុងភូមិហ្នឹងណា ក្នុងភូមិក្នុងក្រុម ការងារអីធ្វើ ធ្វើចម្ការ ឬរឿងវ៉ាវដាំដុះ រឿងសាមគ្គីគ្នា។ ការឈឺថ្កាត់ អ៊ីចឹង។ មួយទៀតដែរ អារឿងការខុស ការត្រូវ ដោះស្រាយច្បាប់អ៊ីចឹង។ អាហ្នឹងហើយផែនការ។

[១០:០៥:០០]

**សៈ** លោកអ៊ំតាំងខាងដើមដែលខ្ញុំសួរលោកអ៊ំមក លោកអ៊ំថាមានគេហៅប្រជុំ ឥឡូវអ៊ំបញ្ជាក់ឡើងវិញពីការប្រជុំនិយាយពីផែនការ ហើយអ៊ំបានមានប្រសាសន៍អំពីផែនការបោសឲ្យស្អាត។ សំដៅលើអីដែរអ៊ំ បោសឲ្យស្អាតហ្នឹង? បោសសំរាម ឬក៏បោសអីផ្សេង?

**ធ៖** បោសឲ្យស្អាតហ្នឹងនៅក្នុងភូមិយើងហ្នឹងណា យើងថែទាំឲ្យម៉ែវាណា ឲ្យវាធ្វើឲ្យវាស្អាតស្អំហ្នឹងណា។ អ៊ីចឹង។

**សៈ** ដូច្នេះផែនការស្អីផ្សេងទៀតដែលអង្គប្រជុំហ្នឹងគេសម្រេចលោកអ៊ំ?

**ឆ៖** ផែនការអង្គប្រជុំហ្នឹងវាសម្រេច ទៅអារឿងយើងចូលទៅអានេះ ប៉ុន្តែបដិវត្តន៍ អានេះក៏វាដើម។ ដល់ចុងបដិវត្តន៍ដល់ចុង។ ផែនការនេះដូចវាខ្លាំង អ៊ីចឹង។ ធ្វើការនេះបើភូមិណាវាមិនកើត វាមានការៗខុស មានការត្រូវភូមិហ្នឹង គេមកគណៈកម្មាធិការនេះហើយវាមិនរឹង អ៊ីចឹង។

**ស៖** ពេលដែលធ្វើខុសផែនការ តើគេធ្វើយ៉ាងម៉េចទៅចំពោះអ្នកធ្វើខុសផែនការលោកអ៊ំ?

**ឆ៖** អាន៎ុងវាក្តៅក្រហាយហើយ ដល់ទៅហើយ គេថាបដិវត្តន៍ អាហ្នឹងហើយ។ អារឿងនេះបើយើងធ្វើមិនកើតវាលែងចោលទៅ ស្តាប់មិនស្តាប់គេលែងចោលប៉ុណ្ណឹង។ ពួកនេះអាផែនការនេះវាដល់ផែនការពួក អាយ៉ា ពួកអាធុច អីនេះណា។ អ៊ីចឹង ពួកដឹកនាំពួកនេះ។ អ៊ីចឹងវាផែនការទីពីរហើយន៎ែ ផែនការទីពីរហ្នឹងហើយ អាអំមិញវា ដូចវាល្អបន្តិច ឲ្យភូមិគ្រប់គ្រងហ្នឹងណា។ អានេះដល់ផែនការនេះអត់ល្អទេ។ បើធ្វើអីក៏មិនកើត ចោទយើងខ្មាំងហើយ។

[១០:០៧:៤៩]

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ចោទខ្មាំង?

**ឆ៖** បាទ។ វាចោទខ្មាំង ភូមិណាដែលមិនកើតកម្មាភិបាលនេះ វាចោទខ្មាំង អ៊ីចឹង។ បានហ្នឹងហើយ ន៎ែ ពេលវេលាដ៏ល្អ ពួកអាគេថាបដិវត្តន៍គេដឹកនាំន៎ុងណា គេហៅបដិវត្តន៍ដែរ។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ក្រោយមកទៀត?

**ឆ៖** បាទ, ក្រោយមកទៀត អ៊ីចឹង។ អានេះវាមានតែទេ ជំនាន់ទីពីរន៎ែ ខ្លាំង។ បើយើងធ្វើកើតវាកើត បើធ្វើមិនកើតយើងទៅហើយ ព្រោះគេថាបដិវត្តន៍ដែរអានេះ។

[១០:០៨:៤៨]

**ស៖** លោកអ៊ំសូមបញ្ជាក់បន្តិចថា ខ្មាំងហ្នឹងគេយកទៅម៉េច? គេចោទថាខ្មាំងហ្នឹងគេធ្វើអីចំពោះខ្មាំងហ្នឹង? ហើយអ៊ំមានប្រសាសន៍ថា យកទៅហើយហ្នឹង យកស្អីគេយកទៅហើយហ្នឹង? យកទៅណាអ៊ំ?

**ឆ៖** ជួនកាលគេឃាំងទុក។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ឃុំឃាំង?

**ឆ៖** ឃុំឃាំងទុក។ ជូនកាលវាទៅរហូតធ្វើព្រៃងណោះ។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

យកទៅព្រៃ?

**ឆ៖** កាប់សម្លាប់មនុស្សទៅមានអី។ អ៊ីចឹង អានោះ ផែនការនេះវាចុងក្រោយ នៅក្តៅហ្នឹងណាស់។ ក្តៅ អានោះហើយសព្វថ្ងៃដែលថា ប៉ុល ពត, ពួក អៀង សារី ថាអ៊ីចឹង អាហ្នឹងកាលហ្នឹងវាក្តៅណាស់។ អាហ្នឹងច្រើនខូចខាតដែរ កម្លាំងសហគមន៍យើង អ៊ីចឹង។ ស្ងប់ស្ងាត់តែម្តង អត់ប៉ានទេមើលមុខមើលមាត់ទៅ មិនប៉ានមាត់កណ៌ា អ៊ីចឹង។ ដូចលលកឃើញខ្លែង។

[១០:១០:២០]

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ឬក៏លលកឃើញខ្លែង។

**ឆ៖** ហ្នឹងហើយ។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ស្ងាត់តែម្តង?

**ឆ៖** ស្ងាត់តែម្តង។ អាហ្នឹងហើយ យើងយល់ស្រាប់ហើយ ទាំងអស់គ្នា យើងឃើញហើយណាគ្រប់ភូមិដែរ ស្រុកដែរ នាំគ្នាថាបដិវត្តន៍គេដែរ អ៊ីចឹង ប៉ុន្តែកាប់សម្លាប់គេច្រើន។ អាហ្នឹង ក៏ខ្ញុំឃើញតែពីរហ្នឹងដែរ។ មួយអារឿងនៅភូមិ ពីរអារឿងដឹកនាំថ្មី។

[១០:១០:៥៥]

**ស៖** អរគុណលោកអ៊ំ។ លោកអ៊ំ នៅចងចាំបានទេ ថាមានខាងសហចៅក្រមស៊ើបអង្កេតធ្លាប់ចុះទៅសួរអ៊ំ នៅដល់ទីតាំងដែលអ៊ំរស់នៅ?

**ឆ៖** ខ្ញុំនៅជាប់គុកហើយ។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

អត់ទេ អ៊ំនៅចាំទេថាពួកតុលាការនេះ អ្នកស៊ើបអង្កេតគេចុះទៅនិយាយសម្ភាសជាមួយអ៊ំចាំទេ?

**ឆ៖** អត់ចាំទេ។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

គេបានទៅជួបអ៊ំអត់?

**ឆ៖** ទៅ។

[១០:១១:៣៣]

**ស៖** នៅពាក់ព័ន្ធដែលគេសួរអ៊ំ អ៊ំបានប្រាប់គេអំពីតួនាទីរបស់អ៊ំក្រោយឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ។ អ៊ំ អាចរៀបរាប់បាន-- អ៊ំអាចបញ្ជាក់បានទេ គេតែងតាំងឲ្យអ៊ំធ្វើអីពេលហ្នឹង?

**ឆ៖** បាទ, ប៉ុន្តែចាំខ្លះ អត់ខ្លះ។ វាយូរ វាអង្វែងហើយ។ កាលនុ៎ង តែងតាំងខ្ញុំធ្វើគណៈកម្មាធិការភូមិ ហើយធ្វើគណៈកម្មាធិការភូមិ។

[១០:១២:៣២]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមអភ័យទោស។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គាត់និយាយអំពីកិច្ចស្តាប់ចម្លើយ ដែលថាដើមបណ្តឹងរដ្ឋប្បវេណីគាត់មិនដឹង ប្រហែលជាឯកសារនោះ គឺកិច្ចសម្ភាសន៍ដោយអង្គភាពជនរងគ្រោះតែប៉ុណ្ណោះ។

ខ្ញុំគិតថា ខាងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីគួរតែលើកឯកសារយោង ថាឯកសារនោះលេខប៉ុន្មានដែរ ដែលបានបញ្ជាក់អម្បាញ់មិញនោះ?

[១០:១៣:១២]

**ប្រធានអង្គជំនុំ៖**

មេធាវីសូមបញ្ជាក់នូវលេខយោងឯកសារ។

**លោក គីម ម៉េងឃី៖**

បាទ, សូមអរគុណលោកប្រធាន គឺឯកសារស្តាប់ប្រតិចារឹកសម្ភាសន៍លោក រម៉ាម យុន គឺមានលេខ D208/3.2 ហើយឯកសារនេះ គឺធ្វើឡើងក្នុងអំឡុងឆ្នាំ២០០៨ ដែលសួរដោយលោក ស្វាយ សំណាង ហើយនិងលោក Bernard Brun នៅថ្ងៃ៨ កក្កដា ២០០៩ សូមទោសលោកប្រធាន។ ហើយឯកសារនេះ គឺមាននៅក្នុងសំណុំរឿងនេះរួចហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបន្តសំណួរទៀត ហើយមេធាវីមានពេលតែប្រាំនាទីទៀតទេណ៎ា។

**សួរដោយលោក គីម ម៉េងឃី៖**

សូមអរគុណលោកប្រធាន។

**ស៖** ជាបន្តទៀត សូមលោក លោកអ៊ំបញ្ជាក់អំពីតួនាទីរបស់លោកអ៊ំក្រោយឆ្នាំ១៩៧៥?

[១០:១៤:៣៦]

**ឆ៖** ខ្ញុំចង់សួរថាអ៊ីចេះ បើការងារនេះ រឿងនេះយ៉ាងម៉េចៗ ខ្ញុំចង់ចុះវាន៉ុង ការងារយើងធ្វើហ្នឹងណា។ វាខុសវាត្រូវយ៉ាងម៉េច វាអ៊ីចឹង។ សួរនេះ សួរតាមការងារធ្វើណ៎ា បាទ។ ពេលអាអំមិញនេះ ខ្ញុំនិយាយតាំងពីយើងធ្វើការងារមុន អានេះការងារក្រោយហ្នឹង។ ក្រោយរំដោះ មានអីក្រោយនេះវា យើងដឹកនាំដូចថាសព្វថ្ងៃនៅតាមភូមិ តាមឃុំស្រុកអ៊ីចឹង។ ធ្វើចម្ការ ធ្វើស្រែហ្នឹងហើយ ដឹកនាំម៉ែឪបងប្អូនទាំងអស់គ្នា ពេលធ្វើចម្ការស្រែមួយពីរឲ្យយើងសាមគ្គីគ្នា ធ្វើស្រែធ្វើចម្ការ។ បីទៀត ការខុស ការត្រូវ ដោះស្រាយតាមច្បាប់អង្គការ អានេះអ៊ីចឹង។ បួនទៀត ដើម្បីយើងកសាងអារឿងការស៊ីចុកបុកទំពា ដំណើរឲ្យមានផលអ៊ីចឹង មានប៉ុណ្ណឹង។

**ស៖** សូមអរគុណលោកអ៊ំ ហើយខ្ញុំអស់ពេលហើយ ខ្ញុំសូមសួរសំណួរមួយសំណួរចុងក្រោយទៅអ៊ំ។ តើអ៊ំអាចបញ្ជាក់បានទេ ថាមានអំពីគុណសម្បត្តិ និងគុណវិបត្តិដែលអ៊ំចូលនៅក្នុងចលនាតស៊ូនៅក្នុងសម័យខ្មែរក្រហមនោះ? សូមអរគុណ។

[១០:១៦:៣៨]

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ចំណុចល្អអ៊ំ ចំណុចអាក្រក់នៃបដិវត្តន៍ហ្នឹងម៉េច?

**ឆ៖** ប៉ុន្តែមុនដំបូងចូលធ្វើបដិវត្តន៍នេះ-- ដើមវា ប៉ុន្តែល្អដុះ ប៉ុន្តែវាអត់មានផ្លែ។ ដើមវា ផ្កាក៏ល្អដែរ ដើមវាក៏ល្អដែរ ដល់ផ្លែវាជ្រុះ អ៊ីចឹង។ មុនដំបូងថាអប់រំឲ្យយើងធ្វើបដិវត្តន៍នេះ វារំដោះជាតិៗទាំងអស់គ្នាយើង ដល់យូរទៅៗឃើញទៅ អាណាខុសនោះរើចោល អាល្អប្រើ ដល់-- ប្រើប្រាស់ស្លៀកពាក់ខោអាវហ្នឹង-- ហ្នឹងហើយ។ អាណាវាដាច់ណាស់ក៏បោះចោលទៅ យកអាថ្មីអ៊ីចឹង។ អាហ្នឹងក៏ខ្ញុំឃើញអ៊ីចឹង។ អង្កាល់ហ្នឹង ប៉ុន្តែដើមដូចវាល្អ ដល់ចុងដូចវាស្អុយអស់ អ៊ីចឹង អាហ្នឹងជំនាន់មួយ។ មួយពីរទៀត វាអស់ជាតិ ជាតិវារលាយអស់ហើយ មិនដឹងគេថាអាពូជអី អានេះពូជអី ទាំងអស់ពូជចាក់ជាមួយគ្នា រលាយចូលមិនដឹងវាខ្មៅ មិនវាស មិនដឹងវាអាក្រក់ មិនដឹងវាស្អុយ ខ្លះដុះ ខ្លះវាអត់ អ៊ីចឹង។ អានេះ ដល់ក្រោយនេះ ដូចវាអត់ត្រូវហើយ បងក៏មិនដឹង ម៉ែក៏មិនដឹង។ កូនរើឪ ឪរើកូន អ៊ីចឹង។

អានេះយើងឃើញវាអត់ចម្រើនទេ។ អាហ្នឹងហើយយើងសព្វថ្ងៃនេះ កម្លាំងប្រទេសយើងនេះ ដូចវា-- អានេះវាកំពុងតែវាដុះថ្មី អង្កាល់នុំងគេកាត់ត្រួយ វាផិតងាប់ៗ អ៊ីចឹង។ យើងយល់ស្រាប់ទាំងអស់គ្នាហើយ អាហ្នឹងជំនាន់នេះ។

[១០:១៩:៣១]

**ប្រធានអង្គជំនុំ៖**

អរគុណអ៊ំ។

ឥឡូវនេះពេលវេលាសម្រាប់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអស់ហើយ។

**លោក ពេជ អង្គ៖**

បាទ, សូមទោសលោកប្រធាន។ ខ្ញុំបាទគ្មានបំណងនឹងលើកជាសំណួរទេ ក៏ប៉ុន្តែដោយពិគ្រោះជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាមេធាវីផ្ទាល់របស់លោកអ៊ំនេះ ឃើញថាលោកអ៊ំហាក់ដូចជាមានការហត់។ លោកប្រធានថា តើសុំអនុញ្ញាតឲ្យគាត់សម្រាកបានប្រាំនាទីបានទេ មុននឹងចាប់ផ្តើមបន្តសំណួរ-- មុននឹងផ្ទេរការសួរនេះទៅភាគីបន្តទៀត? សូមលោកប្រធានពិនិត្យនិងសម្រេច។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ដើម្បីសម្រួលបរិយាកាសនេះឲ្យអាចមានលទ្ធភាពបន្តទៅមុខបាន ហើយពេលវេលាសមល្មមនឹងសម្រាកហើយ។ អង្គជំនុំជម្រះសាលាដំបូងប្រកាសសម្រាកម្ភៃនាទី ហើយចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញសម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២១ នាទី ដល់ម៉ោង ១០:៤៣ នាទី)*

[១០:៤៣:២៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។

**លោក ម៉ៃខល កាណាវាស៖**

សូមអភ័យទោសក្នុងពេលឈប់សម្រាក ខ្ញុំឃើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនិយាយជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលបានមកផ្តល់សក្ខីកម្មនេះ។ ខ្ញុំគិតដល់សក្ខីកម្មនេះ ខ្ញុំគិតថាការធ្វើដូច្នេះ គឺមិនត្រឹមត្រូវនោះទេ ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីកំពុងតែផ្តល់សក្ខីកម្ម។ បើសិនជាទាក់ទងក្រោយពីពេលផ្តល់សក្ខីកម្មទៅ គឺមិនបញ្ហានោះទេ។ ការដែលទាក់ទងក្នុងពេលនេះ គឺមិនសមស្រប ហើយវាមានឥទ្ធិពលទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី។

ដូច្នេះហើយ យើងមិនគួរធ្វើការទាក់ទងជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីនោះឡើយ។ ខ្ញុំឃើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គាត់ងក់ក្បាលដាក់ដើមបណ្តឹងរដ្ឋប្បវេណី ដូច្នេះហើយខ្ញុំមិនដឹងថាតើគាត់មានន័យយ៉ាងម៉េចនោះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ។

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណ។ ខ្ញុំមិនដឹងថាវិធានចែងនៅក្នុងប្រទេសបារាំង និងកម្ពុជាមានចែងយ៉ាងម៉េចនោះទេទាក់ទងទៅនឹងការប្រាស្រ័យទាក់ទងគ្នារបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសម្រាក។ ជាការពិតនៅពេលដែលសាក្សីផ្តល់សក្ខីកម្ម គឺមិនគួរមានឱកាសច្រើនឲ្យមេធាវីរបស់គេនិយាយជាមួយនឹងសាក្សីនោះទេ។ ដូច្នេះបានន័យថា វាមិនដូចគ្នាទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីនោះឡើយ។ ចំពោះជនជាប់ចោទក៏ដោយគ្នាដែរ នៅពេលដែលជនជាប់ចោទផ្តល់សក្ខីកម្ម គឺគាត់មិនត្រូវពិភាក្សាទៅលើមេធាវីទៅលើបញ្ហាប្រធានបទដែលគាត់កំពុងផ្តល់សក្ខីកម្មនោះឡើយ។ សូមអរគុណ។

[១០:៤៥:៣៥]

**ប្រធានអង្គជំនុំ៖**

សូមអរគុណ សហព្រះរាជអាជ្ញារងអន្តរជាតិ។

សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំគិតថាត្រូវតែឲ្យច្បាស់លាស់ទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី។ យើងត្រូវឈប់ហៅគាត់ថាជាសាក្សីទៅ។ ម្សិលមិញលោកចៅក្រម ឡាវែន៍ បានយល់ស្របហើយ គឺគាត់មិនមែន

ជាសាក្សីទេ។ អ៊ីចឹងគឺថា អ៊ីចឹងមេធាវីអាចមានសិទ្ធិទៅពិភាក្សាជាមួយកូនក្តីរបស់ខ្លួន ដូចខាងជនជាប់ចោទនោះដែរ។ អ៊ីចឹងគឺជាវិធានច្បាប់ ហើយកើតចេញពីច្បាប់កម្ពុជា ហើយដែលកើតចេញពីច្បាប់បារាំងនោះ។ អ៊ីចឹងយើងឈប់ពិភាក្សារឿងបញ្ហាអ៊ីចឹងដដែលៗ អ៊ីចឹងត្រូវតែទទួលយកការពិតនេះទៅ។ ហើយយើងថាឈប់រំឭកពីច្បាប់មូលដ្ឋានដដែលៗហ្នឹងទេ។

[១០:៤៦:៣៤]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមបញ្ជាក់បំភ្លឺចំណុចមួយទៀត ចំណុចតូចមួយ។ ខ្ញុំសូម ខ្ញុំមិនជំទាស់កាលពីម្សិលមិញដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីមិនធ្វើការស្បថ។ ខ្ញុំទទួលស្គាល់ដោយសារតែនៅក្នុងប្រព័ន្ធច្បាប់បារាំង។ នៅចុងក្រោយ គឺអង្គជំនុំជម្រះជាអ្នកសម្រេចទៅលើទម្ងន់នៃភស្តុតាង ទៅលើចម្លើយរបស់សាក្សី ឬក៏សក្ខីកម្ម។ គឺចម្លើយ និងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពេលខ្លះមិនសូវមានទម្ងន់ដោយសារតែសក្ខីកម្មមិនបានស្បថ។

ខ្ញុំសូមជម្រាបថា ប្រសិនបើយើងមិនមានការអនុវត្តមួយដោយសមស្រប និងត្រឹមត្រូវនោះទេ គឺវាមិនល្អនោះទេ។ បានន័យថានៅក្នុងពេលដំណើរការផ្តល់សក្ខីកម្មនេះ គឺយើងធ្វើយ៉ាងណាដើម្បីកុំឲ្យមានការប្រាស្រ័យទាក់ទងគ្នាជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែលើកលែងតែជនជាប់ចោទ ដោយសារតែជនជាប់ចោទមានសិទ្ធិក្នុងការប្រឹក្សាជាមួយនឹងមេធាវីរបស់ខ្លួន។

[១០:៤៧:៤៣]

វាមិនជាការអនុវត្តល្អនោះទេ ប្រសិនបើភាគីណាមួយ គាត់យល់ទៅលើបញ្ហាហ្នឹង ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គាត់ព្យាយាមឲ្យដើមបណ្តឹងរដ្ឋប្បវេណីគាត់មានការប្រុងប្រយ័ត្នក្នុងការឆ្លើយតប នឹងផ្តល់សក្ខីកម្ម។

នៅពេលនេះគឺខ្ញុំធ្វើយ៉ាងណា ខ្ញុំជៀសវាងកុំចង់ឲ្យមានបញ្ហាណាមួយកើតឡើង ហើយខ្ញុំលើកឡើងបញ្ហាហ្នឹងដដែលៗ។ ការអនុវត្តដ៏ល្អនេះ គឺដើម្បីឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ទាំងអស់គ្នា។ មិនគួរប្រាស្រ័យទាក់ទងគ្នាជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

[១០:៤៨:២០]

ដូចគ្នានោះដែរ ដើមបណ្តឹងរដ្ឋប្បវេណី មិនគួរទៅធ្វើការប្រាស័យជាមួយនឹងបុគ្គលផ្សេងក្នុងពេលដែលធ្វើសក្ខីកម្មនោះឡើយ។ ក្រោយពេលផ្តល់សក្ខីកម្ម គឺមិនមានបញ្ហានោះឡើយ គាត់អាច

ទាក់ទងបាន។

អង្គជំនុំជម្រះបានព្យាយាមអនុញ្ញាតឲ្យសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីគាត់អានចម្លើយ និងសក្ខីកម្មរបស់គាត់រួចទៅហើយ។ ប៉ុន្តែ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យមេធាវីតំណាងនោះធ្វើការណែនាំកូនក្តីរបស់គាត់ ក្នុងពេលផ្តល់សក្ខីកម្មនោះទេ។ ដូច្នេះហើយ ខ្ញុំមិនស្នើឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គាត់ទៅណែនាំទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ ដូច្នេះហើយក៏មិនចង់ឲ្យគាត់ធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីនោះឡើយ។ ទោះបីជាតាមរយៈការបង្ហាញនៅសញ្ញាណាមួយដល់ដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ។

[១០:៤៩:១៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ពេជ អង្គ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន! យើងមិនគួរមានវិធានណាមួយ ដែលមានការរើសអើងចំពោះមេធាវី និងកូនក្តីរបស់ខ្លួនទេ។ ជនជាប់ចោទ គាត់មានមេធាវីរបស់ខ្លួន គាត់មានសិទ្ធិពេញលេញនៅក្នុងការពិគ្រោះយោបល់គ្រប់ពេលជាមួយនឹងមេធាវីរបស់ខ្លួនទាំងផ្លូវច្បាប់ក៏ដោយ បញ្ហាផ្សេងទៀតក៏ដោយ។

ចំណែកឯខាងដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនកូនក្តីរបស់យើងខ្ញុំពុំមានសិទ្ធិនៅក្នុងការពិគ្រោះយោបល់ជាមួយនឹងមេធាវីរបស់ខ្លួនទេ។ នេះមិនមានភាពស្មើភាព ភាពស្មើគ្នារវាងសិទ្ធិរបស់ភាគីនោះឡើយ។ ហើយម៉្យាងទៀត យើងគ្មានវិធានណាមួយហាមឃាត់មិនឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រាស្រ័យជាមួយនឹងកូនក្តីរបស់ខ្លួនទេ ហើយជាពិសេសទាំងបញ្ហាច្បាប់ ឬក៏ថាបញ្ហាផ្សេងៗរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

[១០:៥០:២៩]

ដើមបណ្តឹងរដ្ឋប្បវេណីមានភាពទន់ខ្សោយចាស់ ហើយទាំងបញ្ហាសមត្ថភាពខាងចំណេះដឹងក៏មានកម្រិត។ ដូច្នេះទាំងសុខភាពក៏អាចមានបញ្ហាដូចគ្នាដែរ។ អ៊ីចឹងគួរតែគោរពនូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការប្រាស្រ័យទាក់ទងជាមួយមេធាវីនៅក្នុងការស្គាល់សុខទុក្ខ និងក៏ដូចជាបញ្ហាផ្លូវច្បាប់ដែរ។ ហើយអ៊ីចឹងនេះគឺជាសិទ្ធិមួយដែលថា ត្រូវតែមានស្មើគ្នារវាងភាគីនិងភាគី ដែលមិនអាចឲ្យមានការរើសអើងចំពោះសិទ្ធិនេះបានទេ។

សូមលោកប្រធានអនុញ្ញាតឲ្យ--

**លោក គីម ម៉េងឃី៖**

បាទ, សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទាំងស្រុងទៅនឹងអ្វីដែលសហមេធាវីអន្តរជាតិខាងការពារក្តីបានលើកឡើងនេះ គឺវាផ្ទុយទៅនឹងទំនៀមទម្លាប់ច្បាប់ដែលធ្លាប់អនុវត្តក្នុងប្រទេសកម្ពុជាយើង ពីព្រោះថា ទាំងនៅក្នុងតុលាការជាតិក៏ដោយ ទាំងនៅក្នុងវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះសាលាដំបូងនេះក៏ដោយគឺថា ដើមបណ្តឹងរដ្ឋប្បវេណីគាត់ទទួលសិទ្ធិការពារផលប្រយោជន៍របស់គាត់គ្រប់ដំណាក់កាល។ ដូច្នេះការប្រាស្រ័យពាក់ព័ន្ធរវាងមេធាវីនិងកូនក្តី គឺជាសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាសិទ្ធិរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី គ្មានភាគីណាមួយអាចជ្រៀតជ្រែកអំពីសិទ្ធិនេះបានទេ។

[១០:៥២:០០]

ហើយសិទ្ធិនេះក៏ប្រៀបដូចជាសិទ្ធិប្រាស្រ័យទាក់ទងរបស់មេធាវីជនជាប់ចោទ និងជាមួយនឹងកូនក្តីរបស់គាត់ដែរ។ ដូច្នេះ ខ្ញុំក្នុងនាមជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមឲ្យអង្គជំនុំជម្រះសាលាដំបូងមេត្តាទទួលស្គាល់សិទ្ធិនេះ គ្រប់ដំណាក់កាលទាំងអស់នៅក្នុងការប្រាស្រ័យទាក់ទងគ្នា ហើយក៏ដូចជាអ្វីដែលយើងបានធ្វើនៅក្នុងសំណុំរឿង០០១ផងដែរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ ហើយបញ្ហានេះដូចជានៅតែមិនទាន់ច្បាស់លាស់ ហើយដើម្បីបញ្ជាក់ច្បាស់លាស់ជាការអនុវត្តតាមច្បាប់ជាតិ ក៏ដូចជាវិធានផ្ទៃក្នុងដែរនោះ គឺថាដើមបណ្តឹងរដ្ឋប្បវេណីក៏ជាភាគីនៃរឿងក្តីដែរ។ ដូច្នេះគាត់មានសិទ្ធិនៅក្នុងការពិភាក្សាប្រឹក្សាយោបល់ជាមួយនឹងមេធាវីរបស់គាត់គ្រប់ពេលវេលានៅក្នុងអំឡុងពេលនៃដំណើរការសវនាការ។ ហើយខ្ញុំបញ្ជាក់ឡើងវិញ អំពីបទប្បញ្ញត្តិដែលចែងពាក់ព័ន្ធជាមួយនឹងជនជាប់ចោទនិងសាក្សី ដែលបានចែងនៅក្នុងវិធាន៨៨ “ការបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះត្រង់អនុកថាខណ្ឌ២ ជនជាប់ចោទមិនត្រូវប្រាស្រ័យទាក់ទងនឹងគ្នាទេ ប្រសិនបើអាចធ្វើទៅបានអ្នកជំនាញ និងសាក្សី ត្រូវស្ថិតក្នុងបន្ទប់ផ្សេង ដែលមិនអាចមើលឃើញ ឬឮពីអ្វីដែលប្រព្រឹត្តនៅក្នុងបន្ទប់សវនាការទេ។ នៅពេលស្ថិតនៅក្នុងបន្ទប់នោះសាក្សីមិនត្រូវប្រាស្រ័យទាក់ទងគ្នាទេ។”

[១០:៥៣:៥៦]

ដូច្នេះនៅក្នុងវិធាននេះចែងច្បាស់លាស់ទៅលើតែជនជាប់ចោទ ទៅតែអ្នកជំនាញសាក្សី តែប៉ុណ្ណោះ។ នេះគឺច្បាស់លាស់ហើយ ហើយប្រសិនបើមានបទប្បញ្ញត្តិឯណាដែលជាច្បាប់ជាតិក្តី ជា

វិធានផ្ទៃក្នុងក្ដី មេធាវីការពារក្ដីអាចបង្ហាញឲ្យបានច្បាស់លាស់ នូវខ្លឹមសារនៃវិធាន ឬបទប្បញ្ញត្តិជាក់លាក់ណាមួយដើម្បីយកមកតតាំង។ អ៊ីចឹងច្បាស់លាស់ចាប់ពីពេលនេះតទៅ គឺញែកឲ្យបានច្បាស់លាស់រវាងឋានៈនៃការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី រវាងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី។ ដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានឋានៈខុសពីសាក្សី គឺដោយចូលមកមិនស្បថទេ។ ចូលមកមានសិទ្ធិក្នុងការប្រាស្រ័យទាក់ទងដោយសេរីជាមួយនឹងមេធាវីរបស់ខ្លួន ហើយក្នុងករណីប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីណាមិនចូលរួម មិនមាន មិនអាចចូលរួមបានគឺវិធាននៃច្បាប់ជាតិ ក៏ដូចជាវិធានផ្ទៃក្នុង មិនមានវិធានឯណាបង្ខំឲ្យមេធាវី ត្រូវតែចូលខ្លួន នាំខ្លួនមកបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះទេ មានតែសាក្សី ឬអ្នកជំនាញប៉ុណ្ណោះ ដែលមានអង្គជំនុំជម្រះ ឬក៏តុលាការអាចចាត់វិធានការបង្ខំ ក្នុងករណីគាត់រឹងរូស រឹងទទឹងមិនព្រមចូលតាមការបង្គាប់របស់តុលាការ។ នេះជាឋានៈខុសគ្នា។

[១០:៥៥:៣៨]

មួយទៀត គឺដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការលើកឡើង ថ្លែងការណ៍ រៀបរាប់ ឬក៏ប្ដឹងទាមទារសំណងចំពោះករណីទូទៅនៅតាមច្បាប់ជាតិ ដោយនៅទីនេះការប្ដឹងទាមទារសំណងជាបន្ទុករបស់មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ប៉ុន្ដែទោះបីយ៉ាងណា អង្គជំនុំជម្រះបានជម្រាបហើយ ថ្លែងរៀបរាប់អំពីព្យសនកម្មដែលខ្លួនបានទទួលរង នៅក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិប-តេយ្យ ដែលខ្លួនមាននៅរហូតដល់សព្វថ្ងៃនេះ។ នេះអង្គជំនុំជម្រះបានជម្រាបមុនហើយ។ ហើយសិទ្ធិនេះគឺមិនមានទេចំពោះសាក្សី។

នេះទំនងជាច្បាស់លាស់ហើយ ហើយដើម្បីបញ្ជាក់បន្ថែមទៀត ដោយសារការអនុវត្តច្បាប់កម្ពុជាដែលមានទំនាក់ទំនងជាមួយនឹង ទទួលឥទ្ធិពលពីច្បាប់បារាំង សូមលោក ហ្សង់ម៉ាក អាចបំពេញបន្ថែមបាន សូមអញ្ជើញ ដើម្បីបញ្ជាក់បញ្ហានេះឲ្យច្បាស់លាស់ថ្ងៃនេះ។ ចៀសវាងរឿងដដែលៗនេះ។

[១០:៥៧:០៣]

បើមិនមានទេ យើងចាប់ផ្ដើមកិច្ចដំណើរការរបស់យើង មុននឹងចាប់ប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការសួរទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសូមជម្រាបដល់ភាគីនិងសាធារណជនបានជ្រាបថា អង្គជំនុំជម្រះមានបំណងស្ដាប់សក្ខីកម្មសាក្សី TCW-395 នៅរសៀលនេះ និងនៅថ្ងៃស្អែក។ តែដោយលក្ខណៈសំខាន់នៃសាក្សីរូបនេះ គួបផ្សំនឹងបញ្ហាសុខភាពផ្ទាល់ខ្លួនរបស់គាត់ផងនោះ ហេតុនេះ ក្នុងករណី ឬកាលៈទេសៈណាមួយ ដែលអង្គជំនុំជម្រះមិនអាចស្ដាប់

សក្ខីកម្មរូបនេះបានចប់សព្វគ្រប់តាមពេលវេលាដែលបានគ្រោងទុកនោះ នោះគឺអង្គជំនុំជម្រះនឹងបន្តធ្វើសវនាការនៅថ្ងៃសុក្រទី៩ ធ្នូ ឆ្នាំ២០១១ ថែមទៀត ដើម្បីបញ្ចប់នូវការផ្តល់សក្ខីកម្មចំពោះសាក្សីដ៏សំខាន់នេះ។

ម្យ៉ាងទៀត ដោយសារបញ្ហាបច្ចេកទេសនៃការស្តាប់សក្ខីកម្ម តាមមធ្យោបាយសោតទស្សន៍មានការលំបាក និងបញ្ហាសុខភាពរបស់គាត់ ដែលមានជំងឺ និងមានភាពចាស់ជរាហើយនោះ។ ដូច្នេះសាក្សី TCW-395 នេះអង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យភាគីអាចសួរសំណួរចំពោះសាក្សីរូបនេះ ចំពោះអង្គហេតុទាំងឡាយនៅក្នុងសំណុំរឿង០០២ ទាំងមូលតែម្តង។

[១០:៥៨:៥៦]

ម្យ៉ាងទៀត ក្នុងករណីសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗទៀត ក្នុងករណីដែលមានស្ថានភាពដូចគ្នា ឬប្រហាក់ប្រហែលគ្នានឹងសាក្សី TCW-395 នេះ អង្គជំនុំជម្រះជម្រាបទៅភាគីថាសូមភាគីធ្វើសំណើសុំមកអង្គជំនុំជម្រះឲ្យបានឆាប់រហ័ស ក្នុងកាលវេលាសមស្រប ដើម្បីអង្គជំនុំជម្រះពិនិត្យសម្រេច និងផ្តល់ព័ត៌មានទាំងនេះជូនទៅភាគីផ្សេងទៀត បានត្រៀមលក្ខណសម្បត្តិក្នុងការពិភាក្សាដេញដោលបានពេញលេញ។

ជាកិច្ចបន្ត សូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការសួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ហើយសហព្រះរាជអាជ្ញាមានពេលសាមសិបនាទី ក្នុងការសួរនេះ។ ពីនេះទៅរហូតដល់ម៉ោងដប់មួយសាមសិបនាទីយ៉ាងយូរបំផុត។

សូមអញ្ជើញ!

[១១:០០:១៣]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងឈេះ**

សូមអរគុណលោកប្រធាន។ ដំបូងទាក់ទងនឹងរយៈពេលសាមសិបនាទី គឺបើខ្ញុំចង់សូមឲ្យលោកប្រធានមេត្តាទន់ភ្លន់បន្តិច ព្រោះទាក់ទងនឹងពេលសាមសិបនាទីនេះ ព្រោះថាវាមានបញ្ហារឿងយល់សំណួរជាភាសាខ្មែររបស់ដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង។ ហើយដោយសារតែសហព្រះរាជអាជ្ញាហ្នឹងមានបន្ទុកភស្តុតាងហ្នឹងនៅក្នុងសំណុំរឿងយើងនេះ។

ដូច្នេះ គឺថាយើងអាចនឹងលើសពីរបីនាទី ព្រោះថាយើងមិនដឹងថា ចម្លើយរបស់សាក្សីហ្នឹងមានលក្ខណៈសង្ខេប ឬក៏អត់នោះទេ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយង៍ ដេស្មាងលៈ**

ជម្រាបសួរលោក រម៉ាម យុន តំណាងឲ្យសហព្រះរាជអាជ្ញា យើងសូមអរគុណលោកដែលថា បានមកពីឆ្ងាយមកដល់ភ្នំពេញ និងផ្តល់សក្ខីកម្មក្នុងការជម្រះសេចក្តីនេះ។ យើងនឹងចោទសំណួរទៅដល់លោក ហើយយើងដឹងហើយថា លោកមិននិយាយភាសាខ្មែរ ដូចភាសាកំណើតនោះទេ។

ដូច្នេះកុំអល់អែកអ្វី បើសិនជាមានបញ្ហារឿងយល់ហ្នឹង មិនយល់អីហ្នឹង សូមប្រាប់យើងឲ្យដឹង។ បើសិនជាលោកមិនចាំអ្វីមួយ អ៊ីចឹងសូមប្រាប់យើងថា លោកមិនចាំច្បាស់លាស់នោះទេ អ៊ីចឹងទៅធ្វើឲ្យយើងអាចនិយាយពីប្រធានផ្សេងបាន។

[១១:០១:៥៦]

**ស៖** ខ្ញុំចង់ត្រឡប់មកនិយាយអំពីអ្វីដែលលោកបានលើកឡើងអម្បាញ់មិញនេះ។ លោកបានជម្រាបថាលោកត្រូវបានគេសួរចម្លើយ ដោយអ្នកស៊ើបអង្កេតនៃតុលាការខ្មែរក្រហមនេះ។ តើលោកអាចបញ្ជាក់សាជាថ្មីម្តងទៀតបានទេ ថាតើលោការសួរចម្លើយលោកនុំងនៅកន្លែងណា? នៅភ្នំពេញ ឬក៏នៅផ្ទះលោក ដើម្បីឲ្យយើងទាំងអស់គ្នាច្បាស់លាស់។

**លោក រម៉ាម យុន៖**

**ឆ៖** ខ្ញុំចង់បញ្ជាក់ អានេះខ្ញុំថាបញ្ជាក់នេះ គឺអត់វែងឆ្ងាយទេ វាខ្លីៗណ៎ា។ តាមយល់ តាមដឹងកន្លែងណាអត់យល់ អត់ដឹង តាមគោលការណ៍អាហ្នឹងវាចង់ឲ្យថា ខ ចំណុចអីដែលនៅមិនទាន់ច្បាស់ណ៎ា។ បើខ្ញុំបន្ថែមទៀត ខ ណាវាច្បាស់ហើយ ទុកអ៊ីចឹង។ ខ្ញុំឆ្លើយ ខ ហ្នឹងវាមិនឃើញណា ខ-១, ខ-២ ណ៎ា យើងដើមណ៎ា។ ឲ្យពួកបងៗ ពួកពូៗ ជួយបង្ហាញឲ្យវាចំណុចណ៎ា។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ចង់សួរអ៊ីចេះអ៊ំថា អ្នកស៊ើបអង្កេតគេធ្លាប់សម្ភាសអ៊ំ ធ្លាប់ជួបនិយាយជាមួយអ៊ំ សម្ភាសអ៊ំ។ សម្ភាសន៍ហ្នឹងសម្ភាសនៅភ្នំពេញ ឬនៅរតនគិរី? គេសម្ភាសហ្នឹងនៅណាអ៊ំ? គេចុះទៅជួបនិយាយជាមួយអ៊ំណ៎ា គេកត់ត្រាអីហ្នឹងនៅភ្នំពេញ ឬនៅរតនគិរី?

**ឆ៖** នៅភ្នំពេញនេះដែរ។ ពេលកត់ត្រានេះនៅរតនគិរី អ៊ីចឹង។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

គេសម្ភាសនៅរតនគិរី?

**ផះ** ហ្នឹងហើយ។

[១១:០៤:២៥]

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

នៅភ្នំពេញទៀត?

**ផះ** ទៅដល់ភ្នំពេញហ្នឹងទៀត។

**សះ** បាទ ខ្ញុំៗ ប្រហែលយល់ថា គាត់បានបំពេញសំណុំឯកសារដែលព័ត៌មានជនរងគ្រោះហ្នឹង នៅរតនគិរី ហើយបន្ទាប់មកទៀតនឹងគាត់ត្រូវបានស្តាប់ចម្លើយនៅភ្នំពេញដោយសហចៅក្រមស៊ើបអង្កេត។ ឥឡូវនេះខ្ញុំសូមត្រឡប់មកនិយាយពីរយៈពេល ដែលលោកត្រូវបានគេជ្រើសរើសចូលទៅក្នុងចលនាបដិវត្តន៍នៅខាងព្លសាន។ តើលោកចាំដែរឬថាតើនៅក្នុងដំណាក់កាលណាដែលខ្មែរក្រហមបានមកដល់នោះ មកដល់ខេត្តស្ទឹងត្រែងហ្នឹង?

**ផះ** រឿងហ្នឹង វាខាងខ្មែរក្រហម។ គេសួរអ៊ីចឹងដែរ?

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ហ្នឹងហើយ ខ្មែរក្រហមទៅដល់ស្ទឹងត្រែងពេលណាអ៊ំ? ឆ្នាំណា? ពេលណា?

**ផះ** ឆ្នាំក៏ភ្លេចដែរ ភ្លេចឆ្នាំ អ៊ីចឹង។ កាលនេះ និយាយៗតាមនឹកឃើញហ្នឹងណា តាមយើងយល់ហ្នឹងណា។ ខ្មែរក្រហមវាបំផុសចលនា ពីដើមខ្ញុំអត់ដឹងទេ អត់ឮទេ ទាល់គេថាខ្មែរក្រហម គេថាបដិវត្តន៍ដែរអ៊ីចឹង។ យ៉ាងម៉េចទៅបដិវត្តន៍? គេថាឥឡូវយើងធ្វើបដិវត្តន៍ ធ្វើចុះធ្វើឡើង អត់កើតៗ យ៉ាងអ៊ីចឹង? បើឯអ្នកយល់ឯណាដឹង អ្នកតស៊ូតវ៉ាបាន។ អ្នកហ្នឹងកាប់ចោល។

[១១:០៦:៥២]

**សះ** លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំពិបាកយល់ ពីព្រោះថាការបកប្រែនោះថាឃឺត ដែលធ្វើឲ្យថាបើសិនជាដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយទៅនឹងសំណួរផ្សេង ដែលមិនមែនជាសំណួរខ្ញុំនោះ ខ្ញុំពិបាកយល់ណាស់។ អ៊ីចឹងអ្វីដែលខ្ញុំចង់ដឹងហ្នឹង ខ្ញុំចង់ត្រឡប់ចូលមកដំណាក់កាលដំបូង ដែលពេលមានគេទៅបញ្ចុះបញ្ចូលលោកឲ្យចូលទៅក្នុងចលនាបដិវត្តន៍។ តើពេលនោះគេបាននិយាយប្រាប់លោកយ៉ាងម៉េចខ្លះ? ហើយនៅពេលដែលគេជួបលោកនោះ គេៗនិយាយយ៉ាងម៉េចខ្លះ ដើម្បីឲ្យគេចូលទៅជាមួយពួកគេ គេប្រាប់ឲ្យលោកធ្វើអីគេខ្លះ?

**ផះ** បាទ។ កាលហ្នឹង គេប្រាប់អ៊ីចេះ យើងធ្វើបដិវត្តន៍ដើម្បីបម្រើជាតិៗ ហើយរំដោះប្រទេស

អ៊ីចឹង។ បម្រើជាតិដើម្បីកសាងឲ្យជាតិចម្រើន។ សាមគ្គីគ្នា បណ្តុះបណ្តាល កសាងជនបទ កសាងទីក្រុង អ៊ីចឹងអាហ្នឹង។ បញ្ហាផ្សេងៗដូចវាអត់ឃើញ ដល់ធ្វើចុះធ្វើឡើងហើយឃើញទៅ។ កសាងយ៉ាងម៉េច? វាប្រទេសក៏មិនកើត ភូមិក៏មិនកើតអ៊ីចឹងហើយ។ កសាងយ៉ាងម៉េចក៏មិនចេញ។ អាហ្នឹងត្រង់នេះវាអត់កើតទេ។

**ស៖** សូមអរគុណ។ តើលោកចូលក្នុងចលនាហ្នឹងដោយស្ម័គ្រចិត្ត ឬក៏មានការបង្ខំណាមួយ តើលោកត្រូវបានគេបង្ខំដែរឬទេ នៅពេលនុង?

[១១:០៩:៣២]

**ឆ៖** ពេលហ្នឹងគេបង្ខំខ្លះ យើងចង់ឃើញខ្លះហ្នឹងណា។ គេបង្ខំ ហើយចង់ធ្វើកម្មាភិបាលដឹកនាំ។ បើរឿងដឹកនាំ កម្មាភិបាលដឹកនាំ អប់រំកម្លាំងសហគមន៍ទាំងអស់។ បើអ៊ីចឹង នេះអ្នកខ្លះវា យល់ អាខ្លះវាអត់យល់ អ៊ីចឹង។ អារឿងនេះវាទាស់ខ្លះ វាមិនយល់ គេថា ប្រឆាំងអ៊ីចឹង។ (ឮមិនច្បាស់) យើងអប់រំទៀត គេថាយើងមិនល្អ ត្រង់នេះវាដូចវាឈឺក្បាលណាស់។ បើអប់រំកម្លាំងសហគមន៍នេះ វា ចង់វាបាន ចង់វាឆ្លាត ចង់វាយល់ ច្បាប់ អារឿងយើងកសាងប្រទេសជាតិ។ ហើយនេះវាខ្លះ វាចង់ខ្លះ វាអត់អ៊ីចឹង។ រឿងនេះវាពិបាក វាពិបាកមែន។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំចង់ត្រឡប់មកដល់ពេលដែលលោកជានីរសារនោះ លោកជានីរសារមុននឹងក្លាយជាប្រធាន។ នៅពេលដែលលោកជានីរសារនោះលោកបាននិយាយប្រាប់យើងអម្បាញ់មិញថា លោកនាំយកសារទៅលោក វ៉ាន់។ ប៉ុន្តែនៅពេលដែលលោកត្រូវយកសារពីឃុំ ទៅភូមិ ឬក៏ក្រុមអីហ្នឹង តើលោកដឹងថា សារដែលលោកយកទៅឲ្យគេនោះចេញមកពីណា? ហើយអ្នកណាអ្នកឲ្យលោកនៅពេលនុ៎ង?

**ឆ៖** អារឿងហ្នឹងខ្ញុំអត់-- ឃើញតែបងវ៉ាន់ គាត់ចុះធ្វើការហ្នឹងណ៎ា។ អានេះគាត់មានសំបុត្រអីបញ្ជូនឲ្យតាមកម្មាភិបាលគាត់ត្រូវការហ្នឹងណ៎ា។ បញ្ជូនឲ្យអ៊ីចឹង។ អានោះ កាលហ្នឹងផ្ទះគាត់នៅអូរអីធ្វើការអប់រំកម្មាភិបាលនោះណាអ៊ីចឹង។ ធ្វើចុះ ធ្វើឡើងថា ថាដូចវារឿងឃើញផ្តែអី មិនដឹងទៅណាមកណា បើយកបាត់ឈឹងទៅ។ យើងវាបាត់ទៅ។

[១១:១២:៥៤]

**ស៖** បាទ,សូមអរគុណ។ អ៊ីចឹងនៅពេលដែលលោកនៅក្នុងតំបន់ព្រៃសានហ្នឹងកាលសម័យហ្នឹងតើភូមិភាគហ្នឹងមានរចនាសម្ព័ន្ធយ៉ាងម៉េចដែរ? តើមានថ្នាក់រដ្ឋបាលច្រើនហ្នឹងនៅក្រោមភូមិភាគហ្នឹង

ចុះ គឺថាចុះមករហូតមកដល់ភូមិដែរឬទេ?

**ឆ៖** បាទ, ប៉ុន្តែរឿងថ្នាក់កម្មាភិបាលនេះមានតាំងពីស្រុក ឃុំ ដល់ភូមិ អ៊ីចឹង។ ដល់ភូមិដែរ ប៉ុន្តែការគេផ្សព្វផ្សាយផែនការ វាផ្សាយតាមខ្សែរយៈការចាត់តាំងដែរ។

**ស៖** នៅលើថ្នាក់ស្រុកហ្នឹង តើមានថ្នាក់អ្វីដែរ?

**ឆ៖** នៅក្នុងថ្នាក់ស្រុកមានផែនការអីក៏អប់រំតាមស្រុក ក្នុងស្រុកហ្នឹងហើយ បើផែនការពីថ្នាក់លើ--។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

លើស្រុកទៀតមានអីអ៊ំ? លើស្រុកទៀត?

**ឆ៖** ប្រធានឃុំគេទៀត។

[១១:១៤:៣០]

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

លើស្រុក។ ស្រុក លើឃុំ។ លើស្រុកទៀតមានអីទៀត?

**ឆ៖** អាហ្នឹងវាមកពីនេះហើយ អង្គការពីលើហ្នឹងណា៎។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ពីលើភូមិមានអី ពីលើភូមិ?

**ឆ៖** ភូមិវាមកពីឃុំហ្នឹង បានភូមិ។ ខ្សែរយៈវាអ៊ីចឹង។ ពីលើនេះគ្រប់គ្រងពួកស្រុក ស្រុកគ្រប់គ្រងឃុំ។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ពីណាគ្រប់គ្រងលើស្រុក អ៊ំ?

**ឆ៖** លើស្រុកហ្នឹងវាមានខ្សែវាដែរ អាណា តាំងពីអា ដូចជាអណ្តូងមាស ស្រុកអណ្តូងមាស ខេត្ត គឺមកតាមខ្សែរយៈខេត្តហ្នឹងដែរ ដល់ស្រុក។ ស្រុកបានដល់ឃុំ។ ឃុំដល់ភូមិ អ៊ីចឹង។ តាមខ្សែរយៈវាអ៊ីចឹង។

**ស៖** បាទ, សូមអរគុណ។ ឥឡូវទាក់ទងទៅនឹងមធ្យោបាយទំនាក់ទំនងគ្នា នៅពេលដែលលោកទទួលបញ្ជា តើបញ្ជាទាំងអស់នោះផ្តល់ជូនមកលោកតាមរបៀបណា ឬតាមតែនីរសារ ឬក៏មានមធ្យោ-បាយទំនាក់ទងផ្សេងទៀត ដើម្បីផ្តល់បទបញ្ជាដល់លោកនោះ?

[១១:១៦:១៤]

**ផ៖** កាលពេលនុ៎ង វាមានតែការប្រើប្រាស់ ព្រោះពេលមានការងារអី វាទាក់ទងហៅគេប្រជុំអីណ៎ា អ៊ីចឹង។ ហើយមួយទៀត អារឿងស្តាប់ពីសភាពការណ៍នេះ ហើយវាមកផ្សព្វផ្សាយក្នុងភូមិខ្លួនឯងអ៊ីចឹង។ មានតែប៉ុណ្ណឹងទេ។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

អ៊ីចឹងទទួលព័ត៌មាន ទទួលការណែនាំពីថ្នាក់លើតាមនីរសារ ឬក៏តាមអីអ៊ំ? តាមអ្នករត់សំបុត្រ ឬក៏អ៊ំម៉េច?

**ផ៖** តាមគេហៅប្រជុំដែរ។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

គេហៅប្រជុំ?

**ផ៖** បាទ។ គេហៅតាមឃុំ គេស្រុក គេចុះទៅឃុំ។ ឃុំចុះទៅភូមិ អ៊ីចឹង។ មានតាមខ្សែរយៈ។

[១១:១៧:១៦]

**ស៖** សូមអរគុណ សំណួរ។ ឥឡូវខ្ញុំចង់ត្រឡប់មកលើពាក្យមួយដែលលោកបានប្រើអម្បាញ់មិញនេះ ពាក្យថា “ខ្មាំង” បើលោកបានផ្តល់ការចង្អុលបង្ហាញខ្លះហើយទាក់ទងខ្មាំងនេះ។ ចំពោះអង្គការមុនឆ្នាំ១៩៧៥ តើអ្នកណាដែលថាអង្គការកំណត់ថាជាសត្រូវនោះ? តើជាសត្រូវតែមួយគត់ ឬក៏វាមានប្រភេទសត្រូវច្រើន? ហើយក្នុងករណីនេះ តើលោកអាចជម្រាបយើងបានទេ តើថាអ្នកណាដែលអាចត្រូវចាត់ទុកថាជាសត្រូវនោះ សម័យនោះ?

**ផ៖** ឆ្លល់អាណាវា-- អារឿងនុ៎ងវា-- បើថាភូមិ ឃុំ វាល្អ អាហ្នឹងគេថាអត់មានសត្រូវទេ។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

អត់មានអី?

[១១:១៨:២២]

**ផ៖** អត់មានសត្រូវនៅណ៎ា។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

អត់មានសត្រូវ។

**ផ៖** បាទ។ ព្រោះអាវាមិនល្អ វាមានសត្រូវក្នុងផ្ទៃក្នុងអ៊ីចឹង។ អាហ្នឹងពេលនុ៎ង។

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

អ្នកណាទៀតដែលជា គេហៅថាសត្រូវនោះ? ក្រៅពីអ្នកធ្វើមិនបានល្អហ្នឹង មានពីណាទៀតទេ គេហៅសត្រូវ?

**ឆ៖** ហៅកម្មាភិបាលយើងដឹកនាំនោះហើយ វាសត្រូវ។ បើវាត្រឹមត្រូវ វាកើតហើយ។

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

អត់អីទេ?

**ឆ៖** អត់អីទេ។ អាហ្នឹងបើវាមិនត្រូវ វារប៉ាត់រប៉ាយទៅ។

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ត្រូវហើយ ខ្លាំងហើយ?

**ឆ៖** ខ្លាំងហើយ។ អាហ្នឹងហើយ មានត្រឹមហ្នឹង។ អាហ្នឹងយើងថាវាច្រើនខូចខាតណ៎ា វារឿងហ្នឹង។ ឧបមាអ៊ីចឹង។

[១១:១៩:១៩]

**ស៖** សូមអរគុណ អម្បាញ់មិញនេះលោកបាននិយាយថា លោកត្រូវបានដំឡើងឋានន្តរសក្តិថាចេញពីប្រធានភូមិ ទៅមេឃុំ។ បន្ទាប់ពីឡើងជាប្រធាន មេឃុំនោះ តើលោកត្រូវបានបានគេដំឡើងឋានន្តរសក្តិទៀតទេ?

**ឆ៖** ត្រឹមស្រុក បាទ។ ពីភូមិដល់ឃុំ។ ដល់ឃុំ ហើយចូលក្នុងស្រុក បាទមានប៉ុណ្ណឹង។

**ស៖** តើស្រុកនោះឈ្មោះអីទៅ? ក៏លេខស្រុកនោះ លោកចាំលេខស្រុកនុំងទេ?

**ឆ៖** ស្រុកហ្នឹង មុនហ្នឹង ពួកអានុំង បងប្អូនខ្មែរនេះដែរ ធ្វើតំណាងគណៈស្រុកនេះណាស់។ ដល់ហើយហ្នឹង ខ្ញុំឡើងទៅ-- ខ្ញុំ-- ចោលខ្ញុំទៀត អ៊ីចឹង។ ខ្ញុំហើយពីអានៅឃុំនេះណាស់--

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

គាត់សួរថា ពេលអ៊ំធ្វើនៅស្រុកហ្នឹង ស្រុកឈ្មោះអី ស្រុកនុំង?

**ឆ៖** អណ្ដូងមាស។

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ស្រុកអណ្ដូងមាស។

**ឆ៖** បាទ។

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

អត់មានលេខទេ?

**ឆ៖** អត់ទេ។

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ស្រុកអណ្ដូងមាស?

**ឆ៖** អណ្ដូងមាស។

[១១:២០:៥៣]

**ស៖** បាទ សូមអរគុណ ហើយការតែងតាំងលោកនោះ កើតឡើងតាមរបៀបណា? លោកបានជម្រាបអំមិញនេះ គឺថាធ្វើឡើងនៅក្នុងកិច្ចប្រជុំ តើគេតែងតាំងលោកជាប្រធានស្រុកអណ្ដូងមាសហ្នឹងនៅពេល-- ក្នុងពេលប្រជុំឬក៏យ៉ាងម៉េច?

**ឆ៖** ពេលប្រជុំ ហើយគេតាំង គេប្រគល់ឲ្យអាអ្នកគ្រប់គ្រងអស់នេះប៉ុន្មានឃុំនែ៎។ ឃុំប៉ុន្មាន? ភូមិប៉ុន្មាន? អ៊ីចឹង ហើយនិងបើពេលទៅយកសភាពការណ៍ពេលថ្នាក់លើ ហៅទៅឃុំ អ៊ីចឹង។ ហៅតាមឃុំៗហ្នឹង អ៊ីចឹង។

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

គាត់ចង់សួរគាត់ថា-- គាត់ចង់សួរអ៊ំថា គេចាត់តាំងអ៊ំឲ្យនៅធ្វើការនៅស្រុកហ្នឹង ពេលប្រជុំ។ ពេលប្រជុំ គេចាត់តាំងឲ្យធ្វើហ្នឹងហ្មង។

**ឆ៖** បាទ។

[១១:២២:១០]

**ស៖** នៅពេលដែលលោកត្រូវបានគេដំឡើងឋានន្តរសក្ដិជាចៅហ្វាយស្រុកនោះ អង្កាល់នុ៎ងហ្នឹងអ្នកណាអ្នកតែងតាំងឲ្យលោកក្លាយជាមេស្រុកហ្នឹង នៅពេលប្រជុំនុ៎ង?

**ឆ៖** តែងតាំងនុ៎ង វាមកពី-- តែងតាំងចុះ ទៅដល់ស្រុក មកពីខេត្តហ្នឹងហើយ វាចុះទៅស្រុកនុ៎ង។ ស្រុករួចចុះទៅតាមឃុំនុ៎ង អ៊ីចឹង។

**ស៖** បាទ, នៅពេលដែលលោកនិយាយថា ខេត្តហ្នឹង គឺថាមានន័យស្មើថាភូមិភាគ ឬក៏យ៉ាងម៉េច? ឬក៏ខុសគ្នា?

**ឆ៖** ឥឡូវខេត្ត ភូមិភាគមិនដឹងហ្នឹង មើលទៅ។ យើងឥឡូវ វាហៅខេត្ត អានុ៎ង ភូមិភាគ។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

អ៊ីចឹង សម័យហ្នឹង គេហៅភូមិភាគ អ៊ំ?

**ឆ៖** បាទ។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ឥឡូវ ខេត្ត ណាស់អ៊ំ?

**ឆ៖** ខេត្ត។

[១១:២៣:៣៨]

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

អ៊ីចឹង ពេលគាត់សួរ អ៊ំនិយាយពាក្យភូមិភាគ និយាយពីពាក្យសម័យហ្នឹងហ្នុង។

**ឆ៖** បាទ ភូមិភាគ។

**ស៖** តើលោកចាំទេ អ្នកណាជាប្រធានភូមិភាគ ឬក៏ប្រធានចៅហ្វាយខេត្តនៅសម័យហ្នឹង ដែលបានតែងតាំងលោនោះ?

**ឆ៖** កាលហ្នឹង ខ្ញុំភ្លេចដែរ ឈ្មោះ។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

គណ:ភូមិភាគអ៊ំ?

**ឆ៖** បាទ, ខ្ញុំភ្លេចហើយ ជំនាន់ហ្នឹង វានឹកអីរកមិនឃើញ។

**ស៖** បាទ, សូមអរគុណ។ បាននៅក្នុងការស្តាប់យកចម្លើយរបស់លោកនោះ យើងយោងទៅលើឯកសារនុ៎ង។ ឥឡូវ ខ្ញុំសូមសួរសំណួរពីរបីទៀត នៅក្នុងភូមិភាគព្លិសាននុ៎ង តើមានរថនាសម្ព័ន្ធយោធាដែរឬទេ? តើមានកងពលដែលឈរជើងនៅទីនោះដែរឬទេ?

[១១:២៥:០៦]

**ឆ៖** មាន។ អង្កាល់នុ៎ងមានកងពលគេ។ គេនៅតាមស្រុក តាមខេត្តហ្នឹងណ៎ា មាន។

**ស៖** តើលោកមានចាំឈ្មោះកងពលមួយ ឬក៏ច្រើនដែលឈរជើងនៅតំបន់ព្លិសានរបស់លោកហ្នឹងទេ? គឺថាអាចនិយាយជាលេខក៏បានដែរ លេខកងពលទាំងអស់ហ្នឹង។

**ឆ៖** អាហ្នឹងយើងមិនចង់ចាំដែរ។ អត់ចងចាំទេ។

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ចាំលេខ ចាំអីទេអ៊ំ? លេខកងពល លេខប៉ុន្មានៗ?

**ឆ៖** អ៊ំ! អត់ចាំទេ។ តាមលឺគេថា--

**ស៖** នៅពេលដែលតែងតាំងជាមេស្រុក តើលោកមានត្រូវបានគេដំឡើងឋានៈអីផ្សេងៗទៀតទេ ឬក៏ជាតំណែងដ៏ធំជាងគេសម្រាប់លោក?

**ឆ៖** ទេ ត្រឹមហ្នឹងហើយ។ ស្រុកៗចុះទៅឃុំ ឃុំចុះទៅភូមិ។

[១១:២៦:៣៦]

**ស៖** នៅពេលលើស្រុក លោកបាននិយាយថា លោកជាមេស្រុក តើបន្ទាប់មកលោកមានត្រូវបានគេដំឡើងឋានៈអីខាងលើទៀតទេ? ហើយប្រសិនបើត្រូវបានដំឡើង តើគេដំឡើងលោកទៅជា--ទៅកាន់ឋានៈអី?

**ឆ៖** អាហ្នឹងមុនដំបូងគេដាក់ពីបញ្ជាក្នុងភូមិ ហើយភូមិហើយបញ្ជានៅឃុំ អ៊ីចឹង។ ហើយឃុំហើយបញ្ជានៅស្រុក អ៊ីចឹង។ ហ្នឹងមានត្រឹមហ្នឹង។

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

អត់មានធ្វើអីទៀតទេ បន្ទាប់ពីទៅស្រុកហើយ អត់មានគេចាត់តាំងឲ្យធ្វើអីទៀតទេ? ធ្វើធំអីផ្សេងទៀតទេ?

**ឆ៖** ធំហើយយើងឡើង អា-- ស្អីទេវាហៅនោះ-- តំបន់។ យើងពេលអានេះវាឡើងមកតំបន់អ៊ីចឹង មើលសភាពការណ៍វាចុះ តំបន់នេះចុះទៅស្រុក ស្រុកចុះទៅឃុំ អ៊ីចឹង។ ទៅមកៗអ៊ីចឹង។ សភាពការណ៍វាមកពីនេះៗដល់នោះ មាន។

**ស៖** សូមអរគុណ។ អ៊ីចឹងលោកមិនមែនជាមេតំបន់ទេ ឬក៏លោកមានតួនាទីអីដែរនៅក្នុងតំបន់នុ៎ង?

[១១:២៨:១៩]

**ឆ៖** តួនាទីរឿង អានេះដូចវាចូលជាមួយថ្នាក់តំបន់ដែរ ពីព្រោះយកពីស្រុកនេះណ៎ា បញ្ចូលមកថ្នាក់តំបន់ហើយ គេថាគណៈកម្មាធិការដែរ អ៊ីចឹង។

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

អ៊ីចឹងចូលគណៈកម្មាធិការរបស់តំបន់ដែរ។

**ឆ៖** ហ្នឹងហើយ។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ប៉ុន្តែធ្វើនៅស្រុកទេ។

**ឆ៖** នៅៗ-- ធ្វើនៅស្រុក។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ប៉ុន្តែនៅក្នុងគណៈរបស់តំបន់។

**ឆ៖** របស់តំបន់។

**ស៖** សូមអរគុណ។ លោកគឺថានៅ ធ្វើការនៅកម្រិតថាស្រុក ហើយក្នុងខណៈហ្នឹងគឺលោកទទួលបានសេចក្តីណែនាំ ឬការបញ្ជាមួយចំនួនដែលមកពីអង្គការ។ តើលោកអាចជម្រាបយើងបានទេថាតើគោលជំហររបស់អង្គការពាក់ព័ន្ធទៅនឹងសាសនាហ្នឹងយ៉ាងម៉េចដែរ? ហើយនិងការអនុវត្តនូវការគោរព ឬក៏សក្ការបូជាទៅលើអារុក្ខអារក្សអ្នកតាអីហ្នឹង?

[១១:២៩:៣០]

**ឆ៖** អារឿងនុ៎ងខ្ញុំដូចជាយល់ខ្លះ វាមិនយល់ខ្លះទេ។ ពេល កាលពេលៗនុ៎ង វាក្រឡេចក្រឡុចដែរ។ ពេលស្រុក ពេលឃុំ ពេលភូមិ សភាពការណ៍អង្កាល់ហ្នឹង។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

គាត់ចង់សួរអ៊ំថា អ៊ំអង្កាល់នៅស្រុកហ្នឹង អ៊ំមានទទួលការណែនាំពីថ្នាក់លើ ពីបញ្ជាពីថ្នាក់លើអីទេ ទាក់ទងនឹងសាសនា ឬក៏ការគោរពអារក្សអ្នកតាហ្នឹង គេមានបញ្ជាមកឲ្យអ៊ំឲ្យផ្សព្វផ្សាយទៅប្រជាជនពីរឿងសាសនា ពីរឿងការគោរពអារក្សអ្នកតាស្អីទេកាលនៅស្រុក?

**ឆ៖** បាទ។ រឿងនេះគោរពអ្នកតាពីដើមហ្នឹង វាគោរពធ្វើដដែល វាមានទៅថាបញ្ជាចុះអ៊ីចឹងទេ។ បើជនជាតិនៅប្រើហ្នឹងរហូត ហ្នឹងហើយវាទំនៀមទម្លាប់ទេណា៎។ មិនបាច់ឲ្យគាត់ចុះទៅដឹកនាំអីដាក់ផែនការហ្នឹងទេ សហគមន៍ធ្វើខ្លួនឯង។

[១១:៣១:៣៤]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណ។ ខ្ញុំបញ្ចប់សំណួរហើយ ខ្ញុំឲ្យសហការីខ្ញុំសួរសំណួរមួយចំនួន ពាក់ព័ន្ធនឹងការជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយនិងការមកដល់នូវបុគ្គលមួយចំនួន នៅក្នុងភូមិភាគរបស់លោក។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកមានប៉ុន្មានសំណួរ ពេលវេលាចែកដូចអស់ហើយ។

**លោក ច័ន្ទ តារាស្មី៖**

ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីសួរសំណួរប្រហែលជាដប់សំណួរ ប្រសិនបើមិនយល់ទាស់ទេ។

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតទេ ពីព្រោះមានពេលវេលា ចាយពេលអស់ហើយ។ ឥឡូវចប់ត្រឹមហ្នឹងហើយ។

តទៅនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅក្រុមមេធាវីការពារក្ដី ដោយក្រុមមេធាវីការពារក្ដីនីមួយៗមានពេល២០មីនុតនៅក្នុងការសួរចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ដោយចាប់ពីក្រុមមេធាវីនួន ជា បន្ទាប់មកមេធាវី អៀង សារី ហើយនិងចុងក្រោយមេធាវីការពារក្ដី ខៀវ សំផន។

យ៉ាងម៉េចទៅលោកព្រះរាជអាជ្ញារងអន្តរជាតិ?

[១១:៣៣:០០]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ប្រសិនណាខ្ញុំសូមលើកចំណុចទូទៅទាក់ទងទៅនឹងការចែកពេលវេលានេះ ខ្ញុំគិតថានៅពេលចាប់ផ្ដើមសវនាការនេះ គឺលោកប្រធានបានថា ពេលវេលាគឺមិនបានកំណត់ច្បាស់លាស់ទេគ្រាន់តែថាដំណើរការសួរដេញដោលនេះ វាដំណើរការដូចម្ដេច។ ប៉ុន្តែវាហាក់បីដូចថា ដើមបណ្ដឹងរដ្ឋប្បវេណីនិងមេធាវីរបស់ខ្លួនបានសាកសួរនោះ។ ហើយទាក់ទងទៅនឹងការសារភាពនៅថ្ងៃទី២៨ ខែមករា ហើយដោយយោងទៅលើអ្វី គឺថា ដូច្នេះសហព្រះរាជអាជ្ញាគឺថាមានពេលប្រហែលជាមួយភាគបីនៃពេលវេលាដែលបានសាកសួរកាលពីពេលនោះ។ ហើយពេលវេលាដែលបែងចែកមកខាងសហព្រះរាជអាជ្ញានាថ្ងៃនេះ គឺខ្លីបន្តិច។ ហើយលោកប្រធានក៏បានជូនយោបល់ថា ទៅដល់ភាគីថា ទាក់ទងទៅនឹងរយៈពេលនៃការសាកសួរ ទាក់ទងទៅនឹងសាក្សីបន្តបន្ទាប់ ក៏ដូចជាដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវចូលខ្លួនមកជាបន្តបន្ទាប់។

[១១:៣៤:១៥]

លើកលែងណាដែលយើងបានដឹងថា អ្នកណាចូលមកទៅតាមលំដាប់លំដោយ ទើបយើងអាច

នឹងដឹងថាតើត្រូវចំណាយពេលប៉ុន្មាន? ត្រូវសាកសួរសាក្សីម្នាក់ៗកន្លះម៉ោង ឬក៏ត្រូវចំណាយពេលពីរម៉ោង។ ហើយប្រសិនណាជាអាចធ្វើទៅបាន ហើយប្រសិនណាលោកប្រធានអាចយល់ព្រមទៅលើសំណើសុំការប៉ាន់ប្រមាណពេលវេលាដែលយើងបានធ្វើ ការសាកសួរទៅលើឯកសារ D9/4.1 នេះមានរយៈពេលវែង។ ប៉ុន្តែបើសិនណាយើងខ្ញុំបានដឹងពេលវេលាជាមុនសម្រាប់រសៀលនេះ ក៏ដូចជាសម្រាប់សប្តាហ៍ក្រោយ គឺនោះវាអាចនឹងបង្កលក្ខណៈងាយស្រួលដល់យើងខ្ញុំដើម្បីរៀបចំពេលវេលា។

សូមអរគុណលោកប្រធាន។

[១១:៣៥:០៥]

**ប្រធានអង្គជំនុំ៖**

បាទ,អរគុណច្រើននូវការកត់សម្គាល់នេះ ហើយអង្គជម្រះសូមជម្រាបថា កាលវេលាដែលយើងបានជម្រាបជូនដោយសារ ការពិភាក្សាគ្នាលើបញ្ហានេះនៅតែជួបប្រទះការលំបាក។ ហើយអង្គជម្រះរក្សាសិទ្ធិចុងក្រោយគឺថា ពេលវេលានឹងមានការកំណត់កម្រិតកំណត់។ ដោយសារការកត់សម្គាល់នូវការសួរសំណួរកាលពីម្សិលមិញ ហើយក៏ប្រហែលគ្នានឹងព្រឹកមិញនេះ បានន័យថា សំណួរដដែលៗជាច្រើននៅក្នុងករណីខ្លះ សំណួរមិនជាប់ពាក់ព័ន្ធជាមួយនឹងខ្លឹមសារដែលបង្ហាញនៅក្នុងកថាខណ្ឌរបស់សហចៅក្រមស៊ើបអង្កេតធ្វើការចោទប្រកាន់នោះទេ។ ឧទាហរណ៍សួរថា ពីរចនាសម្ព័ន្ធសួរដល់ថាមេឃុំ ឃុំ “ក” ហ្នឹង ឈ្មោះអីខ្លះ? ឃុំ “ខ” ហ្នឹងឈ្មោះអីខ្លះ? នោះអាឈ្មោះអីខ្លះនោះ វាមិនមែនជារចនាសម្ព័ន្ធទេ។ បើអាចសួរថា កាលពេលហ្នឹងគណៈកម្មាធិការឃុំហ្នឹងមានប៉ុន្មានរូបការចាត់តាំងសម័យហ្នឹងនោះ? ភូមិហ្នឹងប៉ុន្មានរូប? ដល់ទៅសួរទាំងឈ្មោះទៅទៀត? នោះជាការចាយពេលវេលា គួរតែកម្រិតកំណត់នូវការជ្រើសរើសនូវខ្លឹមសារ ដែលវាសំខាន់នៅក្នុងការសួរ។

[១១:៣៦:២៩]

អ៊ីចឹងហើយបានជាអង្គជម្រះមិនអាចបណ្តែតបណ្តោយសភាពការណ៍នេះបានទេ។ ទីពីរ បញ្ហាដែលយើងបានប្រឹងប្រែងនេះ ដោយសារមូលហេតុនៅរសៀលនេះ បញ្ហាការរៀបចំធ្វើការសួរសាក្សី 395 ត្រូវធ្វើតាមប្រព័ន្ធសោតទស្សន៍ ដែលស្ថានភាពនៃបញ្ហាសុខភាពរបស់គាត់កំពុងតែប្រឈមខ្លាំងហើយស្ថានភាពមិនអំណោយផលឱ្យអង្គជម្រះពន្យារពេលលើបញ្ហានេះបានទេ។ នេះហើយដែលធ្វើឱ្យមានការប្រែប្រួល។ បញ្ហាមួយទៀត យើងគ្រោងហើយលើបញ្ហាពេលវេលា យើងសួរជនជាប់ចោទគាត់មិនអាចដំណើរការបាន សួរតែមួយរយៈពេលគាត់សុំមិនឆ្លើយទៀត ដោយសារបញ្ហាសុខភាព

ដោយសារគាត់ចាស់គាត់លទ្ធភាពឆ្លើយតែប៉ុណ្ណឹង។ យើងបង្ខំយកឲ្យគាត់ឆ្លើយ ជាការអសីលធម៌ គ្មានសីលធម៌ ជាកំហុសមួយការបង្ខំយកចម្លើយរបៀបនេះ។

តែបើសិនយើងកំណត់ថា ឥឡូវពេលមួយអាទិត្យនេះយើងសួរជនជាប់ចោទ យើងសួរអត់បានទេ។ ពេលវេលាត្រូវទំនេរចោល។ នេះជាបញ្ហាប្រឈម ហើយអង្គជម្រះរំពឹងប្រមើលមើលថា ការសិក្សាបទពិសោធន៍ពីមួយថ្ងៃទៅមួយថ្ងៃនេះ នៅសប្ដាហ៍ក្រោយ ឬក៏ចូលមកវិញនៅក្នុងអំឡុងដើមខែមករា ទំនងជាអង្គជម្រះនឹងមានមូលដ្ឋានក្នុងការគិតគូរថាតើកម្រិតកំណត់របៀបណា ដើម្បីឲ្យដំណើរការគ្រប់គ្រងតុលាការនេះ មានប្រសិទ្ធភាពជាងនេះ។

ប៉ុន្តែចំពោះមុខនេះ គឺត្រូវមានពេលវេលាកម្រិតកំណត់ នេះគឺយើងខ្ញុំបានប្រើពាក្យមួយនៅភាពបត់បែននៅក្នុងការគ្រប់កិច្ចដំណើរការសវនាការ។ តែទោះបីយ៉ាងណា អង្គជំនុំជម្រះអរគុណនូវការកត់សម្គាល់របស់សហព្រះរាជអាជ្ញារងអន្តរជាតិ។

[១១:៤០:៥២]

ពេលវេលាអត់រង់ចាំយើងទេ ដោយសារយើងមានបញ្ហាជាច្រើន ដែលខុសពីផែនការដែលបានប្រមើលមើល និងគ្រោងទុកសម្រាប់សួរដេញដោល។ ឥឡូវនេះ ដើម្បីច្បាស់លាស់ ពីព្រោះពេលវេលាដូចជាអស់ហើយសម្រាប់មេធាវីការពារក្ដី។ ដូច្នេះទេ អង្គជំនុំជម្រះសួរទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សួរថាតើនៅសប្ដាហ៍ក្រោយអាចនាំគាត់អាចមកលោក រម៉ាម យុន នេះមកកាន់សវនាការបានទៀតដែរឬទេ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន! ចំពោះលទ្ធភាពសម្រាប់សប្ដាហ៍ក្រោយខាងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីយល់ថា មិនចោទជាបញ្ហាទេ អាស្រ័យទៅលើការរៀបចំរបស់តុលាការ លទ្ធភាពរបស់តុលាការខាងតុលាការនៅក្នុងការរៀបចំ ដើម្បីឲ្យគាត់ត្រឡប់មកវិញ។ អ៊ីចឹង មិនចោទជាបញ្ហាទេចំពោះបញ្ហានេះ។

[១១:៤២:២៩]

**ប្រធានអង្គជំនុំ៖**

អរគុណ នូវការផ្ដល់នូវព័ត៌មាននេះ ហើយដោយសារពេលវេលាខ្លី ហើយអម្បាញ់មិញនេះ មានការតវ៉ាពីខាងសហព្រះរាជអាជ្ញាដែលមានការប៉ុនប៉ងសួរសំណួរផ្សេងទៀត។ ហើយឥឡូវនេះ យើង

មានពេល ដោយសារយើងអាចបញ្ចប់ក្នុងការសួរគាត់នៅពេល នៅសម្រាប់ព្រឹកនេះ។ ដូច្នេះ អង្គជំនុំជម្រះប្រគល់វេទិកាទៅឲ្យសហព្រះរាជអាជ្ញា ដើម្បីបន្តសំណួរសួរដល់គាត់អាច១៥នាទី។

សូមអញ្ជើញ!

**សួរដោយលោក ច័ន្ទ តារាស្មី៖**

អរគុណលោកប្រធានចំពោះការអនុញ្ញាតឲ្យខ្ញុំបាទបានសួរសំណួរទៅលោក រម៉ាម យុន នេះ។

**ស៖** សូមជម្រាបសួរលោកអ៊ំ រម៉ាម យុន ខ្ញុំសូមអនុញ្ញាតសួរសំណួរបន្តទៅទៀត។ សំណួរនេះទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ សូមលោកអ៊ំមេត្តាបញ្ជាក់អំពី កាលពីមុនឆ្នាំ១៩៧៥ មានន័យថា មុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ តើអ៊ំបានទទួលដំណឹងអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរឬទេ?

[១១:៤៣:៥០]

**ឆ៖** កាលហ្នឹងយើងឃើញមុខហើយក៏មិនឃើញ ឮបញ្ជាក់អ៊ីចឹងទៅណា ឮគេថាជម្លៀសមកពីភ្នំពេញអីហ្នឹងណា ប៉ុន្តែយើងកាលហ្នឹងជាក់ស្តែងអត់ទេ ប៉ុន្តែគ្រាន់តែឮដំណឹង។ ឮមែន។

**ស៖** អ៊ំឮតាមរយៈអ្វី? គេប្រាប់ ឬក៏អ៊ំឮតាមរយៈវិទ្យុទូរទស្សន៍ផ្សាយ ឬក៏មានប្រជាជន ឬក៏មានបុគ្គលណាជម្រាបអ៊ំដោយផ្ទាល់ ឬក៏អ៊ំឮតៗគ្នា?

**ឆ៖** ឮតៗគ្នា ឮមកពីខេត្ត មកពីស្រុក។ ឮតៗ មិនឃើញជាក់ស្តែងនឹងភ្នែកខ្លួនឯង អត់។ ឮដំណឹងអ៊ីចឹង។

**ស៖** តើអ៊ំអាចបញ្ជាក់បានច្បាស់ទេថា នរណាគេដែលជម្រាបអ៊ំហ្នឹង ឈ្មោះបុគ្គលដែលជម្រាបហ្នឹងគេ ដែលប្រាប់អំពីការជម្លៀសហ្នឹង? ឈ្មោះនរណាគេអ៊ំអាចចាំបានទេ?

[១១:៤៥:០៥]

**ឆ៖** អត់ចាំទេ។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ឆ្លើយម្តងទៀត។

**ឆ៖** អត់ចាំ។

**ស៖** អរគុណអ៊ំ។ តើមានចំនួនប្រជាជនប៉ុន្មាននាក់ ដែលត្រូវបានជម្លៀសពីក្រុងភ្នំពេញចូលទៅរស់នៅក្នុងតំបន់ដែលអ៊ំគ្រប់គ្រងផ្ទាល់? ពោល គឺនៅក្នុងឃុំដែលអ៊ំគ្រប់គ្រងផ្ទាល់។

**ឆ៖** ខ្ញុំអត់ចាំ អត់ច្បាស់រឿង-- មែនទែនមិនមករាយការណ៍ឲ្យយើងណា៎ ចេះតែឮតាមគេថាណា៎។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកព្រះរាជអាជ្ញាចង់សួរអ៊ំថា ប្រជាជនដែលគេជម្លៀសពីភ្នំពេញ យកពីភ្នំពេញហ្នឹងទៅនៅក្នុងឃុំអ៊ំប៉ុន្មាននាក់? មានគេយកទៅឃុំអ៊ំ ទៅនៅភូមិអ៊ំទេ?

**ឆ៖** អត់មានទេ។

**ស៖** អរគុណអ៊ំ។ អ៊ំអាចបញ្ជាក់បានទេថា មូលហេតុអ្វីបានជាមានការជម្លៀសប្រជាជន មានការផ្លាស់ទីប្រជាជនពីកន្លែងមួយទៅកន្លែងមួយទៀត អ៊ំអាចដឹងពីមូលហេតុហ្នឹងទេ? ហើយបើដឹងតើនរណាគេប្រាប់អ៊ំពីមូលហេតុហ្នឹង?

**ឆ៖** រឿងហ្នឹង វា ពីភូមិនេះទៅភូមិនោះ យើងនេះឮពីគេដែរ។ គេថា ដូចថាភូមិហ្នឹង ភូមិក្បែរគ្នាហ្នឹងណា៎។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ភូមិអី?

**ឆ៖** ឧបមាណា៎។ ប៉ុន្តែយើងមិនឃើញជាក់ស្តែងដែរ។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ភូមិហ្នឹងម៉េចគ្នា? ហេតុអីបានជាគេឲ្យផ្លាស់ពីភូមិមួយទៅភូមិមួយ?

[១១:៤៦:៤៦]

**ឆ៖** ឧបមាអ៊ីចេះ ឮភូមិផ្សេងដូចខ្ញុំជួបអ៊ីចឹង។ ខ្ញុំសួរឮ ហើយឮសួរខ្ញុំហ្នឹងណា មានតែហ្នឹងទៅឃើញជាក់ស្តែងនឹងភ្នែក ថាអត់ឃើញដែរ។ អត់មានភស្តុតាងទេ។ ឮបញ្ជាក់នឹងភ្នែក ក៏មិនឃើញ។

**ស៖** អ៊ំដែលឮគេនិយាយប្រាប់ថា មូលហេតុអ្វីបានជាមានការជម្លៀសប្រជាជន ការផ្លាស់ទីប្រជាជនដូច្នេះទេហ៎? មានអ្នកណានិយាយប្រាប់ទេកន្លងមកនុ៎ង?

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ឆ្លើយអ៊ំៗ។ បានដឹងទេអ៊ំមូលហេតុដែលគេឲ្យផ្លាស់ទីពីភូមិមួយទៅភូមិមួយហ្នឹង មានដឹងថាគេមកពីហេតុអីទេ?

**ឆ៖** វាឆ្ងល់ វាអត់ហ្នឹងហើយវាឆ្ងល់។

**ស៖** អរគុណអ៊ំខ្ញុំសូមសួរបន្តទៀត។ នៅពេលដែលមានប្រជាជនទីក្រុងភ្នំពេញផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយ ឬក៏ប្រជាជនផ្លាស់ទីពីកន្លែងមួយទៅរស់នៅក្នុងតំបន់របស់អ៊ំ។ តើអ៊ំសង្កេតឃើញកាលសម័យនោះ ការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងសម័យនុ៎ង ទាក់ទិននឹងការរស់នៅ ក៏ដូចជាការធ្វើស្រែចម្ការ អ៊ំយល់ឃើញយ៉ាងម៉េចដែរនៅក្នុងសម័យនោះ?

[១១:៤៨:០៧]

**លោក ម៉ៃខល កាណាវាស៖**

សូមអភ័យទោសលោកប្រធាន! អង្គហេតុនេះ គឺមិនបានចេញមកពីមាត់របស់សាក្សីដោយផ្ទាល់នោះទេ គឺការដែលខ្ញុំរំខាននេះ គឺខ្ញុំចង់ឲ្យគាត់បញ្ជាក់តែអ្វីដែលគាត់បានឮទេ។ ឥឡូវនេះ សហព្រះរាជអាជ្ញាបានប្រើពាក្យពេចន៍នាំមុខជូនទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ ដូច្នេះហើយ ការអនុញ្ញាត ពេល ១៥នាទីនេះ គឺមិនត្រូវណាយកសក្ខីកម្មដោយការនាំមុខបែបនេះទេ។

**សួរដោយលោក ច័ន្ទ តារាស្នី៖**

អរគុណលោកប្រធាន ខ្ញុំសូមអនុញ្ញាតបន្ត។

**ស៖** លោកអ៊ំ សូមលោកអ៊ំបញ្ជាក់អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមុនឆ្នាំ ១៩៧៥។ តើអ៊ំបានដឹងឮថា នៅពេលនោះបក្សកុម្មុយនីស្តកម្ពុជា ក៏ដូចជាកម្ពុជាប្រជាធិបតេយ្យក្នុងសម័យកាលនោះ គេបានណែនាំ គេបានដាក់ចេញសេចក្ដីសម្រេច គេបានប្រាប់ទៅអ៊ំឲ្យធ្វើកិច្ចការអ្វីខ្លះ? ហើយមិនឲ្យធ្វើកិច្ចការអ្វីខ្លះនៅក្នុងភូមិភាគ ឬក៏តំបន់ ឬក៏ភូមិឃុំដែលអ៊ំគ្រប់គ្រងផ្ទាល់នោះ? មានន័យថា ផែនការសេចក្ដីសម្រេច ឬក៏ការណែនាំពីថ្នាក់លើមកអ៊ំហ្នឹង តើនៅក្នុងតំបន់ដែលអ៊ំគ្រប់គ្រងហ្នឹង គេហាមមិនឲ្យអ៊ំធ្វើអ្វី? ឬក៏គេអនុញ្ញាតឲ្យអ៊ំធ្វើអ្វី?

[១១:៤៩:៥០]

**ឆ៖** អស់ទេ។ កាលហ្នឹង ខ្ញុំធ្វើការនៅក្នុងឃុំ ហើយធ្វើការក្នុងឃុំនោះ ធ្វើក្នុងស្រុក។ ធ្វើក្នុងស្រុកណោះ កាលនុ៎ងមិនដឹងយ៉ាងម៉េច គេថាខ្ញុំនេះបក្សអីៗ គេថាហៅខ្ញុំក៏មិនដឹងខ្ញុំថាបក្សអីទេ។ បក្សកម្ពុជា ប៉ុន្តែមិនដឹងគេវិថ្ឋយ ថាខ្ញុំនេះ បក្សអីៗ។ អ៊ីចឹងគេបានចាប់ខ្ញុំទៅដាក់ភ្នំពេញនេះដែរ អ៊ីចឹង។

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ប៉ុន្តែចង់និយាយថា មុន៧៥ ហ្នឹង ខាងបដិវត្តន៍ហ្នឹង គេប្រាប់ប្រជាជន ហើយនិងអ៊ំហ្នឹងឲ្យធ្វើ

អីខ្លះ? ហើយគេមិនឲ្យយើងមិនធ្វើអីខ្លះ កាលនោះអ៊ំ?

**ឆ៖** បាទ, កាលនុ៎ង ព្រោះផែនការ ដូចដែលថារឿងចាត់ចែងក្នុងភូមិ ក្នុងឃុំ ប្រាប់យើងធ្វើ។

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

គេឲ្យធ្វើអីអ៊ំ? ឲ្យធ្វើអី?

**ឆ៖** ធ្វើអាគណៈកម្មាធិការភូមិ។ ហើយយើងនៅធ្វើក្នុងឃុំ។ បើនិយាយទៅ ជួនកាលការងារគេក្នុងស្រុក វាច្រើនពេក វាខ្វះមនុស្សទៅជួយមួយរយៈ អ៊ីចឹង។ មានប៉ុណ្ណឹង។

[១១:៥១:៤៦]

**ស៖** អរគុណអ៊ំ ខ្ញុំសូមសួរបន្តទៀត។ ទាក់ទិននឹងការរៀបអាពាហ៍ពិពាហ៍របស់ប្រជាពលរដ្ឋនៅក្នុងសម័យកាលនោះ នៅក្នុងតំបន់ដែលអ៊ំគ្រប់គ្រង តើការរៀបចំអាពាហ៍ពិពាហ៍ ការរៀបការប្ដីប្រពន្ធនៅសម័យនុ៎ងដូចម្ដេចដែរអ៊ំ?

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ការប្ដីប្រពន្ធ។

**ឆ៖** កាលនុ៎ងអត់ការទេ។ កាលជំនាន់នោះ។

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ធ្វើម៉េច?

**ឆ៖** ពេលវាត្រូវការគ្នា អានេះវាត្រូវ អានេះត្រូវ ក៏វាយកគ្នាទៅ។ វាអត់ការ។

[១១:៥២:២២]

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

សម័យបដិវត្តន៍នោះ?

**ឆ៖** ហ្នឹងហើយ។ អាជំនាន់អា ពត នោះណា៎។

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

មុនហ្នឹង?

**ឆ៖** មុននោះការ។ ការមុន ពេលដល់សង្គមចាស់ៗ ពីដើម ដល់ខ្មែរនេះ អាសង្គមនុ៎ង អា ពត វាអត់បានការទេ។

**លោក ច័ន្ទ តារាស្រី៖**

លោកប្រធានដោយសារតែពេលវេលាមិនអំណោយផល ខ្ញុំសូមអនុញ្ញាតបញ្ចប់ការសួររបស់ខ្ញុំតែប៉ុណ្ណឹង។ បាទ សូមអរគុណ។

[១១:៥៣:៤៨]

**ប្រធានអង្គជំនុំ៖**

អរគុណលោកសហព្រះរាជអាជ្ញា ហើយអំមិញដល់ ត្រូវដល់មេធាវីការពារក្តីហើយ ហើយឥឡូវនេះមានបន្តិចបន្តួចប៉ុណ្ណោះ។ អង្គជំនុំជម្រះចង់ដឹងពីខាងមេធាវីការពារក្តីវិញ ថាតើខ្លួនហ្នឹងមានគោលបំណងក្នុងការសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីនេះដែរឬទេ?

**លោក សុន អរុណ៖**

សូមគោរពលោកប្រធាន ខ្ញុំ ខ្លួនខ្ញុំៗមេធាវីការពារលោក នួន ជា បូកទាំងអស់ ទាំងមេធាវីអន្តរជាតិ និងខ្ញុំមានប្រហែលជាកន្លះម៉ោង។ ប៉ុន្តែខ្ញុំជឿថាពេលវេលាមិនអនុញ្ញាតឲ្យទេ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ចុះមេធាវីដទៃទៀត?

[១១:៥៥:០០]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធានសូមគោរព។ យើងខ្ញុំក៏មានសំណួរត្រូវដែរ អាស្រ័យថាតើក្រុមដទៃទៀតត្រូវការពេលប៉ុន្មាននោះ? សម្រាប់ក្រុមខ្ញុំប្រហែលជាត្រូវការពេលវេលា២០នាទី អាចលើស ឬក៏តិចជាងនេះបន្តិចបន្តួច។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ចុះរបស់មេធាវីការពារ ខៀវ សំផន?

**លោក គង់ សំអុន៖**

សូមជម្រាបលោកប្រធាន ខាងយើងមានសំណួរតិចតួចដែរ ប្រហែលជាចំណាយពេលខ្ទង់២០នាទី អ៊ីចឹងដែរ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណច្រើន។

ឥឡូវនេះ ដោយសារពេលវេលាមិនអំណោយផលនៅក្នុងការស្ដាប់នូវសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី រម៉ាម យុន ដោយហេតុនៅរសៀលនេះ អង្គជំនុំជម្រះត្រូវធ្វើសវនាការសាក្សីដែលបានជម្រាបជូនរួចហើយ។ ដូច្នេះ អង្គជំនុំជម្រះអរគុណចំពោះលោក រម៉ាម យុន ដែលបានខឹតខំប្រឹងប្រែងឆ្លើយផ្ដល់សក្ខីកម្មទៅតាមសំណួររបស់ភាគីដែលពាក់ព័ន្ធ និងបានសួរលោក ប៉ុន្តែដោយសារថ្ងៃនេះ អង្គជំនុំជម្រះមិនអាចបន្តការសួរសំណួរចំពោះលោក អ៊ីចឹងលោកត្រូវអញ្ជើញមកកាន់តុលាការនេះម្ដងទៀតនៅក្នុងសប្ដាហ៍ក្រោយ។ ចំពោះពេលវេលា គឺអង្គជំនុំជម្រះនឹងជម្រាបជូនលោកតាមរយៈអង្គភាពដែលពាក់ព័ន្ធដើម្បីលោកបានជ្រាប។

លោក ស្មីត!

[១១:៥៧:១២]

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ដោយសារលោកប្រធានឲ្យសហព្រះរាជអាជ្ញា ទាក់ទងនឹងសាក្សី 395 នេះ គឺខ្ញុំសូមសួរលោកប្រធាន ថាតើអាចមានត្រូវសាកសួរសាក្សីណាផ្សេងទៀត ឬជនជាប់ចោទ ឬក៏ត្រូវសួរទៅលើសាក្សី315 នេះ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានជម្រាបហើយ បញ្ហាដែលយើងមានផែនការនេះ គឺចាប់ពីរសៀលនេះទៅ និងថ្ងៃស្អែក ហើយទំនងជាអាចរហូតដល់ថ្ងៃសុក្រផង ក្នុងការសួរសាក្សី395 នេះ។ ប៉ុន្តែបញ្ហានេះក៏យើងគ្រោងផងដែរ ថាអាចមានការប្រែប្រួលប្រសិនបើបញ្ហាបច្ចេកទេស ឬក៏បញ្ហាសុខភាពរបស់គាត់ហ្នឹងមានអាចប្រែប្រួលនៅក្នុងអំឡុងពេលនេះ ដោយអង្គជំនុំជម្រះ គឺខឹងខំប្រឹងប្រែងដើម្បីជំរុញនូវលទ្ធភាពក្នុងការសវនាការ មិនទុកពេលទំនេរទេ។

[១១:៥៨:២៥]

អ៊ីចឹង បញ្ហាទៅមុខទៀតហ្នឹង គឺអាចមានការពាក់ព័ន្ធជាមួយនឹងជនជាប់ចោទ ឬក៏សាក្សីមកជំនួស ដែលអង្គជំនុំជម្រះបានត្រៀមរួចហើយ។ អ៊ីចឹង បញ្ហាដែលដំបូងៗនេះ គឺអង្គជំនុំជម្រះក៏បានប្រមើលមើលពីបញ្ហាប្រឈមផ្សេងៗដែលក្នុងការរៀបចំកាលវិភាគនៃកិច្ចដំណើរការសវនាការ។

ដោយសារមូលហេតុនៃបញ្ហា ជាពិសេស គឺសុខភាពរបស់អ្នកដែលពាក់ព័ន្ធក្នុងការជាគោលដៅនៃការសួរ ដូចជាភាគី និងសាធារណជនបានឃើញជាក់ស្តែងនឹងភ្នែកហើយ គឺសុទ្ធតែមានវ័យចាស់។ ដូច្នេះ គឺនឹងអាចមានការប្រែប្រួល ប៉ុន្តែការផែនការ គឺអង្គជំនុំជម្រះបានជម្រាបហើយ ពីព្រោះខាងបច្ចេកទេសបានបញ្ជូនទៅដល់គោលដៅលំនៅដ្ឋាននៃគោលដៅហើយ ហើយបានរៀបចំរួចហើយ អ៊ីចឹងហើយបានជាកិច្ចប្រឹងប្រែងរបស់អង្គជំនុំជម្រះ គឺចាប់ផ្តើមធ្វើនៅរសៀលនេះ រហូតដល់ស្អែក ឬក៏ក្នុងករណីចាំបាច់គឺរហូតដល់ថ្ងៃសុក្រទៀត ដោយសារសារៈសំខាន់នៃសាក្សី។

[១១:៥៩:២៧]

ហើយបញ្ហាសុខភាព ប្រសិនបើយើងសួរទៅមានការហត់ ការអីៗអ៊ីចឹង ក៏ដូចគ្នានឹងជនជាប់ចោទ ឬក៏សាក្សីដទៃដែលដើមបណ្តឹងរដ្ឋប្បវេណីដែលមានវ័យចាស់ ដូចដែលបានយើងឃើញពីព្រឹកមិញអ៊ីចឹង។

អ៊ីចឹង សូមមានការប្រុងប្រៀបត្រៀមនូវគោលដៅដែលត្រូវសួរ ដែលយើងបានរៀបចំផែនការសម្រាប់ពីថ្ងៃ៥ រហូតដល់ថ្ងៃ១៦។ អាហ្នឹង គឺត្រៀមទាំងអស់គ្នា គ្រប់ភាគី។

[១២:០០:០០]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំក៏សូមសួរថាតើលោកប្រធាន ទទួលយកសំណើសុំរបស់សហព្រះរាជអាជ្ញាដែលបានដាក់ពាក្យព្រឹកមិញនេះ ថាដោយសារវ័យចាស់ជរា និងស្ថានភាពសុខភាពរបស់សាក្សី 395 ដោយពិនិត្យទៅលើចម្លើយរបស់គាត់ទាំងមូលតែម្តងទាក់ទងទៅនឹងដីកាបញ្ជូនរឿងឲ្យជំនុំជម្រះ។ ហើយសហព្រះរាជអាជ្ញាបានដាក់សំណើសុំ ដោយយោងទៅលើមូលដ្ឋាននេះ ហើយយើងទើបតែទទួលបានព័ត៌មានខ្លីៗនេះទេ។ ហើយដូចដែលលោកប្រធានបានជម្រាបមកហើយថា ការសាកសួរគឺវាអាស្រ័យទៅលើកាលៈទេសៈនិងពេលវេលាជាក់ស្តែង។ ដូច្នេះ ការសាកសួរសាក្សីនេះ បើសិនណាជាស្ថានភាពរបស់គាត់មិនអំណោយផល គឺថាត្រូវពិចារណាចំណុចនេះ។ សូមអរគុណ។

[១២:០០:៥៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក អេនគ្រូ អ៊ីន្នូហ្ស៊ី៖**

ជម្រាបសួរលោកប្រធាន តើលោក រម៉ាម យុន ឬក៏ ក្លាន វិត ឬក៏ នួន ជា? ខ្ញុំនិយាយអំពីផែនការ “ខ”។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

មិនទាន់មានផែនការ “ខ” នៅឡើយទេ។ តុលាការគឺថា ត្រូវមានលក្ខណៈបត់បែនពេលវេលាបន្តិច។ ដូច្នេះ មេធាវីការពារក្តីត្រូវតែត្រៀមលក្ខណៈរបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងពេលវេលា។

**លោក អេនគ្រូ អ៊ីន្នូហ្ស៊ី៖**

សូមអរគុណលោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

សូមជម្រាបជូនព្រះរាជអាជ្ញារងថា ខ្ញុំជាប្រធានអង្គជំនុំជម្រះដូចជា ពេលដែលឈប់សម្រាក ហើយពេលចូលមកវិញ គឺបានជម្រាបជូនដំណឹងច្បាស់លាស់អំពីការអនុញ្ញាតឱ្យសួរសាក្សី TCW-395 នេះ នៅចំពោះអង្គហេតុដែលបានចោទប្រកាន់ទាំងមូលក្នុងដីកាដំណោះស្រាយ។ បើមិនច្បាស់មើលប្រតិចារឹកប្រហែលជាច្បាស់លាស់ហើយ។

[១២:០២:៣៦]

ឥឡូវបញ្ហាមិនចេះចប់។ ឥឡូវនេះ អង្គជំនុំជម្រះបន្ថែមបន្តិចទៀតដោយសារ បញ្ហាមិនច្បាស់លាស់រវាងការស្តាប់សាក្សីនៅវសៀលនេះ។ ដូចខ្ញុំបានជម្រាបជូនអ៊ីចឹង ដោយសារបញ្ហាសុខភាព និងបច្ចេកទេសនៃប្រព័ន្ធសោតទស្សន៍ដែលយើងធ្វើហ្នឹងគឺមានបញ្ហាលំបាក ដោយសារយើងបានសាកល្បងម្តងពីរដងហើយ ប៉ុន្តែនៅតែមិនប្រាកដប្រជាថា ជាក់លាក់ដំណើរការបានល្អ។ ដូច្នេះ ដើម្បីជាការត្រៀមលក្ខណៈសម្បត្តិសម្រាប់សវនាការរសៀលនេះឱ្យបានប្រព្រឹត្តទៅដោយមិនខាតពេលនោះ អង្គជំនុំជម្រះតម្រូវលោក រម៉ាម យុន មានវត្តមាននៅក្នុងរសៀលនេះ នៅ អ.វ.ត.ក យើងដើម្បីត្រៀមលក្ខណៈថាប្រសិនបើយើងមិនអាចធ្វើបានចំពោះសាក្សី 395 ទេ យើងអាចបន្តលោក រម៉ាម យុន ឱ្យបានចប់ទៅដើម្បីអាចឱ្យគាត់មានលទ្ធភាពត្រឡប់ទៅលំនៅដ្ឋានរបស់គាត់បាន មិនត្រឡប់មកវិញផង។

[១២:០៣:៥០]

សូមខាងភាគីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជ្រាប ហើយឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់។ ដោយសម្រេចសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយ និងសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ។ ហើយសូមអញ្ជើញភាគី និងសាធារណជនត្រឡប់មកវិញឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី ជាកំណត់។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរ បន្ទប់រង់ចាំក្រោមសាលសវនាការនេះ ហើយបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់សាលសវនាការនូវរសៀលនេះឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី ជាកំណត់។

អញ្ជើញសម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោយឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៤ នាទី ដល់ម៉ោង ១៣:៣៨ នាទី)*

[១៣:៣៨:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមផែនការដែលបានជម្រាបជូនភាគីកាលពីព្រឹកមិញគឺនៅរសៀលនេះ ហើយនិងនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងស្តាប់នូវសក្ខីកម្មរបស់សាក្សីមួយរូប គឺឈ្មោះ ឡុង នរិន្ទ។

ហើយមុននឹងស្តាប់នូវសក្ខីកម្ម អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគី និងសាធារណជនឲ្យបានជ្រាបថា អំពីកិច្ចដំណើរការនីតិវិធីក្នុងការស្តាប់សក្ខីកម្មសាក្សីរូបនេះ គឺថាដោយសារសាក្សីរូបនេះជាមនុស្សមានវ័យចាស់ជរា និងកំពុងមានបញ្ហាសុខភាពផង ហើយម្យ៉ាងទៀតការស្តាប់សក្ខីកម្មរូបនេះត្រូវធ្វើតាមរយៈមធ្យោបាយឧបករណ៍សោតទស្សន៍ពីកន្លែងដែលគាត់ស្នាក់នៅ មកទីនេះ។ ដូច្នេះ វាមានការរអាក់រអួលខ្លះនៅក្នុងអំឡុងពេលនៃការធ្វើសវនាការដេញដោល ដោយបណ្តាលមកពីឧបករណ៍សោត-ទស្សន៍ ឬក៏អាចបញ្ហាសុខភាពផ្ទាល់ខ្លួនរបស់ជនជាប់ចោទ។

[១៣:៤០:០៣]

ហើយដើម្បីជាការសម្របសម្រួលនៅក្នុងកិច្ចដំណើរការ ខាងអង្គភាពគាំពារសាក្សី អ្នកជំនាញ និងខាងបច្ចេកទេសសោតទស្សន៍នៃ អ.វ.ត.ក បានចាត់តាំងមន្ត្រីមួយចំនួនទៅកាន់ទីនោះ ដើម្បីរៀបចំសម្របសម្រួលធ្វើកិច្ចការនេះឲ្យបានល្អ។

មួយទៀត គឺដោយសារមូលហេតុបច្ចេកទេសសោតទស្សន៍ ដោយសារតំបន់នៅដាច់ឆ្ងាយ ដាច់ស្រយាលពីទីប្រជុំជន ដែលជាហេតុធ្វើឲ្យការបកប្រែភាសាមិនអាចធ្វើការបកបណ្ដោញដូចដែលយើងធ្លាប់ធ្វើនៅទីនេះបានទេ។ ដូច្នេះការបកប្រែត្រូវធ្វើតាមរយៈនៃការបកបណ្ដាក់ ហើយដោយសារការបកប្រែបណ្ដាក់នេះ គឺអាចមានបញ្ហា។ ដូច្នេះ ភាគីដែលមានការពាក់ព័ន្ធក្នុងការអនុវត្តនូវសិទ្ធិរបស់ខ្លួនក្នុងការសួរដេញដោលសាក្សី សូមខិតខំនៅក្នុងការរៀបចំធ្វើយ៉ាងណាឲ្យមានការសម្របសម្រួលរវាងការសួរ និងការឆ្លើយនេះឲ្យបានល្អទាំងការឆ្លើយ ទាំងការបកប្រែបានពេញលេញ។

ហើយបញ្ហានេះអង្គជំនុំជម្រះនឹងជម្រាបជូនទៅដល់សាក្សីដែលត្រូវឆ្លើយ។

[១៣:៤១:៥៣]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ជម្រាបសួរលោក ឡុង នរិន្ទ។ លោក ឡុង នរិន្ទ ឮទេ? ជម្រាបសួរលោក ឡុង នរិន្ទ។

**លោក ឡុង នរិន្ទ៖**

**ឆ៖** បាទ ជម្រាបសួរ។

**ស៖** ជម្រាបសួរអ៊ំ ឡុង នរិន្ទ ឮទេ? ឮទេ ឮខ្ញុំនិយាយទេ ឡុង នរិន្ទ? លោក ញ៉ែម សំណាង អ៊ីចឹងអីនៅជាប់នឹង ឡុង នរិន្ទ។ លោកឈ្មោះ ញ៉ែម សំណាង?

**លោក ញ៉ែម សំណាង៖**

បាទ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកជាបុគ្គលិកគាំពារសាក្សី-- អង្គភាពគាំពារសាក្សី និងអ្នកជំនាញនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមែនទេ?

**លោក ញ៉ែម សំណាង៖**

បាទ, លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ហើយនៅក្នុងការរៀបចំទំនាក់ទំនងនៃការធ្វើសវនាការស្តាប់សក្ខីកម្មពីចម្ងាយហ្នឹង តើលោកមានបុគ្គលិកភ្នាក់ងារដែលទៅពី អ.វ.ត.ក ប៉ុន្មាននាក់ដែរ?

**លោក ញ៉ែម សំណាង៖**

មានចំនួនបួននាក់ លោកប្រធាន! ហើយនៅក្នុងបន្ទប់ផ្តល់សោតទស្សន៍នេះ គឺមានតែខ្ញុំពីរនាក់ និងសាក្សី TCW-395 លោកប្រធាន។

[១៣:៤៣:៥០]

**ប្រធានអង្គជំនុំ៖**

**ស៖** លោក ឡុង នរិន្ទ តើលោកឈ្មោះ ឡុង នរិន្ទ អ៊ីចឹងមែនទេ?

**ឆ៖** សួរថាម៉េចមិញហ្នឹង?

**លោក ញ៉ែម សំណាង៖**

សួរថាតើអ៊ំឈ្មោះ ឡុង នរិន្ទ មែនទេ?

**ឆ៖** ខ្ញុំឈ្មោះ ឡុង នរិន្ទ មែនហើយ។

**ស៖** បាទ អរគុណ។ តើលោកអ៊ំមានឈ្មោះហៅក្រៅដែរទេ ហៅក្រៅផ្សេងពី ឡុង នរិន្ទ ទេ?

**ឆ៖** ឈ្មោះក្រៅ គេហៅ រិទ្ធ។

**ស៖** បាទ អរគុណ! ហើយលោកមានអាយុប៉ុន្មានឆ្នាំហើយឆ្នាំនេះ?

**លោក ញ៉ែម សំណាង៖**

អ៊ំមានអាយុប៉ុន្មានឆ្នាំហើយឆ្នាំនេះ?

**ឆ៖** អាយុចិតសិបប៉ុន្មានទេ ចាំមើលខ្ញុំធ្វើលេខសិន។ ខ្ញុំកើតឆ្នាំ១៩៣៨។ គិតទៅនេះប៉ុន្មានឆ្នាំ? ៧០។

[១៣:៤៥:០៩]

**ស៖** បាទ, អរគុណអ៊ំ។ ឲ្យតែដឹងឆ្នាំកំណើតហ្នឹងល្អជាងអាយុទៅទៀត។ ហើយអ៊ំសព្វថ្ងៃហ្នឹងរស់នៅទីកន្លែងណា?

**ឆ៖** សព្វថ្ងៃរស់នៅភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ក្នុងខេត្តបន្ទាយមានជ័យ។

**ស៖** បាទ, អរគុណ។ ហើយ អ៊ំប្រកបមុខរបររកស៊ីធ្វើអ្វីដែរសព្វថ្ងៃ?

**ឆ៖** សព្វថ្ងៃធ្វើស្រែចម្ការ ជាកសិករ។

**ស៖** អរគុណ។ ហើយឪពុករបស់លោកឈ្មោះអ្វីដែរ?

**លោក ញ៉ែម សំណាង៖**

ឪពុកអ៊ំឈ្មោះអ្វី?

**ឆ៖** ឪពុកខ្ញុំឈ្មោះ ឡុង ភួង។ ស្លាប់ហើយ។

[១៣:៤៦:២៣]

**ស៖** ចុះម្ដាយរបស់លោកឈ្មោះអីដែរ?

**ឆ៖** ម្ដាយឈ្មោះ ម៉ៅ ថេង គាត់ស្លាប់ដែរហើយ។

**ស៖** លោកមានប្រពន្ធទេ?

**លោក ញ៉ែម សំណាង៖**

អ៊ំមានប្រពន្ធទេ?

**ឆ៖** ខ្ញុំមានប្រពន្ធ។ ឥឡូវនេះខ្ញុំមានកូន៥នាក់។ ប្រុស ៣ ស្រី ២។

**ស៖** លោក ឡុង នរិន្ទ តាមរបាយការណ៍របស់ក្រឡាបញ្ជីថា លោកតាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានឪពុក ម្ដាយ បុព្វញាតិ កូន បច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនសាច់ថ្លៃ ឬប្រពន្ធ ត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងរឿងក្ដី០០២ទេ។ តើនេះជាការពិតដែរឬទេ?

**លោក ញ៉ែម សំណាង៖**

ថាអ៊ំមានជាប់សាច់ញាតិជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណីដែរឬទេអ៊ំ?

**ឆ៖** ជាមួយនឹងជនជាប់ចោទនេះ?

**លោក ញ៉ែម សំណាង៖**

ដើមបណ្ដឹងរដ្ឋប្បវេណីអ៊ំ? មានទេ អ៊ំមានសាច់សាលោហិតទេ? លោកប្រធានគាត់សួរថា មានជាប់សាច់សាលោហិតជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណីទេអ៊ំ?

[១៣:៤៨:២៥]

**ឆ៖** ខ្ញុំអត់មានទេ។

**ស៖** បាទ,អរគុណ។ ហើយតើលោកបានធ្វើសម្បថរួចហើយឬនៅ?

**លោក ញ៉ែម សំណាង៖**

អ៊ំបានធ្វើសម្បថហើយឬនៅ?

**ឆ៖** ទទួលហើយ។

**ស៖** លោកអ៊ំនៅក្នុងរឿងក្តីនេះ ក្នុងនាមជាសាក្សី គឺនៅចំពោះមុខអង្គជំនុំជម្រះ លោកអាចបដិសេធនៅក្នុងការឆ្លើយទៅនឹងសំណួរ ឬការធ្វើអំណះអំណាងណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនរបស់លោក បានសេចក្តីថា គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថាដោយសារតែចម្លើយ ឬអំណះអំណាងលោក នាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។

ទីពីរ ដោយសារការបកប្រែភាសាតាមរយៈបកប្រែបណ្តាក់ ដូច្នេះក្រោយពេលដែលអ៊ំឆ្លើយវគ្គនីមួយៗ សូមអ៊ំពន្យារពេលបន្តិច ដើម្បីទុកលទ្ធភាពឲ្យអ្នកបកប្រែភាសាដោយវិធីបណ្តាក់នោះអាចបកប្រែបាន។ គាត់ស្តាប់បានទេ?

**លោក ញ៉ែម សំណាង៖**

ស្តាប់បានទេអ៊ំ?

[១៣:៥០:៣៦]

**លោក ឡុង នរិន្ទ៖**

អត់។ អាល័យតែឈឺបត់ជើងនេះ។

**លោក ញ៉ែម សំណាង៖**

ជម្រាបប្រសាសន៍លោកប្រធាន សាក្សីសុំអធ្យាស្រ័យទៅបន្ទប់ទឹក គាត់ឈឺបត់ជើង។

**ប្រធានអង្គជំនុំ៖**

នេះអ៊ំប្រាប់បន្ថែមបន្តិច ដោយសារអ៊ំមានវ័យចាស់ ហើយសាក្សីអាចទៅបន្ទប់ទឹកបាន នៅពេលណាដែលអ៊ំត្រូវការទៅ អ៊ំសុំមកអង្គជំនុំជម្រះភ្លាម មកយើងដើម្បីយើងអនុញ្ញាតណ៎ា។ ឥឡូវអញ្ជើញទៅចុះ!

អញ្ជើញមេធាវី!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមលោកប្រធានមេត្តាសួរសំណួរម្តងទៀត។ ទាក់ទងនឹងពាក្យថា “សម្បថ” ហើយខ្ញុំឮគាត់ឆ្លើយ ឮថាទទួលទៅវិញ ប្រហែលជាឮថាសំបុត្រមិនដឹង។ អ៊ីចឹងសូមមេត្តា

លោកប្រធានសួរម្តងទៀត ដើម្បីច្បាស់។ ព្រោះលោកប្រធានបានសួរថា “បានធ្វើសម្បថហើយ ឬនៅ?” ហើយអ្នកខាងណោះឆ្លើយថា សំបុត្រ គាត់ឆ្លើយថា “បានទទួលហើយ” អ៊ីចឹងច្រឡំសម្បថ សំបុត្រ ឬទេ។ ព្រោះអាចថាមានសំបុត្រពីតុលាការទៅគាត់បានទទួល។

សូមអរគុណ។

**លោក វីណ្ឌៀម ស្មឹត៖**

ខ្ញុំសូមឆ្លៀតឱកាសនេះថា យើងត្រូវចងចាំដោយសារតែនេះជាការបកប្រែបណ្តាក់មិនមែនប្រដេញនោះទេ ដូច្នេះវានឹងចំណាយពេលទ្វេដងចំពោះសាក្សីរូបនេះ ហើយចំពោះបញ្ហាតភ្ជាប់រូបភាពវីដេអូនេះក៏ចំណាយពេលច្រើនផងដែរ។ ដូច្នេះហើយ ខ្ញុំគិតថា ខាងសហព្រះរាជអាជ្ញាគួរតែទទួលការអនុញ្ញាតឱ្យសួរដេញដោលរហូតដល់ម៉ោងបួននៅក្នុងថ្ងៃនេះ ហើយនៅចុងថ្ងៃនេះ នៅបញ្ចប់ថ្ងៃនេះ លោកចៅក្រមអាចធ្វើការវិភាគ ពិចារណាថាតើរយៈពេលប៉ុន្មានដែលសមស្របដោយសារតែសាក្សីនេះ វាមានភាពសារៈសំខាន់ណាស់ ដែលយើងត្រូវសួរទៅលើគ្រប់អង្គហេតុដែលមាននៅក្នុងដីកាចោទប្រកាន់បញ្ជូនរឿង ទៅជំនុំជម្រះ។ សូមអរគុណ។

[១៣:៥៤:៣៩]

**ប្រធានអង្គជំនុំ៖**

សួស្តីលោក ឡុង នរិន្ទ! ឡុង នរិន្ទ ខ្ញុំសូមបញ្ជាក់ម្តងទៀតថា នៅក្នុងអំឡុងពេលនៃការស្តាប់សក្ខីកម្មនេះ គឺលោកមានសិទ្ធិនៅក្នុងការសុំសម្រាក ដើម្បីទៅបន្ទប់ទឹក គ្រាន់តែប្រាប់មកយើង ដើម្បីយើងរៀបចំអនុញ្ញាតដូចអម្បាញ់មិញនេះ។ ហើយបញ្ហាមួយទៀត គឺដោយសារចម្លើយអម្បាញ់មិញហ្នឹងមិនច្បាស់លាស់។ ឥឡូវស្តាប់សំណួរម្តងទៀត ថាតើលោកបានធ្វើសម្បថរួចហើយឬនៅ មុនពេលផ្តល់សក្ខីកម្មនេះ?

ស្តាប់ឮទេៗ? ខ្ញុំសួរលោក ថាតើលោកបានធ្វើសម្បថ បានស្បថហើយនៅមុននឹងផ្តល់សក្ខីកម្ម?

**លោក ញ៉ែម សំណាង៖**

ឮទេអ៊ំ? សួរថា អ៊ំបានធ្វើសម្បថហើយឬនៅអ៊ំ?

**ឆ៖** ស្បថអម្បាញ់មិញហ្នឹង។

**លោក ញ៉ែម សំណាង៖**

ហ្នឹងហើយៗ អ៊ីចឹងជម្រាបលោកប្រធាន។

**ឆ៖** បាទ, ខ្ញុំបានធ្វើហើយ។

**ស៖** ធ្វើសម្បថពីពេលណា?

**ឆ៖** សម្បថអំមិញៗហ្នឹងមុននឹង។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ លោកសហព្រះរាជអាជ្ញាដោយអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង និងលិខិតចាត់តាំងភារកិច្ចឲ្យទទួលខុសត្រូវជាចម្បងក្នុងការសួរដេញដោលចំពោះសាក្សីបួននាក់ដំបូងចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ របស់អង្គជំនុំជម្រះ។ អង្គជំនុំជម្រះផ្តល់វេទិកានេះទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការសួរសាក្សីរូបនេះ។

សូមអញ្ជើញសហព្រះរាជអាជ្ញា!

[១៣:៥៧:១៤]

**លោក ខេល លីសាក់៖**

អរុណសួស្តីលោកចៅក្រម លោក លោកស្រីចៅក្រម!

**អ្នកបកប្រែ៖**

សូមអនុញ្ញាតពីលោកប្រធានដោយសារមានសំឡេងឆ្លងនៅក្នុងឧបករណ៍ ដូច្នេះអ្នកបកប្រែទទួលសំឡេងសហព្រះរាជអាជ្ញាអត់បាន។

សូមគោរពលោកប្រធានសាជាថ្មី! ដោយសារតែឮសំឡេងឆ្លងនៅក្នុងឧបករណ៍របស់អ្នកបកប្រែ។ ដូច្នេះអ្នកបកប្រែទទួលសំឡេងសហព្រះរាជអាជ្ញាអត់បាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលសម្របសម្រួលបញ្ហាបកប្រែភាសា។

*(មានបញ្ហាបច្ចេកទេស)*

[១៣:៥៩:១៨]

សហព្រះរាជអាជ្ញារង បញ្ហាសំឡេងនេះមិនមែនបញ្ហាសំឡេងរំខានដោយសារបច្ចេកទេសនៅទីនេះទេ។ ដោយសារសំឡេងនៅឯនាយឯនោះ គេមានរៀបការៗ នៅជិតផ្ទះរបស់សាក្សី។ អ៊ីចឹងហើយបានជាមានបញ្ហា យើងគ្រាន់តែសម្រួលឲ្យគេបង្វែរនូវក្បាលមីក្រូចេញបន្តិចប៉ុណ្ណោះ យើងអត់មានដំណោះស្រាយអីផ្សេងទេ។

ហើយអម្បាញ់មិញតាមស្តាប់លោកសហព្រះរាជអាជ្ញាសូមអង្គុយសួរ ដោយសារមូលហេតុនៃការមើលឃើញទៅចំពោះរូបភាពជាមួយ-- ទល់ជាមួយនឹងសាក្សី។ អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំ។ អាចអង្គុយសួរបាន។

**លោក ឌេល លីសាក់៖**

សូមអរគុណច្រើនលោកប្រធាន។

**អ្នកបកប្រែ៖**

លោកប្រធានឧបករណ៍សំឡេងនៅពេលដែលបើកក្បាលមីក្រូហ្វូនគឺអត់ឮសំឡេង។

បាទ ពេលនេះឮវិញហើយ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

សូមសួស្តីលោក ឡុង នរិន្ទ ខ្ញុំឈ្មោះ ឌេល លីសាក់ ខ្ញុំនឹងសួរសំណួរមួយចំនួននៅក្នុងរសៀលនេះតាងនាមឲ្យខាងការិយាល័យសហព្រះរាជអាជ្ញា។

[១៤:00:៥0]

**ស៖** តើលោកបានឮសំឡេងខ្ញុំច្បាស់ដែរឬទេ?

លោក ឡុង នរិន្ទ តើលោកបានទទួលសំឡេងខ្ញុំដែរឬទេ? លោកបានឮសំឡេងខ្ញុំដែរឬទេ?

**មន្ត្រីអង្គភាពគាំពារសាក្សី/អ្នកជំនាញ៖**

បានឮទេអ៊ំៗ?

**លោក ឡុង នូរិន្ទ៖**

**ឆ៖** ឮ ប៉ុន្តែមិនដឹងគេនិយាយពីរឿងអី។

**ស៖** ខ្ញុំអម្បាញ់មិញនេះធ្វើការណែនាំឈ្មោះរបស់ខ្ញុំ ហើយខ្ញុំសួរទៅលោក ថាតើលោកបានឮខ្ញុំនិយាយដែរឬទេ? ដូច្នេះនៅពេលនេះ តើលោកបានឮដែរឬទេ ហើយប្រសិនបើលោកមានបញ្ហាស្តាប់មិនឮសំណួរដែលខ្ញុំសួរ សូមលោកនិយាយប្រាប់ខ្ញុំ ខ្ញុំនឹងនិយាយសំណួរឡើងវិញ។ តើលោកស្តាប់បានដែរឬទេ?

លោកចៅក្រមជាទីគោរព! ខ្ញុំមិនដឹងថាតើសាក្សីបានស្តាប់សំឡេងខ្ញុំឮដែរឬទេ?

លោក ឡុង នរិន្ទ ប្រសិនបើលោកបានឮនេះ គឺខ្ញុំចង់ឲ្យលោកជម្រាបអំពីប្រវត្តិនៃការសិក្សារៀន

សូត្ររបស់លោក។ តើលោកអាចជម្រាបបានដែរឬទេ អំពីប្រវត្តិនៃការសិក្សារៀនសូត្ររបស់លោក?

**ឆ៖** ថាម៉េចអំមិញ?

**លោក ញ៉ែម សំណាង៖**

អំមិញសហព្រះរាជអាជ្ញា គាត់សុំសួរអ៊ំថាតើលោកអ៊ំឮទេ? ហើយអ៊ំអាចឲ្យអ៊ំនិយាយអំពីប្រវត្តិនៃការសិក្សារបស់អ៊ំពីដើមមក។

**ស៖** លោក ឡុង នរិន្ទ សូមឲ្យលោកបញ្ជាក់ថា លោកឮដែរឬទេ? សំណួរទីមួយដែលខ្ញុំចង់សួរទៅកាន់លោក ថាតើលោកធ្លាប់បានទៅរៀនសូត្រនៅសាលាណាដែរ? ហើយការរៀនសូត្រនោះ រៀនសូត្រពីអ្វីខ្លះ? សូមលោកជម្រាបប្រសិនបើលោកឮ។

[១៤:០៣:៥៨]

**ប្រធានអង្គជំនុំ៖**

លោក ញ៉ែម សំណាង លោកស្តាប់បានទេ?--

**លោក ញ៉ែម សំណាង៖**

បាទ លោកប្រធានៗ។

**ប្រធានអង្គជំនុំ៖**

សំណួររបស់លោកសហព្រះរាជអាជ្ញារងអន្តរជាតិសួរគាត់អំមិញនេះ លោកផ្ទាល់ខ្លួនឯង លោក ញ៉ែម សំណាង ឮទេ ខ្លួនឯងឮទេ?

**លោក ញ៉ែម សំណាង៖**

ឮៗលោកប្រធាន ខ្ញុំបាទឮ។

**ប្រធានអង្គជំនុំ៖**

ហើយចុះ គាត់អត់ឮទេ ឬក៏គាត់មានការអន់ត្រចៀក ឬក៏យ៉ាងម៉េច? សួរគាត់មើល តើគាត់ឮស្តាប់ឮទេ? បានអត់ឮគាត់ ឃើញឮឆ្លើយផង។

**លោក ញ៉ែម សំណាង៖**

អ៊ំឮទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

បាទ ឮទេ។

**លោក ញ៉ែម សំណាង៖**

ឮអ្វីដែលសហព្រះរាជអាជ្ញាសួរអំមិញទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

អូ៎! មិនដឹងសួរពីរឿងអីទេអំមិញ។

**លោក ញ៉ែម សំណាង៖**

សាក្សីឮអត់ច្បាស់ ហើយមិនដឹងថាសួរយ៉ាងម៉េច ហើយខ្ញុំបាទមិនប៉ាន ទាល់មានការអនុញ្ញាត ពីលោកប្រធានបានខ្ញុំអាចនិយាយបកប្រែឲ្យគាត់បាន អ និយាយថាឡើងវិញជូនគាត់ស្តាប់បាន លោកប្រធាន។

[១៤:០៤:៥៤]

**លោក ឌេល លីសាក់៖**

ថាតើលោក ឡុង នរិន្ទ បានឮខ្ញុំនិយាយជាភាសាខ្មែរដែរឬទេ? ឬក៏ឮជាភាសាអង់គ្លេស? ពេលដែលលោកឮហ្នឹង? ឮជាភាសាខ្មែរ ឬក៏អង់គ្លេស?

**លោក ញ៉ែម សំណាង៖**

អ៊ំឮទេ អ៊ំ?

**ឆ៖** អំមិញនេះ គាត់សួរអំមិញខឹង ហើយខ្ញុំអត់ឮទេ។

**លោក ញ៉ែម សំណាង៖**

បើអ៊ំបានឮ អ៊ំឆ្លើយ។ បើអ៊ំអត់ឆ្លើយ ខាងនោះ គេអត់ដឹងទេ។ អ៊ំ អញ្ជើញឆ្លើយ ដើម្បីឲ្យឮទៅខាងនោះ អ៊ំណ៎ា។

**ឆ៖** បាទៗ។

**លោក ញ៉ែម សំណាង៖**

អត់ទេ អ៊ំគ្រាន់តែនិយាយទៅបានហើយ អានេះស្រួបហើយ ណ៎ាអ៊ំ។

**ឆ៖** បាទ។

**លោក ញ៉ែម សំណាង៖**

អ៊ំគ្រាន់តែនិយាយទៅបានហើយ។ បើអ៊ំអត់ច្បាស់ អ៊ំសួរខ្ញុំណាស់អ៊ំ។

**ឆ៖** បាទ។

[១៤:០៥:៥៣]

**ស៖** លោកប្រធាន ខ្ញុំអត់ទទួលបានការបកប្រែមកខ្ញុំវិញ ថាតើគាត់បាននិយាយខ្លះ? ដូច្នេះ ខ្ញុំអត់ដឹងថាតើគាត់ទទួលបានសំឡេងខ្ញុំ ឬក៏អត់នោះទេ? ខ្ញុំសូមសាកសួរម្តងទៀត លោក ឡុង នរិន្ទ្រ តើលោកអាចប្រាប់ខ្ញុំ ថាតើលោកទៅរៀននៅឯណានៅពេលដែលលោកអ៊ំនៅក្មេងនោះ?

**ឆ៖** ពេលខ្ញុំនៅក្មេង ខ្ញុំទៅអឺរ៉ុបនោះ គឺទៅរៀននៅស្រុកឆេកូស្លូវ៉ាគី។

**ស៖** ថាតើលោកអ៊ំទៅរៀនឆេកូនោះ រយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំទៅរៀននៅឆេកូហ្នឹង រយៈ១០ឆ្នាំ។

**ស៖** តើលោកអ៊ំអាចជម្រាបទេ ទៅរៀននៅនុ៎ង នៅឆ្នាំណាដែរ?

**លោក ញ៉ែម សំណាង៖**

អ៊ំទៅរៀននៅឆ្នាំណាដែរ?

**ឆ៖** ខ្ញុំនៅរៀននៅឆ្នាំ១៩៦០-៦១ ឆ្នាំសិក្សា រហូតទាល់មកដល់ ៧០-៧១ បានខ្ញុំត្រឡប់មកវិញ តាមប៉េកាំង។ ដោយសារព្រះករុណាលោក-- ព្រះករុណា សីហនុ លោកអំពាវនាវទៅពីប៉េកាំងទៅថា ឲ្យមកជួយធ្វើនៅក្នុងប្រទេស។

[១៤:០៧:៥០]

**ស៖** នៅពេលដែលលោកនៅឆេកូស្លូវ៉ាគីនោះ តើលោកអ៊ំបានរៀនមុខវិជ្ជាអីដែរ?

**លោក ញ៉ែម សំណាង៖**

នៅឆេកូ អ៊ំរៀនមុខវិជ្ជាអ្វីដែរ?

**ឆ៖** នៅឆេកូ ខ្ញុំរៀនមុខវិជ្ជាកាយអប់រំ ហាត់កីឡា និងកីឡា នៅមហាវិទ្យាល័យ-- វិទ្យាស្ថានកាយអប់រំ និងកីឡា នៅប្រាត។

**ស៖** នៅពេលក្នុងឆ្នាំដែលលោកអ៊ំនៅឆេកូស្លូវ៉ាគីនោះ តើលោកអ៊ំបានធ្វើការទាក់ទងជាមួយនឹងនរណាម្នាក់នៅក្នុងបក្សពលករកម្ពុជា ហើយក្រោយមកដែលដូរទៅជាបក្សកុម្មុយនីស្តកម្ពុជានោះ ដែរឬទេ អ៊ំមានទាក់ទងជាមួយអ្នកណាគេនៅក្នុងបក្សនុ៎ងដែរឬទេ?

**ឆ៖** ពេលហ្នឹង ខ្ញុំអត់មានទាក់ទងជាមួយនឹងគណបក្សនយោបាយនៅអីក្នុងស្រុកនោះទេ។

**ស៖** ថាតើមាននរណាម្នាក់បានអញ្ជើញអ៊ំឲ្យទៅប៉េកាំងនោះដែរឬទេ? ឬក៏ការធ្វើដំណើរទៅប៉េកាំងនោះ គឺអ៊ំទៅដោយខ្លួនឯង?

**ឆ៖** ពេលនុ៎ង ព្រះករុណាសម្ដេចឪ សីហនុ លោកធ្វើសេចក្ដីអំពាវនាវពីប៉េកាំងទៅ។ ដល់អ៊ីចឹង ខ្ញុំក៏ត្រូវតែ ខ្ញុំចង់មកស្រុកគឺខ្ញុំត្រូវតែមកតាមប៉េកាំងបានចូលមកស្រុកខ្មែរយើង។

[១៤:១០:០០]

**សៈ** តើលោកអ៊ំស្នាក់នៅប៉េកាំងរយៈពេលប៉ុន្មានដែរ លោកអ៊ំ ឡុង នរិន្ទ?

**ឆ៖** សួរថាម៉េចទេ ស្ដាប់អត់បានទេ។

**ប្រធានអង្គជំនុំ៖**

លោក សំណាង នៅពេលដែលលោកស្ដាប់បាន ហើយបើគាត់ស្ដាប់មិនបានទេ គឺលោកអាចរំឭកប្រាប់ពីសំណួរហ្នឹងបញ្ជាក់បន្ថែម បញ្ជាក់ឲ្យច្បាស់ទៅគាត់ ដើម្បីឲ្យគាត់ស្ដាប់សំណួរច្បាស់ ហើយនិងអាចឆ្លើយតបបាន។

**លោក ញ៉ែម សំណាង៖**

បាទ, លោកប្រធាន។

តើអ៊ំស្នាក់ទៅប៉េកាំងហ្នឹងរយៈពេលប៉ុន្មានដែរអ៊ំ?

**ឆ៖** ដូចប្រាំមួយខែ-- ខ្ញុំស្នាក់នៅប៉េកាំងគឺថាទាល់តែដល់រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិត្រូវត្រឡប់មកស្រុកវិញដែរ។

[១៤:១១:៣៣]

**សៈ** តើលោកអ៊ំបានចូលរួមជាមួយនឹងចលនាតស៊ូដែរឬទេ នៅពេលដែលលោកអ៊ំស្នាក់នៅទីក្រុងប៉េកាំងនោះ?

**ឆ៖** ពេលដែលខ្ញុំស្នាក់នៅក្រុងប៉េកាំងហ្នឹង គឺបានចូលរួមជាមួយនឹងចលនាតស៊ូដែរ គឺចលនាតស៊ូដែលមានព្រះករុណា សីហនុ ជាប្រធាន។

**សៈ** តើលោកអ៊ំអាចជម្រាបប្រាប់អង្គជំនុំជម្រះដែរឬទេ ថាតើអ៊ំចូលរួមចលនាតស៊ូនោះដោយរបៀបណា? ហើយគេណែនាំយ៉ាងម៉េចខ្លះដើម្បីចូលចលនាតស៊ូនុ៎ង?

**ឆ៖** អង្កាល់ពេលនោះ គឺចលនាតស៊ូហ្នឹងមានរាជរដ្ឋាភិបាលស្នាក់នៅប៉េកាំង ដូច្នោះខ្ញុំចូលជាមួយនឹងរាជរដ្ឋាភិបាលនោះឯង។ ធ្វើការនៅក្រសួងការបរទេស។

**សៈ** ថាតើនរណាគេដែលជ្រើសរើសអ៊ំឲ្យធ្វើការនៅក្រសួងការបរទេសនៅទីក្រុងប៉េកាំងនុ៎ង?

**លោក ញ៉ែម សំណាង៖**

តើនរណាគេជ្រើសរើសអ៊ំឲ្យធ្វើការនៅក្រសួងការបរទេសនៅប៉េកាំង?

**ឆ៖** អង្គាល់ហ្នឹងគឺ អ្នកដែល-- និស្សិតដែលរៀនចប់ហើយទៅពីក្រៅទៅ ទៅចូលធ្វើនៅក្នុងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិនៅក្នុងប្រ៉ុង។ ដូច្នោះអង្គាល់នុ៎ង រដ្ឋមន្ត្រីការបរទេសគឺមានឯកឧត្តម សារិន ឆាក ហើយដូចអត់មានដាក់ពាក្យសុំអីចូល អីទេ គឺថាទៅដល់ហ្នឹងអ្នកដែលទៅពីក្រៅទៅហ្នឹង ទៅចូលធ្វើការនៅហ្នឹងតែម្តង ពីព្រោះការងារនៅក្រសួងការបរទេសហ្នឹងមានការវាយម៉ាស៊ីន មានការបកប្រែភាសា និងមានការសរសេរ ជាញត្តិជាអីផ្សេងៗ ជាសំបុត្រផ្សេងៗ។

[១៤:១៥:១៣]

**ស៖** តើលោកអ៊ំស្គាល់ អៀង សារី ដែរឬទេ?

**លោក ញ៉ែម សំណាង៖**

តើអ៊ំស្គាល់លោក អៀង សារី ដែរឬទេ?

**ឆ៖** ពីមុនខ្ញុំអត់ស្គាល់ទេ ដល់ចូលទៅនៅក្នុងក្រសួងហ្នឹងបានស្គាល់គាត់ច្បាស់។

**ស៖** ចាតើលោកអ៊ំអាចជម្រាបតុលាការបានដែរឬទេថា លោកអ៊ំជួប អៀង សារី ដំបូងនៅពេលណា?

**លោក ញ៉ែម សំណាង៖**

អ៊ំជួប អៀង សារី ដំបូងនៅពេលណា?

**ឆ៖** ខ្ញុំជួបនឹងលោក អៀង សារី គឺនៅពេលដែលចូលទៅក្នុងក្រសួងការបរទេសនៅប៉េកាំងហ្នឹងឯង។ ពីមុនៗមកគ្រាន់តែឃើញ គ្រាន់តែជួបគាត់ដែរ ប៉ុន្តែមិនមែននេះទេ គ្រាន់តែពេលដែលគាត់មកពីស្រុកបារាំងវិញ ក៏បានជួបគាត់ដែរ។ ប៉ុន្តែអត់មាននិយាយអីទេនុ៎ង គ្រាន់តែជួបសួរសុខទុក្ខអីប៉ុណ្ណឹង អត់មានចូលរឿងនយោបាយទេ។

**ស៖** នៅពេលដែលលោកអ៊ំនិយាយថា លោកអ៊ំបានជួបគាត់ពីមុននៅពេលដែលលោកអ៊ំមុនដែលមកពីប្រទេសបារាំងនោះ មុនដែលគាត់មកពីប្រទេសបារាំងនោះ តើអ៊ំជួបគាត់ក្នុងឆ្នាំណាដែរ?

**ឆ៖** ខ្ញុំមិនចាំទេ មិនចាំថាឆ្នាំណាទេអង្គាល់ហ្នឹង។

[១៤:១៧:៣០]

**ស៖** នៅពេលដែលលោកអ៊ំនិយាយថា លោក អៀង សារី វិលត្រឡប់មកពីប្រទេសបារាំងនោះ

ថាតើលោក អៀង សារី ហ្នឹងគាត់ធ្វើដំណើរទៅណា មុនពេលដែលលោកអ៊ំហ្នឹងជួបលោក អៀង សារី ហ្នឹងនៅក្នុងទីក្រុងប៉េកាំង?

**ឆ៖** អត់ទេ អង្កាល់ហ្នឹងខ្ញុំអត់ជួបនៅប៉េកាំងទេ គឺខ្ញុំជួបនៅស្រុក នៅភ្នំពេញតែម្តង។ គាត់បណ្តើរគ្រួសារគាត់ទៅ ហើយខ្ញុំក៏ដើរលេងដែរ កាលហ្នឹងបុណ្យអីមិនដឹងទេ។ ទៅមានមិត្តម្នាក់ទៀតនោះ គេស្គាល់គាត់។ គេប្រាប់ខ្ញុំថា គេគ្រាន់តែចង្អុលប្រាប់ខ្ញុំថានេះ អៀង សារី ហើយបានជាខ្ញុំជួបសួរទុក្ខគាត់តែប៉ុណ្ណឹងទេ ហើយចប់។

**ស៖** នៅពេលដែលជួបហ្នឹងបានន័យថា មុនពេលដែលលោកអ៊ំទៅឆេកូស្លូវ៉ាគី ក្នុងឆ្នាំ១៩៦១ ហ្នឹងមែនអត់?

**លោក ញ៉ែម សំណាង៖**

អ៊ំស្តាប់បានទេ?

**ឆ៖** អត់បានទេ។

**លោក ញ៉ែម សំណាង៖**

តើអ៊ំបានជួបលោក អៀង សារី មុនឆ្នាំអ៊ំអញ្ជើញទៅឆេកូស្លូវ៉ាគី នៅឆ្នាំ១៩៦១ហ្នឹងមែនទេ?

**ឆ៖** អត់ទេ ពេលដែលជួប មែនទែនទៅខ្ញុំចាំមិនច្បាស់ទេ ភ្លេចហើយអាហ្នឹង។ ប៉ុន្តែពីឆ្នាំណាដែលជួបគាត់ហ្នឹង។ ប៉ុន្តែអត់មាននិយាយរឿងអីទេ។

**ស៖** ពេលលើកទីមួយដែលអ៊ំជួបលោក អៀង សារី ថាតើលោកអ៊ំបានដឹងអ្វីខ្លះ និងស្គាល់ថាគាត់ជានរណាដែរឬទេ?

**ឆ៖** ពេលហ្នឹងដែលគេប្រាប់ខ្ញុំគាត់ឈ្មោះ អៀង សារី ហ្នឹង ខ្ញុំស្គាល់តែប៉ុណ្ណឹង។

[១៤:២០:០០]

**ស៖** តើគេនោះដែលគេហ្នឹងអ្នកណាគេដែលថាប្រាប់អ៊ំហ្នឹង ដែលគេចង្អុលប្រាប់ថាគាត់ជា អៀង សារី នោះ? គេនោះគឺអ្នកណាដែរអ៊ំ?

**ឆ៖** ដូចជា អង្កាល់ហ្នឹង ដូចជា ថាច់ ជា។ និស្សិតម្នាក់ទៀតនៅសាលាគរុកោសល្យដែរ ហើយដែលរៀនជំនាន់ខ្ញុំ។

**ស៖** សូមអរគុណ។ តើលោកអ៊ំមានការទាក់ទងជាមួយនឹងលោក អៀង សារី ដែរឬទេក្នុងរយៈពេលដែលលោកអ៊ំស្នាក់នៅក្នុងប្រទេសឆេកូស្លូវ៉ាគី ១០ឆ្នាំហ្នឹង?

**ឆ៖** កាលដែលខ្ញុំស្នាក់នៅប្រទេសឆេកូស្លូវ៉ាគីនោះ អត់មានការទាក់ទងជាមួយនឹងលោក អៀង សារី ទេ។ អត់ស្គាល់គាត់ទេ។

**ស៖** នៅពេលដែលលោកអ៊ំជួបលោក អៀង សារី នៅទីក្រុងប៉េកាំង តើលោក អៀង សារី បានធ្វើអ្វីដែរនៅប៉េកាំងហ្នឹង គាត់នៅធ្វើអីដែរ?

**ឆ៖** កាលដែលនៅប៉េងកាំងនោះ លោក អៀង សារី គាត់ជាវរជនពិសេសរបស់រដ្ឋាភិបាលហ្គ្រុង ទទួលខាងការបរទេស។

[១៤:២១:៥៤]

**ស៖** នៅពេលណាដែលលោកអ៊ំបានចូលរួមជាមួយនឹងបក្សពលករកម្ពុជា ឬក៏បក្សកុម្មុយនីស្តកម្ពុជាហ្នឹង?

**ឆ៖** ខ្ញុំមិនចាំច្បាស់ទេ មិនដឹងពេលណាទេ ប៉ុន្តែក្រោយមកហើយ។ ក្រោយទាល់តែយើងឈ្នះអាមេរិករួចហើយ។

**ស៖** តើនរណាគេដែលអញ្ជើញអ៊ំ ឬខទ្មេសនាមអ៊ំឲ្យចូលជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជានោះ?

**ឆ៖** អង្កាល់ពេលនោះជារួមទៅអ្នកដែលធ្វើការនៅក្នុងក្រសួងទាំងអស់គ្នាហ្នឹងគឺថា ពីព្រោះចូលក្នុងចលនាប្រឆាំងនឹងអាមេរិក អង្កាល់នៅនឹងវ៉ៃជាមួយអាមេរិកហ្នឹង គឺចូលទាំងអស់គ្នាអត់មាននរណាអញ្ជើញនរណាអីទេ។

**ស៖** ខ្ញុំសូមសួរបំភ្លឺ។ នៅពេលដែលលោកអ៊ំនិយាយថា លោកអ៊ំចូលរួមជាមួយនឹងបដិវត្តន៍ លោកអ៊ំមានន័យថា លោកអ៊ំបានចូលជាសមាជិករបស់បក្សហ្នឹងមែនទេ?

[១៤:២៣:៥៤]

**លោក ញ៉ែម សំណាង៖**

អ៊ំឮទេអ៊ំ? អ៊ំស្តាប់សំណួរបានទេអ៊ំ?

**ឆ៖** បាទ។ មែនទែននិយាយជារួមទៅ ចូលក្នុងបក្សហ្នឹងដោយមិនដឹងខ្លួនផងទេ មែនទែនទៅ។ វាទាំងអស់គ្នា ទាំងអស់គ្នាទៅហើយ ពីព្រោះប្រទេសយើងត្រូវគេឈ្លានពាន វាត្រូវតែចូលរួមប្រយុទ្ធហើយ។

**ស៖** តើលោកអ៊ំអាចជម្រាបអង្គជំនុំជម្រះបានដែរឬទេ? តើលោកអ៊ំបានធ្វើការងារអ្វីដែរ នៅ

ក្នុងពេលដែលលោកអ៊ំស្នាក់នៅក្នុងទីក្រុងប៉េកាំងនុ៎ង?

[១៤:២៥:០០]

**ឆ៖** អង្កាល់ដែលខ្ញុំស្នាក់នៅប៉េកាំងហ្នឹង គឺថាធ្វើការ ការងារដែលខ្ញុំថាការបរទេសហ្នឹងគឺវាយម៉ាស៊ីន វាយសំបុត្រផ្សេងៗ ដែលទាក់ទងពីប្រទេសមួយទៅប្រទេសមួយ ឬក៏ចលនាមួយ ទៅចលនាមួយនោះឯង។

**ស៖** តើលោកអ៊ំចាំដែរឬទេថា តើនៅពេលណាដែរដែលលោកអ៊ំចាកចេញពីទីក្រុងប៉េកាំង?

**ឆ៖** អង្កាល់ហ្នឹងគឺថា ក្នុងខែមេសានោះហើយ ប៉ុន្តែមិនដឹងថ្ងៃប៉ុន្មានខ្ញុំមិនចាំទេ។

**ស៖** តើខែមេសា ក្នុងឆ្នាំណាដែរលោកអ៊ំ?

លោក ឡុង នរិន្ទ ខ្ញុំមិនដឹងថាលោកអ៊ំបានស្តាប់ខ្ញុំឮដែរឬទេ ខែមេសានោះ តើនៅក្នុងឆ្នាំណាដែរដែលលោកអ៊ំចាកចេញពីទីក្រុងប៉េកាំង?

**ឆ៖** ឯករាជ្យហ្នឹងមួយពាន់-- ឆ្នាំណា? មួយពាន់ប្រាំបួនរយ? គឺចាកចេញពីចេញពីក្រុងប៉េកាំងក្រោយថ្ងៃ ១៧ មេសា។ មែនទែនទៅប្រទេសកម្ពុជាឯករាជ្យហើយ។

**ស៖** បានន័យថា មកដល់ហ្នឹងគឺនៅក្នុងពេលដែលមុនឆ្នាំ១៩៧៥ ហ្នឹង នៅក្នុងពេលដែលលោកអ៊ំ នៅទីក្រុងហាណូយហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** អ្ហែ! ភ្លេច ៧៦ អី៧៥? ពេលដែលខ្ញុំត្រឡប់មកវិញហ្នឹងគឺថា មកឆ្លងកាត់ហាណូយ បានជួបនឹងលោកជំទាវ អៀង ធីរិទ្ធ គាត់នៅក្រសួងឃោសនា។ មែនទែននៅក្នុងវិទ្យុរណសិរ្សរួបរួមជាតិប្រជាធិបតេយ្យ។ ហើយខ្ញុំឈប់ធ្វើការ ខ្ញុំមកចូលនៅហ្នឹង ហើយធ្វើការនៅហ្នឹងដូចជាប្រាំមួយខែ បានបន្តដំណើរមកទៀត មកស្រុកខ្មែរ។

[១៤:២៩:២៨]

**ស៖** តើលោកអ៊ំអាចជម្រាបយើងខ្ញុំដែរឬទេ? ថាតើវិទ្យុរណសិរ្សរួបរួមជាតិប្រជាធិបតេយ្យនោះ ធ្វើអីដែរ? ផ្សព្វផ្សាយអ្វីដែរ?

**ឆ៖** វិទ្យុរួបរួមជាតិប្រជាធិបតេយ្យហ្នឹងគឺថា ជាសំឡេងអ្នកតស៊ូ ផ្សាយនៅទៅខាងក្រៅ។

**ស៖** ថាតើមានបុគ្គលិកកម្មាភិបាលប៉ុន្មាននាក់ដែរ ដែលធ្វើការនៅក្នុងវិទ្យុហ្នឹងនៅហាណូយនុ៎ង?

**ឆ៖** ខ្ញុំមិនចាំទេ ប៉ុន្មាននាក់ធ្វើការនៅហ្នឹង នៅក្នុងវិទ្យុហ្នឹងខ្ញុំអត់ចាំទេនៅហាណូយហ្នឹង។

**សៈ** ថាតើអៀង ធីរិទ្ធ ជាអ្នកទទួលបន្ទុកមើលការខុសត្រូវនៅក្នុងវិទ្យុហ្នឹង ឬក៏មិនមែនទេ?

**លោក ញ៉ែម សំណាង៖**

ថាតើលោកស្រី អៀង ធីរិទ្ធ ទទួលបន្ទុកការងារនៅក្នុងវិទ្យុនោះមែន ឬទេ?

**ផៈ** ពេលនោះ លោកស្រី អៀង ធីរិទ្ធ ជាចាងហ្វាងវិទ្យុនុ៎ង។

**សៈ** ថាតើអ្នកណាដែលជាអ្នកស្នើសុំឲ្យលោកធ្វើការនៅស្ថានីយវិទ្យុផ្សាយសំឡេងនោះ?

**លោក ញ៉ែម សំណាង៖**

សំណួរថាតើនរណាស្នើសុំអ៊ំឲ្យធ្វើការនៅវិទ្យុផ្សាយសំឡេងនោះ?

[១៤:៣១:៤១]

**ផៈ** មែនទែនទៅអត់មានអ្នកណាស្នើទេ គឺថាមក អត់វា-- ពេលហ្នឹងវាត្រូវពេលដែលខ្វះបុគ្គលិកធ្វើការ ចូលតែម្តង។ ចូលទៅធ្វើការនៅហ្នឹងតែម្តង។

**សៈ** តើអ្នកណាដែលជាអ្នកជ្រើសរើសលោកឲ្យធ្វើនៅស្ថានីយវិទ្យុនោះ?

**ផៈ** មែនទែនទៅអត់មានអ្នកណាស្នើចូលទេ អង្គាល់ហ្នឹង គឺថាចូលទៅខ្លួនឯង ប៉ុន្តែលោកអៀង សារី គាត់ណែនាំថា វិទ្យុហ្នឹងក៏ជាការតស៊ូសំខាន់ដែរ ហើយវាខ្វះបុគ្គលិក បើយើងចង់ទៅស្រុកបើយើងនៅហាណូយហ្នឹងសិនធ្វើការសិន រួចចាំចប់សឹមយើងទៅស្រុកក៏បាន អត់អីទេ។ ដល់អ៊ីចឹងខ្ញុំចូលទៅក្នុងវិទ្យុហ្នឹងទៅ។

**សៈ** តើលោកបានធ្វើអ្វីខ្លះក្នុងអំឡុងពេលដែលលោកបម្រើការងារនៅវិទ្យុផ្សាយសំឡេងនោះ?

**ផៈ** នៅពេលនុ៎ង ខ្ញុំក្រៅពីបកពីខ្មែរទៅឡាតាំង សារពីក្នុងស្រុកទៅហ្នឹង គឺថាខ្ញុំទទួលខាងសាលារៀន គឺអប់រំកូនចៅអ្នកដែលគេនៅហាណូយពីមុន ហើយគេត្រឡប់ចូលមកតស៊ូក្នុងស្រុក។ ដូច្នេះ កូនចៅគេនៅឯហាណូយនោះ ត្រូវតែយើងរៀបចំសាលាឲ្យគ្នារៀន ជាភាសាខ្មែរ ជានេះហ្នឹង។ ខ្ញុំទទួលខាងសាលារៀន។

**សៈ** តើវិទ្យុនោះ ផ្សាយសំឡេងជាភាសាអ្វីដែរ?

**ផៈ** វិទ្យុនោះ ផ្សាយសំឡេងជាខ្មែរ។

[១៤:៣៥:០២]

**សៈ** លោកបានបញ្ជាក់ថា ក្រោយពេលលោកបំពេញការងារនៅវិទ្យុផ្សាយសំឡេងនោះ លោកក៏បានវិលត្រឡប់មកកាន់ប្រទេសកម្ពុជា តើលោកវិលត្រឡប់មកប្រទេសកម្ពុជានៅពេលណាដែរ?

**ឆ៖** គឺប្រទេសកម្ពុជា ពេលដែលស្រុកបានឯករាជ្យមែនទែនហើយ បានឈ្នះសង្គ្រាមនៅ-- ឈ្នះសង្គ្រាមជាមួយអាមេរិកហើយ។ បត់ជើងតូច។

**ប្រធានអង្គជំនុំ៖**

ចង់ទៅបន្ទប់ទឹកអ្នេះ?

**លោក ញ៉ែម សំណាង៖**

បាទ, លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទៗ សូមអញ្ជើញទៅចុះ!

[១៤:៣៧:៤៣]

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកដែរហើយ ហើយដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាក ដប់ប្រាំនាទីចាប់ពីម៉ោងនេះទៅ រហូតដល់ម៉ោងបីខ្វះប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តសវនាការ។

*(សវនាការសម្រាកពីម៉ោង១៤:៣៨នាទី ដល់ម៉ោង ១៤:៥៩ នាទី)*

[១៤:៥៩:០៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ មុននឹងផ្តល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីសួរសាក្សី។ អង្គជំនុំជម្រះសូមជម្រាបដល់ដើមបណ្តឹងរដ្ឋប្បវេណី ក្លាន រិត និង រម៉ាម យុន ថា លោកទាំងពីរអាចត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោកវិញបានហើយ។ ហើយអង្គជំនុំជម្រះក៏បង្គាប់ ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ សម្របសម្រួលចាត់ចែងក្នុងការវិលត្រឡប់របស់ដើមបណ្តឹង រដ្ឋប្បវេណីទាំងពីររូបនេះ ឲ្យទៅកាន់លំនៅដ្ឋានរបស់គាត់វិញ ស្រួលបួលផងចុះ។ ហើយដើមបណ្តឹង រដ្ឋប្បវេណីទាំងពីររូបនេះ ហ្នឹងគឺអង្គជំនុំជម្រះនឹងធ្វើការកោះហៅមកចូលរួមសវនាការ ទំនងជាមិន អាចប្រព្រឹត្តទៅបាននៅក្នុងសប្តាហ៍ក្រោយទេ គឺទំនងជាអាចធ្វើបាននៅដើមនៅឆ្នាំ២០១២។ ហើយ កាលបរិច្ឆេទជាក់លាក់ក្នុងការកោះហៅពេលណានោះ អង្គជំនុំជម្រះនឹងកំណត់ពេលវេលា ហើយនិង ជូនដំណឹងក្នុងកាលវេលាសមស្រប។

ជាបន្ត អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរចំពោះសាក្សី ឡុង នរិន្ទ។ សូមអញ្ជើញ!

[១៥:០០:៤៦]

**លោក ខេល លីសាក់៖**

លោកប្រធានមុននឹងបន្ត ដោយសារថាមានការលំបាកបន្តិចហើយ ទាក់ទងទៅនឹងការសាកសួរសាក្សីនេះ។ ខ្ញុំសូមបន្តសួរឲ្យបានឆាប់ តាមដែលអាចធ្វើទៅបាន។ ខ្ញុំសូមជូនយោបល់ទៅតុលាការថា យើងនឹងត្រូវការពេលវេលាសម្រាប់ថ្ងៃស្អែក ព្រឹកស្អែកខ្លះទៀត ដើម្បីបញ្ចប់ការសាកសួរទៅលើសាក្សី ដោយសារតែបញ្ហានៃការភ្ជាប់បណ្តាញប្រព័ន្ធសោតទស្សន៍នេះ។ វាត្រូវការស៊ីពេលវេលា ហេតុដូច្នេះឯងប្រហែលជាស្អែក ព្រឹកស្អែកនេះគឺថាអាចនឹងត្រូវការពេលវេលាពាក់កណ្តាលព្រឹកទៀត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបន្ត ហើយបញ្ហានេះ អំមិញបានតំណាងសហព្រះរាជអាជ្ញាអន្តរជាតិក៏បានលើកឡើងបញ្ហានេះដែរ។ ដោយអង្គជំនុំជម្រះកំពុងតែប្រមើលមើលដែរ ថាតើស្ថានការណ៍នេះ នឹងមានលទ្ធភាពយ៉ាងម៉េច? ប៉ុន្តែអង្គជំនុំជម្រះជម្រាបភាគី និងសាធារណជនរួចហើយ ថាជាផែនការគឺយើងធ្វើមួយថ្ងៃកន្លះ ពីថ្ងៃនេះទៅថ្ងៃស្អែក ប៉ុន្តែដោយសារសុខភាព បញ្ហាបច្ចេកទេស និងនៃប្រព័ន្ធសោតទស្សន៍ និងបញ្ហាបកប្រែ។ អ៊ីចឹង បានយើងគ្រោងរួចហើយ ថាបើធ្វើមិនទាន់ទេ យើងនឹងគ្រោងធ្វើបន្តទៅថ្ងៃសុក្រទៀត។ ដូច្នេះកាលដែលពេលវេលាហ្នឹង គឺអាចបន្តទៅថ្ងៃស្អែកកម្រិតប៉ុន្មាននោះ គឺអង្គជំនុំជម្រះនឹងជម្រាបជូនបញ្ជាក់បន្ថែមនូវរសៀលនេះ ឬក៏នៅថ្ងៃស្អែកតែម្តង ពីព្រោះបញ្ហាដូចជាយើងបានយល់ដឹង ហើយក្តាប់បានទាំងអស់គ្នាហើយ។

សូមអញ្ជើញបន្តចុះ!

[១៥:០២:៤៧]

**សួរដោយលោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**ស៖** លោក ឡុង នរិន្ទ មុននឹងយើងខ្ញុំចូលនិយាយទៅដល់ពេលវេលាដែលលោកវិលត្រឡប់មកកាន់ប្រទេសកម្ពុជា។ ខ្ញុំមានពីរសំណួរទៀត ទាក់ទងទៅនឹងស្ថានីយវិទ្យុផ្សាយសំឡេងនោះ។ សំណួរទីមួយគឺអ្នកណាជាអ្នករៀបរៀងឯកសារដែលត្រូវធ្វើការផ្សាយនៅលើវិទ្យុផ្សាយសំឡេងរបស់ហ្នុងនោះ?

**លោក ញ៉ែម សំណាង៖**

អ៊ំៗយល់សំណួរទេអ៊ំ?

**ឆ៖** បាទ គឺបញ្ហាហ្នឹងទាក់-- លោកជំទាវ អៀង ធីរិទ្ធ គាត់ជាចាងហ្វាង។ ដូច្នោះ គាត់អ្នករៀបចំអាហ្នឹង ធ្វើម៉េចឲ្យផ្សាយហ្នឹង ឲ្យដើរ ឲ្យវិទ្យុនោះវាដើរ។

[១៥:០៤:១៦]

**ស៖** តើលោកបានដឹងថាមានការទំនាក់ទំនងរវាងវិទ្យុផ្សាយសំឡេងហ្នឹងនៅទីហាណូយជាមួយនឹងមេដឹកនាំចលនាតស៊ូដែលស្ថិតនៅក្នុងប្រទេសកម្ពុជាដែរឬទេ នាពេលនោះ?

**ឆ៖** ក្នុងនុ៎ងខ្ញុំដឹង គ្រាន់តែថាមានការណែនាំពីខាងក្នុងទៅ។ មានការទាក់ទងក្នុងការណែនាំជូនកាលការផ្សាយអីហ្នឹង គឺថា--

**ស៖** តើលោកអាចប្រាប់ខ្ញុំបានទេ ថាអ្នកណាជាផ្តល់សេចក្តីណែនាំ ឬក៏ការណែនាំនេះ? ហើយគេណែនាំបែបម៉េចដែរ?

ខ្ញុំមិនដឹងថាតើលោក ឡុង នរិន្ទ បានស្តាប់ឮសំណួរខ្ញុំទេ ថាតើការណែនាំពីមេដឹកនាំដែលស្ថិតនៅក្នុងប្រទេសកម្ពុជាហ្នឹង តើមានការណែនាំថាដូចម្តេចដែរ?

**ឆ៖** ខ្ញុំមិនបានដឹងទេអាហ្នឹង ពីព្រោះបញ្ជូនមកតាមទូរលេខ បញ្ជូនមកចាងហ្វាងវិទ្យុ។

**ស៖** តើលោកបានដឹងថា មានការណែនាំពីមេដឹកនាំដែលស្ថិតនៅក្នុងប្រទេសកម្ពុជា ណែនាំទៅដល់វិទ្យុផ្សាយសំឡេងនោះដោយរបៀបណា?

**ឆ៖** គឺមែនទែន ទៅតាមកម្ពស់រលកដែរ។ សូម្បីតែអត្ថបទហ្នឹងក៏អ៊ីចឹងៗដែរ អត់មានសរសេរនៅអីហាណូយទេ សរសេរពីស្រុក សរសេរពីក្នុងប្រទេសនេះទៅ ហើយផ្ញើអត្ថបទហ្នឹងទៅហាណូយទៅឲ្យវិទ្យុ។

[១៥:០៧:២៤]

**ស៖** តើលោកដឹងថា អ្នកណាដែលជាអ្នករៀបចំ ឬជាអ្នកសរសេរអត្ថបទនោះដើម្បីឲ្យផ្សាយនៅលើវិទ្យុនោះ?

**ឆ៖** ខ្ញុំមិនអាចដឹងបានទេ។ ពីព្រោះនេះវាជាការងារទៅខាងក្រុមវិទ្យុដែលនៅខាងក្នុងប្រទេសខ្ញុំគឺគ្រាន់តែទទួលអត្ថបទទៅជាអក្សរសម្ងាត់ ជាលេខសម្ងាត់ ហើយត្រូវបកអាលេខសម្ងាត់ហ្នឹងឲ្យទៅ

ជាភាសាខ្មែរយើង ងាយគេអាន។

**ស៖** សូមអរគុណលោក។ តើវិទ្យុនោះផ្សាយទៅកាន់ប្រទេសណាខ្លះដែរ ឬទៅកាន់តំបន់ ឬក៏ផ្នែកណាខ្លះដែរ?

**ឆ៖** វិទ្យុនោះមែនទែនផ្សាយទៅក្នុងប្រទេសផង ហើយផ្សាយទៅក្រៅប្រទេសផង។

**ស៖** តើវិទ្យុនោះបានផ្សព្វផ្សាយ ផ្សាយសំឡេងមកកាន់ប្រទេសកម្ពុជាដែរឬទេ?

**ឆ៖** បានៗផ្សាយជា-- តាមកម្ពស់រលកមកប្រទេសកម្ពុជាវិញ។ មែនទែនអត្ថបទសរសេរនៅប្រទេសកម្ពុជា ក៏ប៉ុន្តែដល់ទៅជាកម្ពស់រលកគឺផ្សាយពីហាណូយមក។

**ស៖** តើគេផ្សព្វផ្សាយមកកាន់ទូទាំងប្រទេសកម្ពុជាតែម្តង ឬគ្រាន់តែផ្សព្វផ្សាយមកកាន់តំបន់រំដោះតែប៉ុណ្ណោះ?

[១៥:០៩:៥៤]

**ឆ៖** អាហ្នឹងវាទាក់ទងទៅនឹងការដែលអត្ថបទដែលសរសេរពីក្នុងទៅហ្នឹង ថាម៉េច? ជួនកាលទាក់ទងពីរឿង ឧបមាថារឿងរៀបចំសហករណ៍ អាហ្នឹងគឺថាផ្សាយមកក្នុងវិញ ក៏និយាយពីរឿងផ្សាយពីរឿងរៀបចំសហករណ៍ហ្នឹងដែរ។

**ស៖** តើប្រធានបទ ឬក៏ថាកម្មវិធីបែបណាដែលគេផ្សព្វផ្សាយអំពីបញ្ហាសហករណ៍នុ៎ង?

**ឆ៖** ខ្ញុំមិនចាំទេ យូរណាស់ទៅហើយ។

**ស៖** សូមអរគុណលោក។ ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយនៅពេលដែលលោកត្រឡប់មកកាន់ប្រទេសកម្ពុជា នៅពេលដែលលោកត្រឡប់មកពីទីក្រុងហាណូយ។ តើលោកត្រឡប់មកកាន់ទីក្រុងភ្នំពេញតែម្តង ឬក៏លោកត្រឡប់ទៅធ្វើដំណើរទៅទីណាមុនសិន?

**ឆ៖** ពេលហ្នឹងគឺថាខ្ញុំមកតាមផ្លូវហូជីមិញ មកចូលឈប់នៅហាណូយ ហើយបានចេញពីហាណូយ មកតាមផ្លូវហ្នឹង មកភ្នំពេញ។ មកមែនទែនមិនទាន់មកភ្នំពេញភ្លាមទេ មែនទែនមកស្ទឹងត្រែងក្រចេះ ហើយកាត់កំពង់ចាម បានមកដល់ភ្នំពេញ។

[១៥:១២:០៨]

**ស៖** តើលោកមានបានចំណាយពេលវេលាស្នាក់នៅកំពង់ចាម ដើម្បីបម្រើការជូនបក្សនៅទីនោះ ឬក៏មុននឹងលោកមកដល់ភ្នំពេញនេះ?

**ឆ៖** កំពង់ចាម អត់មានបានធ្វើការអីទេ គឺថាមកកំពង់ចាមហ្នឹងគ្រាន់តែស្នាក់មួយយប់ប៉ុណ្ណឹង ហើយជិះឡានមកភ្នំពេញ។

**ស៖** តើលោកនៅចាំមន្ទីរមួយហៅថាមន្ទីរឃ-២០ ដែរឬទេ?

**ឆ៖** សួរម៉េចអំមិញហ្នឹង មិនដឹងមន្ទីរណាទេ?

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន! ការកែតម្រូវរបស់អ្នកប្រែ៖ តើលោកមាននៅចាំមន្ទីរមួយឈ្មោះថាមន្ទីរប-២០? សំណួរខ្ញុំសួរថាតើលោកធ្លាប់បានធ្វើការងារនៅមន្ទីរមួយហៅថាមន្ទីរប-២០ ដែរឬទេ?

**ឆ៖** ខ្ញុំអង្កាល់ដែលត្រឡប់មកពីហាណូយវិញហ្នឹងភ្លាមហ្នឹង អង្កាល់ដែលលើកដំបូងហ្នឹង ខ្ញុំអត់មកឆ្លងតាមប-២០ ទេ។ ខ្ញុំមកឆ្លងកំពង់ចាមតែម្តង កំពង់ចាមហើយមកភ្នំពេញ មកប-១។

[១៥:១៣:៥០]

**ស៖** សូមលោកជួយជម្រាបជូនអង្គជំនុំជម្រះថាតើមន្ទីរក-១ នេះ គឺជាមន្ទីរអីដែរ?

**ឆ៖** មន្ទីរប-១ គឺជាក្រសួងការបរទេស។

**ស៖** តើមន្ទីរប-១ ដែលលោកធ្វើការ ក្រោយពីលោកត្រឡប់មកពីទីក្រុងហាណូយហ្នឹង មន្ទីរប-១ ហ្នឹងមានទីតាំងស្ថិតនៅកន្លែងណាដែរ?

**ឆ៖** មន្ទីរប-១ ហ្នឹង គឺថាស្ថិតនៅផ្ទះកោងហ្នឹងតែហ្មង! ផ្ទះកោងនៅភ្នំពេញហ្នឹង។

**ស៖** លោកសំដៅទៅលើទីតាំងមួយដែលស្ថិតនៅក្នុងទីក្រុងភ្នំពេញមែនទេ?

**លោក ញ៉ែម សំណាង៖**

តើលោកសំដៅទៅលើទីតាំងមួយដែលស្ថិតនៅក្នុងទីក្រុងភ្នំពេញមែនទេ? សំដៅទៅលើទីតាំងដែលស្ថិតនៅក្នុងទីក្រុងភ្នំពេញណាអ៊ំ?

**ឆ៖** កាលដែលមកនោះអ្វែ?

**លោក ញ៉ែម សំណាង៖**

សូមជម្រាបលោកប្រធាន សូមអធ្យាស្រ័យសូមតាំងសំណួរម្តងទៀត ដោយសាក្សីពុំយល់។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញាតាំងសំណួរសាជាថ្មីម្តងទៀត សំណួរអម្បាញ់មិញចុងក្រោយនេះ ព្រោះសាក្សីស្តាប់មិនយល់អំពីសំណួរ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំមិនបានស្តាប់ឮចម្លើយលោកឲ្យបានពេញលេញទេ ប៉ុន្តែទីតាំងដែលលោកបានរៀបរាប់អំពីមន្ទីរប-១ នោះ តើលោកអាចរៀបរាប់បានទេតើទីតាំងមន្ទីរប-១ នេះស្ថិតនៅទីក្រុងភ្នំពេញ ឬក៏យ៉ាងណា?

**ឆ៖** នៅជិតក្រសួងសង្គមកិច្ច មែនទែនទៅ ឥឡូវនេះគឺមួយរយៈជាទីស្តីការនាយករដ្ឋមន្ត្រី។ ឥឡូវនេះមិនដឹងជាទៅជាស្អីទេ ខ្ញុំអត់ដឹងដែរឥឡូវ។ ខ្ញុំមិនដែលទៅភ្នំពេញផងឥឡូវនេះ។

**ស៖** មុននឹងខ្ញុំចូលទៅនិយាយដល់រយៈពេលដែលលោកធ្វើការនៅមន្ទីរប-១ នៅទីក្រុងភ្នំពេញ ខ្ញុំចង់សួរបញ្ជាក់ថា មុននឹងលោកត្រឡប់មកទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ តើលោកបានធ្វើការនៅការិយាល័យមួយនៅក្នុងស្រុកស្ទឹងត្រង់មែនទេ?

[១៥:១៧:១៦]

**ឆ៖** ក្រោយមកទៀតទេ នៅពេលដែលខ្ញុំទៅធ្វើការស្ទឹងត្រង់នោះ។

**ស៖** តើលោកធ្វើការនៅស្ទឹងត្រង់ហ្នឹងនៅក្នុងឆ្នាំណាដែរ? នៅពេលណាដែរ?

**ឆ៖** តាមខ្ញុំចាំគឺថា ពេលហ្នឹងសន្តិភាពហើយដែរ នៅកម្ពុជាយើងសន្តិភាពហើយ បានខ្ញុំមកដល់ភ្នំពេញ។ ខ្ញុំមកគឺចូលស្ទឹងត្រង់ហ្នឹងមួយភ្លែត រួចហួសមកភ្នំពេញ ហើយបានវិលទៅវិញ។

**ស៖** តើលោកបានធ្វើការងារនៅស្ទឹងត្រង់អស់រយៈពេលប៉ុន្មានដែរ? ហើយលោកធ្វើអ្វីដែរនៅទីនោះ?

**ឆ៖** ខ្ញុំនៅស្ទឹងត្រង់ បើតាមខ្ញុំចាំគឺ៦ខែ ហើយធ្វើការ គឺការបង្កបង្កើនផល ដាំដំឡូង ដាំពោត ។ល។

**ស៖** ចាតើការងារនេះគឺលោកធ្វើនៅមុន ឬក៏នៅក្រោយថ្ងៃរំដោះ១៧ មេសា ១៩៧៥?

**ឆ៖** ខ្ញុំនៅឯស្ទឹងត្រង់ឯណោះ ឬនៅភ្នំពេញនេះ? ខ្ញុំមិនចាំទេ ពីព្រោះខ្ញុំមិនដឹងពេលរំដោះហ្នឹងខ្ញុំនៅស្ទឹងត្រង់ ឬក៏ខ្ញុំមកភ្នំពេញហើយ។

**ស៖** តើលោកនៅចាំឈ្មោះមន្ទីរដែលលោកធ្វើការនៅស្ទឹងត្រង់នោះដែរឬទេ?

[១៥:១៩:៤៨]

**ឆ៖** ដែលធ្វើការនៅស្ទឹងត្រង់គឺនៅប-២០។ ហើយដំបូងធ្វើការនៅប-២០ រួចក្រោយមកទៀតធ្វើការនៅប-១៥។

**ស៖** តើប-២០ និងប-១៥ គឺគេធ្វើបំពេញកិច្ចការអីដែរ? មានមុខងារធ្វើអ្វីដែរ?

**ឆ៖** មុខងារកាលនៅប-២០ បង្កបង្កើនផល និងដាំបន្លែ ដាំស្ពៃ ដាំត្រប់ ដាំអីហ្នឹង ហើយដល់ទៅប-១៥ អាហ្នឹងរឹតតែច្បាស់ណាស់ទៀតហើយ គឺការដាំបន្លែ ហើយធ្វើចម្ការ។

**ស៖** តើអ្នកណាជាអ្នកគ្រប់គ្រងមន្ទីរទាំងពីរហ្នឹង គឺមន្ទីរប-២០ និងមន្ទីរប-១៥នេះ?

**ឆ៖** កម្មាភិបាលអង្គាល់ហ្នឹង គឺកម្មាភិបាលមកពីមូលដ្ឋាន។ ឥឡូវហ្នឹង ខ្ញុំភ្លេចឈ្មោះហើយ មិនដឹងឈ្មោះអីទេ។

**ស៖** នៅក្នុងអំឡុងពេលដែលលោកបំពេញការងារនៅប-២០ និងប-១៥ តើមាន ដែលមានទំនាក់ទំនងជាមួយនឹងមេមន្ទីរទាំងនេះដែរឬទេ?

**ឆ៖** ថាម៉េច?

**លោក ញ៉ែម សំណាង៖**

ទាំងពីរ។

**ឆ៖** ទាំងពីរហ្នឹងអ្ហេះ?

**លោក ញ៉ែម សំណាង៖**

បាទ។

**ឆ៖** កាលហ្នឹង ខ្ញុំជាយុទ្ធជន គេប្រើឱ្យខ្ញុំទៅណា ខ្ញុំទៅហ្នឹងហើយ។

**ស៖** នៅពេលមួយលោកបានទៅធ្វើការនៅព្រះវិហារ តើមែនទេ?

**លោក ញ៉ែម សំណាង៖**

សូមជម្រាបលោកប្រធាន អត់ឮអ្នកបកប្រែច្បាស់ ហើយឥឡូវនេះសាក្សីសុំអនុញ្ញាតទៅបន្ទប់ទឹក។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ អង្គជំនុំជម្រះអនុញ្ញាត។ អញ្ជើញទៅចុះ!

*(សាក្សីទៅបន្ទប់ទឹក)*

[១៥:២៥:១៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញាបន្តសំណួរ ហើយសួរសំណួរចុងក្រោយម្តងទៀត ពីព្រោះសាក្សី

ស្តាប់មិនបានទេ។ ហើយ សំណាង សូមសំណាងស្តាប់ឲ្យបាន ហើយពិនិត្យគាត់ភ្លាម បើសិនជាទំនងគាត់ស្តាប់មិនទេ ហើយ សំណាង ស្តាប់បាន សំណាង រំឭកឡើងវិញប្រាប់គាត់ ដូចអ្វីដែលបានធ្វើនេះថាគេសួរថាអីចេះ ប្រាប់គាត់ពីសំណួរទៅ ដើម្បីឲ្យបានលឿន។ ជៀសវាងគាត់ស្តាប់មិនយល់ ហើយសំណាង នៅចាំដែរ អីចឹងវាអាចបញ្ហាហ្នឹងទៅ វាអត់អាចបានចម្លើយទេ។

**លោក ញ៉ែម សំណាង៖**

បាទៗ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញ!

**សួរដោយលោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**ស៖** អ្វីដែលខ្ញុំបានសួរមុនពេលលោកនៅបន្ទប់ទឹកនោះ លោក ឡុង នរិន្ទ គឺសំណួរសួរថានៅពេលដែលលោកធ្វើការនៅ“ប-២០” និង“ប-១៥” ហើយក្រោយមក គឺលោកបានទៅកាន់ខេត្តព្រះវិហារ ហើយធ្វើការងារនៅទីនោះ មែនទេ?

**ឆ៖** បាទ, អង្គាល់ហ្នឹងគឺថា ខ្ញុំធ្វើការនៅៗការងារនៅ “ប-២០” រួចក្រោយមកទៅ “ប-១៥” ហើយរួចទៅបានទៅព្រះវិហារ។

**ស៖** អ្នកណាដែលជាអ្នកឲ្យលោកទៅធ្វើការនៅព្រះវិហារ?

**លោក ញ៉ែម សំណាង៖**

តើអ្នកណាឲ្យអ៊ំទៅធ្វើការនៅឯព្រះវិហារ?

**ឆ៖** ទៅព្រះវិហារគឺ ពេលទៅនោះ គឺថាប្រធានមន្ទីរ គេប្រាប់ថាឲ្យទៅអីចឹងហ្នង។ ប៉ុន្តែអ្នកដែលណែនាំទៅព្រះវិហារ តើត្រូវទៅធ្វើអីនោះ គឺឯកឧត្តម ខៀវ សំផន ហើយនិងលោកតា នួន ជា ណែនាំថាឲ្យទៅរៀនសូត្រពីប្រជាជន។

**ស៖** តើលោកបានជួបលោក នួន ជា លើកដំបូងនៅពេលណា?

**ឆ៖** គឺនៅពេលហ្នឹងៗ ដែល ពេលដែលមុនពេលទៅព្រះវិហារហ្នឹង ខ្ញុំបានជួបជាលើកដំបូងហើយហ្នឹង។

**ស៖** តើលោកបានជួបគាត់នៅទីណា?

[១៥:២៨:៥០]

**ឆ៖** គឺនៅពេលមុនចេញទៅព្រះវិហារ ខ្ញុំទៅចូល"ប-២០" សិន គឺនៅកន្លែងនុ៎ងហើយដែលជួបលោកទាំងពីរនុ៎ង ហើយណែនាំឲ្យទៅ-- អឺ ទៅធ្វើអីខ្លះ ទៅព្រះវិហារហ្នឹង។

**ស៖** តើលោកជួបលោក នួន ជា និងលោក ខៀវ សំផន នៅមុនពេលនេះ ឬក៏យ៉ាងម៉េច?

**ឆ៖** ពេលនុ៎ងគឺថាសង្គ្រាមវាធូរ ជិតចប់ហើយ អង្កាល់ហ្នឹង។

[១៥:៣០:០៥]

**ស៖** សំណួរខ្ញុំ គឺសួរថានេះគឺជាលើកដំបូងឬ ដែលលោកបានជួប នួន ជា និងលោក ខៀវ សំផន?

**លោក ញ៉ែម សំណាង៖**

អ៊ំយល់សំណួរទេអ៊ំ? សួរថាតើអ៊ំបានជួបលោក នួន ជា និងលោក ខៀវ សំផន ជាលើកដំបូង?

**ឆ៖** បាទ, គឺថាជួបជាលើកដំបូងហើយហ្នឹង។

**ស៖** នៅពេលដែលលោកបានជួបលោក នួន ជា និងលោក ខៀវ សំផន នៅមន្ទីរប-២០ តើលោកបានដឹងថាគាត់ទាំងពីរជាអ្នកណាទេ? ហើយបានដឹងថាគាត់ទាំងពីរមានតួនាទីអ្វីដែរទេ?

**ឆ៖** ពេលហ្នឹងខ្ញុំអត់ៗដឹងតួនាទីគាត់ជាស្អីទេ។ ដឹងគ្រាន់តែដឹងអាតួនាទីដែលចំហានោះ អាហ្នឹងដឹង។ ប៉ុន្តែឲ្យដឹងថាម៉េច អត់ដឹងទេ គឺគ្រាន់តែដឹងថាអ្នកដឹកនាំ។

**ស៖** អ្នកដឹកនាំអ្វី? តើលោកដឹងថាជាអ្នកដឹកនាំស្អីដែរ?

**ឆ៖** មែនទែនទៅអត់ដឹងជាអ្នកដឹកនាំស្អីទេ ក៏ប៉ុន្តែការដែលគាត់ណែនាំហ្នឹងវា គឺថាជារបៀបអ្នកដឹកនាំ។ ទៅព្រះវិហារក្តាប់សំណូមពររបស់ប្រជាជន ថាតើគាត់ចង់បានអី ពេលឯករាជ្យនេះ ហើយកុំឲ្យភ្ញាក់ផ្អើល បើសិនណាជាចប់សង្គ្រាមក៏កុំអាល់ទាមទារត្រឡប់មកភ្នំពេញវិញ-- ត្រឡប់មកប-២០ វិញអីហ្នឹង គឺមិនឲ្យទាមទារទេ។ ឲ្យនៅចាំទូរលេខមួយទៅទៀតពីៗដឹកនាំទៅ។

[១៥:៣២:៤០]

**ស៖** តើគាត់ទាំងពីរបានពន្យល់លោកថា ហេតុអ្វីបានជាគេឲ្យលោកនៅចាំនៅព្រះវិហារសិនរហូតដល់មានការជូនដំណឹងជាក្រោយទៀត?

**ឆ៖** ពេលនុ៎ងគាត់អត់បានប្រាប់ថាម៉េចទេ។ គ្រាន់តែប្រាប់ថា ឲ្យនៅចាំទូរលេខទៅសឹមមកអ្នកណាដឹងអាហ្នឹងសុទ្ធតែរឿងមជ្ឈិម ក្នុង។

**សៈ** តើគេអាចផ្ញើសារទូរលេខទៅឲ្យលោកនៅព្រះវិហារដោយរបៀបណាដែរ?

**លោក ញ៉ែម សំណាង៖**

សំណួរ ចង់សួរថាតើផ្ញើសារជាទូរលេខហ្នឹងទៅអ៊ំដោយរបៀបណា?

**ឆៈ** ខ្ញុំមិនដឹងជាផ្ញើ-- គេផ្ញើ-- អង្កាល់ហ្នឹងមិនដឹងផ្ញើយ៉ាងម៉េចទេ ក៏ប៉ុន្តែខ្ញុំទៅនៅព្រះវិហារ ខ្ញុំស្នាក់នៅផ្ទះមេភូមិ។ ដូច្នោះ លោកមេភូមិហ្នឹង គាត់យកសារទូរលេខហ្នឹងមកឲ្យ។

**សៈ** តើសារទូរលេខនោះផ្ញើមកពីណាដែរ ហើយសារទូរលេខនោះគឺគេសរសេរថាម៉េចដែរ?

**ឆៈ** មែនទែនទៅសារទូរលេខហ្នឹង គ្រាន់តែប្រាប់ថាឲ្យត្រឡប់មកភ្នំពេញតែប៉ុណ្ណឹងទេ។

**សៈ** តើសារទូរលេខនោះ គេផ្ញើទៅលោកតាម-- ដោយលោក នួន ជា ឬក៏លោក ខៀវ សំផន ជាអ្នកផ្ញើទៅលោកឬ?

**លោក ញ៉ែម សំណាង៖**

អ៊ំយល់ទេ អ៊ំ?

[១៥:៣៥:០០]

**ឆៈ** យល់។ មែនទែនទៅ សារទូលេខហ្នឹងមិនមែនផ្ញើមកខ្ញុំទេ គឺផ្ញើមកប្រធានភូមិ ផ្ញើមកកម្មាភិបាល។ ប្រាប់ថាឲ្យខ្ញុំត្រឡប់ទៅភ្នំពេញវិញ។

**សៈ** ខ្ញុំចង់បញ្ជាក់ឡើងវិញថា តើសារទូរលេខនេះ គឺគេប្រាប់ឲ្យកម្មាភិបាលទាំងអស់ឲ្យវិញត្រឡប់មកភ្នំពេញ ឬក៏ប្រាប់តែលោកម្នាក់ទេឲ្យវិលត្រឡប់មកភ្នំពេញ?

**ឆៈ** និយាយជារួមគឺថា ខ្ញុំទៅ អង្កាល់ដែលទៅព្រះវិហារហ្នឹងមិនមែនទៅតែខ្ញុំម្នាក់ឯងទេ គឺថាទៅដូចតាមខ្ញុំចាំដូច៦នាក់។ ប៉ុន្តែនាក់ដែលមកជាមួយខ្ញុំ គឺនែប្រធានភូមិប្រាប់ខ្ញុំថា ឥឡូវនែ! ពូអត់ទាន់ដឹងថាឯករាជ្យនៅឡើយទេ គេធ្វើបុណ្យឯករាជ្យរួចហើយ នៅភ្នំពេញនោះ។ ឥឡូវត្រូវពូត្រឡប់ទៅភ្នំពេញវិញ។

**សៈ** តើលោកបានដឹងថាប្រជាជននៅភ្នំពេញត្រូវបានគេជម្លៀស នៅពេលណាដែលលោកបានដឹងថាគេជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

**ឆៈ** ខ្ញុំអត់ដឹង។

[១៥:៣៦:៥៤]

**សៈ** តើលោកបានមកដល់ភ្នំពេញនៅពេលណា ក្រោយពីលោកវិលត្រឡប់មកពីព្រះវិហារ?

ឆ៖ គឺតាមខ្ញុំចាំ ដូចប្រហែលក្នុង២០មេសា។

ស៖ នៅពេលដែលលោកបានមកដល់ភ្នំពេញ តើលោកឃើញថាមានប្រជាជនរស់នៅក្នុងភ្នំពេញខ្លះៗដែរ ឬក៏ប្រជាជនទាំងអស់ត្រូវបានគេជម្លៀសចេញពីក្រុងភ្នំពេញហើយ?

ឆ៖ មិនទាន់ជម្លៀសចេញពីភ្នំពេញនៅឡើយទេ។ ពេលហ្នឹងមកដល់ក្រោយហ្នឹងមក ខ្ញុំឃើញតែប្រជាជនទៅរពុយចេញទៅក្រៅហ្នឹង ប៉ុន្តែមិនដឹងគេជម្លៀសទៅណា អីទៅណា ខ្ញុំអត់ដឹងទេអាហ្នឹង។

ស៖ តើអ្នកណាដែលបាននាំខ្លួន នាំលោកមកកាន់ទីក្រុងភ្នំពេញ?

ឆ៖ កាលហ្នឹងគឺថា នីរសារពីខាងព្រះវិហារនាំមកភ្នំពេញហ្នឹង។

[១៥:៣៨:៥៥]

ស៖ តើលោកមានការភ្ញាក់ផ្អើលទេ នៅពេលដែលលោកបានឃើញប្រជាជនធ្វើដំណើរចាកចេញពីទីក្រុងភ្នំពេញ?

ឆ៖ ពេលហ្នឹងមែនទែនទៅ ខ្ញុំអត់ដឹងថាប្រជាជនដែលចេញទៅរពុយហ្នឹងជាសុទ្ធតែប្រជាជនជម្លៀសទៅទេ។ ដូច្នេះ ខ្ញុំអត់ដឹងទេរឿងហ្នឹង។

ស៖ ចាតើលោកមានបានសួរអ្នកណាម្នាក់ថា ហេតុអ្វីបានជាគេជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទេ?

ឆ៖ អត់ទេ អត់បានសួរ។

[១៥:៤០:00]

ស៖ តើគេបានចាត់តាំងឲ្យលោកធ្វើអ្វីដែរនៅពេលលោកបានមកដល់ភ្នំពេញ?

ឆ៖ បានមកដល់ភ្នំពេញ ខ្ញុំ-- ឲ្យខ្ញុំមកធ្វើការនៅ-- យកខ្ញុំមកដាក់នៅផ្ទះកោង ហើយមានផ្ទះដែលសម្រាប់នៅ នៅខាងក្រោយហ្នឹង។

ស៖ តើផ្ទះកោងនេះជាផ្នែកមួយនៃមន្ទីរប-២០ ដែលជា-- មន្ទីរប-១ ដែលជាមន្ទីរមួយរបស់ក្រសួងការបរទេស ឬមិនមែនទេ?

ឆ៖ ផ្ទះកោងហ្នឹងជាមន្ទីរការបរទេសតែម្តង។

ស៖ តើផ្ទះកោងនេះគឺជាផ្ទះកោងដែលលោកបានធ្វើការចាប់តាំងពីខែមេសា ១៩៧៥ រហូតដល់ ៧ មករា ១៩៧៩ មែនទេ?

**ឆ៖** បាទ។
[១៥:៤១:៣០]
**ស៖** តើលោកដឹងថាមានបុគ្គលិក ឬកម្មាភិបាលប៉ុន្មាននាក់ដែរ ធ្វើការនៅក្រសួងការបរទេស?
**ឆ៖** ខ្ញុំអត់ដឹងទេ។
**ស៖** តើលោកអាចជម្រាបជូនយើងខ្ញុំបានទេ លោកមានតួនាទីធ្វើអ្វីដែរ នៅក្រសួងការបរទេសនេះ?
**ឆ៖** នៅក្រសួងការបរទេសនេះ ខ្ញុំវាយម៉ាស៊ីនតែប៉ុណ្ណឹង។
**ស៖** តើលោកវាយម៉ាស៊ីនហ្នឹង លោកវាយអ្វីដែរ វាយអត្ថបទអ្វីដែរ?
**ឆ៖** ខ្ញុំភ្លេចទៅហើយ មិនដឹងជាវាយអីខ្លះទេ។
**ស៖** តើលោកមានតួនាទីអីដែលត្រូវបំពេញប៉េបបទលិខិតឆ្លងដែន ប៉ាស្ព័រនេះដែរឬទេនៅក្នុងពេលហ្នឹង?
**ឆ៖** ពេលហ្នឹងខ្ញុំមានជួយធ្វើរឿងលិខិតឆ្លងដែនដែរ គឺសរសេរលិខិតឆ្លងដែន នរណាមួយត្រូវចេញទៅធ្វើការក្រៅអីហ្នឹង គឺសរសេរលិខិតឆ្លងដែនហ្នឹងទៅ រួចគេយកបាត់ទៅ។
**ស៖** តើលោកមានការទទួលខុសត្រូវអ្វី ទាក់ទងទៅនឹងលិខិតឆ្លងដែនរបស់ជនបរទេស ដែលត្រូវមកកាន់ប្រទេសកម្ពុជានាពេលនោះដែរឬទេ?
**ឆ៖** រឿងហ្នឹង ខ្ញុំអត់មានការទទួលខុសត្រូវអីទេ គឺថា គេមកគ្រាន់តែកត់ឈ្មោះគេ អ្នកណាមកពីប្រទេសណាធ្វើអី ហើយមកចូលមកកម្ពុជាហ្នឹងក្នុងឋានៈជាស្អីតែប៉ុណ្ណឹង។
**ស៖** អ្នកដែលមកពីប្រទេសក្រៅ តើលោកបាននិយាយជាមួយនឹងមនុស្សទាំងនេះ នៅកន្លែងណាដែរ?
**ឆ៖** ខ្ញុំអត់បាននិយាយជាមួយទេ ប៉ុន្តែគ្រាន់តែគេមកគេមានប៉ាស្ព័រគេ ហើយគេគ្រាន់តែ អ្នកដែលធ្វើការនៅកន្លែងហ្នឹង គឺថាមានកម្មាភិបាលប្រាប់ថា ម្នាក់នេះ គេសុំទៅណាអីចឹង។
[១៥:៤៥:៣៨]
**ស៖** តើលោកមានការទទួលខុសត្រូវណាមួយក្នុងការតាមដានអ្នកការទូតបរទេស ដែលមកទស្សនកិច្ចនៅប្រទេសកម្ពុជាដែរឬទេ?
**ឆ៖** ខ្ញុំអត់មានទេអាហ្នឹង។

**ស៖** នៅក្នុងអំឡុងពេលដែលលោកធ្វើការនៅក្រសួងការបរទេស តើមានអ្នកធ្វើការនៅក្រសួងការបរទេសបាត់ខ្លួនដែរឬទេ?

**ផ៖** អាហ្នឹង ខ្ញុំមិនច្បាស់ទេ។

**ស៖** តើលោកអាចមាននឹកឃើញ ឬក៏នៅចាំកម្មាភិបាលណាដែលត្រូវគេចាប់ខ្លួនពីក្រសួងការបរទេសដែរឬទេ?

**ផ៖** អត់ទេ ខ្ញុំអត់ចាំទេ ភ្លេចអស់ហើយ។

[១៥:៤៧:១៥]

**ស៖** តើគេមានដែលធ្លាប់ឲ្យលោកសរសេរប្រវត្តិរូបសង្ខេបរបស់លោក ដើម្បីជូនក្រសួងការបរទេសដែរឬទេ?

**ផ៖** ដែល។

**ស៖** សូមលោកជួយប្រាប់ខ្ញុំបន្តិច តើអ្នកណាជាអ្នកបញ្ជាឲ្យលោកសរសេរប្រវត្តិរូបរបស់លោកនេះ ហើយសរសេរដើម្បីស្អី?

**ផ៖** មែនទែន មេខ្ញុំផ្ទាល់ដែលនៅធ្វើការជាមួយគ្នានៅក្នុងមន្ទីរ ក្នុងផ្នែកហ្នឹងតែម្តង។

**ស៖** អ្នកណាដែលជាប្រធានផ្ទាល់របស់លោក ដែលបញ្ជាឲ្យលោកសរសេរប្រវត្តិរូបរបស់លោកហ្នឹង?

**ផ៖** ពេលហ្នឹង ប្រធានរបស់ខ្ញុំដែលផ្ទាល់ហ្នឹងគឺលោក សួង ស៊ីគឿន។

**ស៖** តើលោក សួង ស៊ីគឿន ហ្នឹងបានប្រាប់លោកថា ហេតុអ្វីបានជាគាត់ឲ្យលោកសរសេរប្រវត្តិរូបរបស់លោកនេះ?

**ផ៖** អត់បានប្រាប់ថាម៉េចទេ គ្រាន់តែថាឥឡូវសុំឲ្យមិត្តសរសេរប្រវត្តិរូប ហើយខ្ញុំក៏សរសេរទៅ។

[១៥:៤៩:៤៣]

**ស៖** តើមានអ្នកណាម្នាក់ធ្លាប់ប្រាប់លោកថា លោកត្រូវបានគេចោទប្រកាន់ថាលោកជាភ្នាក់ងារ សេ.អ៊ី.អា ដែរឬទេ?

**ផ៖** ហ្នឹងអត់មានទេខ្ញុំ ប៉ុន្តែដល់លោក អៀង សារី គាត់សួរខ្ញុំផ្ទាល់។ គាត់សួរថា "មិត្តចូល សេ.អ៊ី.អា ពីអង្កាល់មក?" ខ្ញុំថា "ខ្ញុំអត់មានដែលចូល សេ.អ៊ី.អា អីទេ"។ គាត់ថា "ចុះ មានស្គាល់ ថាច់

ជា ទេ?" ខ្ញុំថា "ស្គាល់ ពីព្រោះរៀនជំនាន់ជាមួយគ្នា ហើយលេងបាល់ លេងអី លេងបាល់ទាត់ជាមួយគ្នា វត់កីឡា ខាងរត់ចម្ងាយជាមួយគ្នា ប៉ុណ្ណឹង"។

**ស៖** តើលោក អៀង សារី សួរលោកអ៊ំនៅពេលណាដែរថា លោកអ៊ំជា សេ.អ៊ី.អា នុ៎ង?

**ឆ៖** គឺពេលខ្ញុំទៅហាណូយ។

**ស៖** ហើយបុគ្គលដែល អៀងសារី សួរលោកអ៊ំថា តើស្គាល់អត់នុ៎ង តើបុគ្គលនុ៎ងជានរណាដែរ?

**លោក ញ៉ែម សំណាង៖**

ម៉េចយល់ទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

បាទ?

**លោក ញ៉ែម សំណាង៖**

យល់ទេអ៊ំ សំណួរ?

**លោក ឡុង នរិន្ទ៖**

សួរថាម៉េចអំមិញ?

**លោក ញ៉ែម សំណាង៖**

សូមតាំងសំណួរម្តងទៀត។

**ស៖** សូមអភ័យទោស លោកអ៊ំបានបញ្ជាក់ថា លោកអ៊ំ-- លោកអៀង សារី បានសួរលោកអ៊ំថា តើលោកអ៊ំជា សេ.អ៊ី.អា ឬក៏មិនមែន? ហើយថា តើលោកអ៊ំស្គាល់បុគ្គលផ្សេងទៀតដែរឬទេ? ដូច្នេះ ខ្ញុំចង់ឲ្យលោកអ៊ំនិយាយឡើងវិញថា នៅពេលដែលលោក អៀង សារី សួរថា បុគ្គលនោះជានរណាហ្នឹង។ សូមឲ្យអ៊ំបញ្ជាក់មើលថា បុគ្គលដែល អៀង សារី ហ្នឹងគឺជានរណាដែរ?

**ឆ៖** គឺថាគាត់ជាចៅក្រសួងរបស់ខ្ញុំ គឺក្រសួងការបរទេសហ្នឹងឯង។

**ស៖** សូមអភ័យទោស។ ខ្ញុំមិនមែនសួរថា តើលោក អៀង សារី ជានរណានោះទេ។ តែខ្ញុំសូមឲ្យលោកអ៊ំរៀបរាប់ថា នូវឈ្មោះបុគ្គលទាំងឡាយដែលលោក អៀង សារី ស្គាល់បុគ្គលទាំងអស់មួយចំនួនដែរឬទេ។ សូមរៀបរាប់ឈ្មោះរបស់បុគ្គលទាំងអស់ដែលលោក អៀង សារី សួរលោកអ៊ំហ្នឹង?

**ឆ៖** អត់ទេ គាត់សួរតែ ថាច់ ជា មួយហ្នឹងទេ ប៉ុណ្ណឹង ហើយខ្ញុំក៏ឆ្លើយតែ ថាច់ ជា មួយហ្នឹងដែរ។

[១៥:៥៣:៤៧]

**ស៖** តើនរណាគេជា ថាច់ ជា នុ៎ង?

**ឆ៖** ថាច់ ជា ហ្នឹងគឺថា ចូលនៅសាលាគរុកោសល្យជំនាន់ខ្ញុំ ហើយរៀន ប៉ុន្តែរៀនថ្នាក់ខុសគ្នាទេ។ ប៉ុន្តែលេងកីឡា លេងអី គឺថាជាមួយគ្នា នៅក្នុងក្រុមជាមួយគ្នា គឺលេងឲ្យសាលាគរុវិជ្ជាហ្នឹងឯង។

**ស៖** ហេតុអ្វីបានជាលោក អៀង សារី ចាប់អារម្មណ៍នឹងករណីដែលថា លោកអ៊ំស្គាល់ ថាច់ ជា ហ្នឹង?

**ឆ៖** គឺៗក្នុងហ្នឹង ប្រហែលជា ថាច់ ជា ហ្នឹង គាត់ដឹងថា ថាច់ ជា សេ.អ៊ី.អា។ រួចពាក្យនេះក៏មានគេរាយការណ៍ទៅពីក្រោមអីថា ខ្ញុំនេះជិតស្និទ្ធជាមួយនឹង ថាច់ ជា ហ្នឹង បានជាលោកអ៊ំ អៀង សារី គាត់សួរខ្ញុំត្រង់ហ្នឹង។

[១៥:៥៥:១៣]

**ស៖** ថាតើលោក ថាច់ ជា ធ្វើការងារអ្វីដែរ ក្រោយពីឆ្នាំ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥? តើគាត់ជាកម្មាភិបាលនៅក្នុងក្រសួងការបរទេសដែរ ឬក៏យ៉ាងម៉េច?

**ឆ៖** ថាច់ ជា គាត់ជានិស្សិត សាស្ត្រាចារ្យផ្នែកអក្សរភាសាបារាំង។

**ស៖** ថាតើលោក ថាច់ ជា ហ្នឹងស្នាក់នៅក្នុងប្រទេសកម្ពុជាក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែរឬទេ? ថាតើគាត់ធ្វើការនៅកន្លែងណាដែរ?

**ឆ៖** អង្កាល់ពេលហ្នឹង គឺគាត់ស្នាក់នៅសាលាគរុកោសល្យហ្នឹងឯង ព្រោះគាត់ជានិស្សិតសាស្ត្រាចារ្យ ដូច្នោះរស់នៅសាលាហ្នឹង បានអាហារូបករណ៍ហូបបាយនៅហ្នឹង សម្រាកនៅហ្នឹង។ ក្រោយមកទៀតគាត់ទៅណា ខ្ញុំមិនដឹងទេ។

**ស៖** តើនរណាគេប្រាប់លោកថា ថាច់ ជាហ្នឹងជា សេ.អ៊ី.អា?

**ឆ៖** ខ្ញុំអត់ដឹងដែរ អាហ្នឹងមិនដឹងជាអ្នកណា មិនដឹងជាយ៉ាងម៉េចបានគាត់សួរតែ ថាច់ ជា ហ្នឹងមួយ រឿង ថាច់ ជា ហ្នឹង។

[១៥:៥៧:៣០]

**ស៖** តើលោក អៀង សារី បានប្រាប់លោកដែរឬទេថា លោក ថាច់ ជា បានឆ្លើយដាក់ថាលោកជា សេ.អ៊ី.អា ដែរ? តើគាត់មានប្រាប់អីចឹងទេ?

**ឆ៖** អត់ទេ។ លោក អៀង សារី អត់បានប្រាប់ថា ចាច់ ជាហ្នឹងជាស្អី អីអត់ទេ។

**ស៖** ក្រោយពេលដែលលោកនិយាយជាមួយនឹងលោក អៀង សារី ពីបញ្ហាហ្នឹងហើយ ទើបគេឲ្យលោកសរសេរប្រវត្តិរូបហ្នឹងមែនដែរឬទេ?

**ឆ៖** ក្រោយពីហ្នឹងមក គឺថាខ្ញុំត្រូវសរសេរប្រវត្តិរូបពីរឿងហ្នឹង ព្រោះខ្ញុំសរសេរមួយឆ្នាំ។

**ស៖** យើងមានឯកសារមួយដែលយើងខ្ញុំសូមបង្ហាញជូនលោកអ៊ំ ថាតើឯកសារនោះជាប្រវត្តិរូបរបស់លោកអ៊ំ ដែលលោកអ៊ំបានសរសេរដោយខ្លួនឯងដែរឬទេ? ដូច្នេះហើយយើងត្រូវការរៀបចំបង្ហាញជូនលោកអ៊ំ។

លោកប្រធាន ឯកសារមួយនោះយើងជឿថាជាប្រវត្តិរូបរបស់លោក ឡុង នរិន្ទ ដូច្នេះហើយបើសិនជាអាចធ្វើទៅបាន យើងខ្ញុំសូមដាក់បង្ហាញជូនលោក ឡុង នរិន្ទ ឲ្យគាត់មើល។

**ឆ៖** គេឲ្យឯកសារមួយ។

**លោក ញ៉ែម សំណាង៖**

គេបង្ហាញពីចម្ងាយឲ្យអ៊ំមើលឯកសារណាអ៊ំណា។

**ឆ៖** បាទ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងសមល្មមនឹងឈប់សម្រាកហើយសម្រាប់ថ្ងៃនេះ។ ដូច្នេះការ កិច្ចនៃការនីតិវិធីនៃការចាប់ផ្ដើមការបង្ហាញឯកសារហ្នឹង គឺយើងនឹងលើកយកទៅធ្វើទៅថ្ងៃស្អែក។ ចាប់ផ្ដើមដំបូងគឺយើងចាប់ផ្ដើមពីនីតិវិធីហ្នឹងតែម្ដង។ អ៊ីចឹងអង្គជំនុំជម្រះប្រកាសផ្អាកសម្រាប់កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងបន្តទៅព្រឹកថ្ងៃស្អែកចាប់ពីវេលាម៉ោងប្រាំបួនព្រឹកទៅ។ ដូច្នេះ សូមភាគីនិងសាធារណជនជ្រាប។ ហើយអ៊ំ ឡុង នរិន្ទ គឺថ្ងៃស្អែកជួបគ្នានៅម៉ោងប្រាំបួនព្រឹកចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងវិញ ហើយនិងឲ្យនាំគាត់មកសាលសវនាការនេះនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនជាកំណត់៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០១ នាទី)*